# សិក្សាព្រះសូត្រ

## ភាគទី ៨



រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**

# មាតិកា

| ឈ្មោះអត្ថបទ | ទំព័រ |
|---|---|
| ១- ៥០ព្រះសូត្រ ក្នុងបិដកមជ្ឈិមនិកាយ មូលបណ្ណាសក | ១ |
| ២- កន្ទរកសូត្រ | ១៥ |
| ៣- អដ្ឋកនាគរសូត្រ | ២៥ |
| ៤- សេក្ខប្បដិបទាសូត្រ | ៣៧ |
| ៥- បោតលិយសូត្រ | ៥១ |
| ៦- ជីវកសូត្រ | ៦៥ |
| ៧- ឧបាលិវាទសូត្រ | ៧៤ |
| ៨- កុក្កុរោវាទសូត្រ | ៨៣ |
| ៩- អភយរាជកុមារសូត្រ | ៨៩ |
| ១០- ពហុវេទនីយសូត្រ | ៩៩ |
| ១១- អបណ្ណកសូត្រ | ១១០ |

# ៥០ ព្រះសូត្រ ក្នុងបិដក
# មជ្ឈិមនិកាយ មូលបណ្ណាសក

**ក-មូលបរិយាយវគ្គ** មាន ១០ ព្រះសូត្រ គឺ

១- **មូលបរិយាយសូត្រ** សម្ដែងអំពីហេតុដែលជាមូល ៨ យ៉ាង គឺមូលរបស់បុថុជ្ជន ១ មូលរបស់ព្រះសេក្ខបុគ្គល ១ មូលរបស់ព្រះអរហន្តសាវ័ក ៤ និងមូលរបស់ព្រះតថាគត ២ ។ មូល ទាំង ៨ នេះ ប្រព្រឹត្តទៅក្នុង **សព្វធម្ម** ២៤ វារៈ ។

២- **សព្វាសវសំវរសូត្រ** សម្ដែងអំពីហេតុដែលធ្វើអាសវៈទាំងពួងរបស់បុគ្គលដែលបានសង្រួមហើយ ឲ្យដល់នូវការអស់ទៅ មិនកើតឡើងទៀតឡើយ ។ ហេតុនៃការលះបង់នូវអាសវៈទាំងឡាយ មាន ៧ ចំណែក ។

៣- **ធម្មទាយាទសូត្រ** សម្ដែងអំពីធម្មទាយាទប្បដិបទា គឺធម៌បដិបត្តិរបស់ភិក្ខុដែលជាធម្មទាយាទ អ្នកមានធម៌ជាមរតក ។

៤- **ភយភេរវសូត្រ** សម្តែងអំពីភ័យនិងសភាពដែលគួរឲ្យភ័យខ្លាចដល់ភិក្ខុដែលនៅក្នុងព្រៃ ព្រោះទោសទាំងឡាយ មានកាយកម្មមិនបរិសុទ្ធជាដើម ។

៥- **អនង្គណសូត្រ** សម្តែងអំពីបុគ្គល ៤ ពួក ដែលមានអង្គណៈ និងមិនមានអង្គណៈ រួចហើយសម្តែងអំពីអង្គណៈ គឺអកុសលធម៌ដ៏លាមកដែលបានគ្របសង្កត់ចិត្ត ដោយអំណាចនៃឥច្ឆាវចរៈ មាន ១៩ ។

៦- **អាកង្ខេយ្យសូត្រ** សម្តែងអំពីអានិសង្សសីល ១៧ ប្រការ គឺថា បើភិក្ខុមានសេចក្តីប្រាថ្នាក្នុង ១៧ ប្រការ គប្បីធ្វើសីលឲ្យបរិបូណ៌ ដែលសីលនេះជាបទដ្ឋាននៃសមថៈនិងវិបស្សនា ។

៧- **វត្ថូបមសូត្រ** សម្តែងអំពីឧបក្កិលេស ១៦ ដែល ធ្វើឲ្យចិត្តសៅហ្មង ឧបមាដូចសំពត់ប្រឡាក់មន្ទិលសៅហ្មង ។ សីល សមាធិ បញ្ញាដូចជាទឹកស្អាតដែលបោកលាងនូវឧបក្កិលេស របស់ចិត្ត ។

៨- **សល្លេខសូត្រ** សម្តែងអំពីធម៌ផ្សេងៗ គឺសល្លេខធម៌ ៤៤ មានការមិនបៀតបៀនគ្នាជាដើម ។ ត្រៃសរណគមន៍ជាបាទនៃលោកុត្តរធម៌ ។

៩- **សម្មាទិដ្ឋិសូត្រ** សម្តែងអំពីសម្មាទិដ្ឋិរបស់ព្រះអរិយ-សាវ័ក ១៦ វារៈ ។ ដោយសង្ខេប ១៦ វារៈ ដោយពិស្តារ ១៦ វារៈ ត្រូវជា ៣២ ស្ថាន ព្រះសារីបុត្តសម្តែងសច្ចៈ ៤ ក្នុង ៣២ ស្ថាន ។

១០- **សតិប្បដ្ឋានសូត្រ** សម្តែងអំពីទីតាំងនៃសតិ រលឹក ៤ ពួក គឺពួកកាយ ពួកវេទនា ពួកចិត្ត និងពួកធម៌ ។ នាមរូប មានការកើតរលត់ប្រាកដតាមទ្វារទាំង ៦ ជាអារម្មណ៍នៃវិបស្សនា ។

## ខ.**សីហនាទវគ្គ** មាន ១០ ព្រះសូត្រ គឺ

១- **ចូឡសីហនាទសូត្រ** សម្តែងអំពីសមណៈមាននៅតែក្នុងព្រះពុទ្ធសាសនានេះប៉ុណ្ណោះ ដោយការបន្លឺសីហនាទ ។

២- **មហាសីហនាទសូត្រ** សម្តែងអំពីកម្លាំងញាណ ទាំង ១០ ជាដើម របស់ព្រះតថាគតដោយការបន្លឺសីហនាទ ញ៉ាំងព្រហ្ម-ចក្រឲ្យប្រព្រឹត្តទៅ ។

៣- **មហាទុក្ខក្ខន្ធសូត្រ** សម្តែងអំពីការកំណត់ដឹងនូវកាមទាំងឡាយ ការកំណត់ដឹងនូវរូបទាំងឡាយ និងការកំណត់ដឹងនូវវេទនាទាំងឡាយ ជាពិសេសទោសរបស់កាមទាំងឡាយ ដែលត្រូវឃើញច្បាស់ក្នុងបច្ចុប្បន្ន ជាគំនរនៃទុក្ខ មានកាមជាហេតុ មាន

ច្រើនប្រការ ។

៤- **ចូឡទុក្ខក្ខន្ធសូត្រ** សម្ដែងអំពីកាមទាំងឡាយ មានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនោះ មានច្រើនក្រៃពេក ។

៥- **អនុមានសូត្រ** សម្ដែងអំពីធម៌ដែលធ្វើឲ្យជាអ្នកប្រដៅបានដោយក្រ មាន ១៦ យ៉ាង និងសម្ដែងឲ្យភិក្ខុទាំងឡាយ មាននូវអនុមានធម៌ គឺគប្បីពិចារណាថ្លឹងថ្លែងនូវខ្លួនដោយខ្លួនឯង ។

៦- **ចេតោខីលសូត្រ** សម្ដែងអំពី **ចេតោខីលៈ** គឺបង្គោលរបស់ចិត្ត ៥ ប្រការ និង **ចេតសោ វិនិពន្ធៈ** បានដល់ចំណងរបស់ចិត្ត ៥ ប្រការ ។

៧- **វនបត្ថសូត្រ** សម្ដែងអំពីហេតុនៃការនៅក្នុងព្រៃ ដល់ភិក្ខុទាំងឡាយ សំខាន់គឺកុសលធម៌ចម្រើនឡើង អកុសលធម៌ សាប-សូន្យទៅ រហូតសម្រេចព្រះអរហត្តផុតចាកទុក្ខទាំងពួង ។

៨- **មធុបិណ្ឌិកសូត្រ** សម្ដែងអំពី បុគ្គលមានវាទៈ យ៉ាងណា ដែលមិនមានជម្លោះជាមួយនឹងបុគ្គលនៅក្នុងលោកនេះ ជាដើមព្រះតថាគតក៏មានវាទៈយ៉ាងនោះ ។ ខ្លឹមសារនៃព្រះធម៌ប្រៀបបីដូចជានំផ្អែមដែលមានឱជារសពិសេស ។

៩- **ទ្វេធាវិតក្កសូត្រ** សម្តែងអំពីវិតក្កពីរចំណែក គឺ អកុសលវិតក្កមួយចំណែក និងកុសលវិតក្កមួយចំណែក ។ កុសល-វិតក្ក មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងជាដើម ជាវិតក្កធ្វើបញ្ញាឲ្យចម្រើន ជាចំណែកនៃសេចក្តីមិនចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

១០- **វិតក្កសណ្ឋានសូត្រ** សម្តែងអំពីការកម្ចាត់បង់ នូវអកុសលវិតក្កមាន ៥ បព្វៈ មានអញ្ញនិមិត្តបព្វៈ កំណត់និមិត្ត ដទៃជាដើម ។

## **គ-ឱបម្មវគ្គ** មាន ១០ ព្រះសូត្រ គឺ

១- **កកចូបមសូត្រ** ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើពួកចោរដែលប្រព្រឹត្តអាក្រក់ នាំគ្នាអារអវយវៈតូច ធំរបស់អ្នកទាំងឡាយ ដោយរណារដែលមានដងទាំងសងខាង ភិក្ខុណាមួយ ញ៉ាំងចិត្តឲ្យប្រទូស្តចំពោះចោរទាំងអម្បាលនោះ ភិក្ខុនោះមិនឈ្មោះថាជាអ្នកធ្វើតាមសាសនារបស់តថាគតឡើយ ព្រោះហេតុតែមិនមានការអត់ធន់នោះឯង ។

២- **អលគទ្ទូបមសូត្រ** សម្តែងអំពីការរៀនព្រះពុទ្ធវចនៈ

ដូចចាប់ពស់វែកត្រង់កន្ទុយ គឺថាពស់វែកនោះនឹងបែរខាំវិញ ព្រោះតែរៀនមិនល្អ ដូចអរិដ្ឋភិក្ខុជាដើម ។

៣- **ធម្មិកសូត្រ** សម្តែងអំពីបញ្ហាធម៌ ១៥ ចំណុច មានការចាប់ផ្តើមត្រង់ពាក្យថាដំបូក **ធម្មិកោតិ** នោះ ជាឈ្មោះនៃកាយនេះ ដែលប្រកបដោយមហាភូតរូប ៤ ។

៤- **រថវិនីតសូត្រ** សម្តែងអំពីវិសុទ្ធិ ៧ ប្រៀបដូចរថព្រះទីន័ងទាំង ៧ ដែលស្តេចត្រូវយាងបន្តគ្នា អំពីរថមួយទៅរថមួយទៀត ។

៥- **និវាបសូត្រ** សម្តែងអំពីកាមគុណ ៥ ប្រៀបដូចជាដំណាំដែលគេដាំធ្វើជានុយ សម្រាប់ចាប់ពួកម្រឹគ ។ ព្រះដ៏មាន-ព្រះភាគ ទ្រង់សម្តែងចែកពួកម្រឹគជា ៤ ពួក ។

៦- **បាសរាសិសូត្រ** សម្តែងអំពីការស្វែងរកពីរប្រការ គឺការស្វែងរកមិនប្រសើរ ១ និងការស្វែងរកដ៏ប្រសើរ ១ ។ បច្ច័យ ៤ ដូចអន្ទាក់ដែលព្រានដាក់ក្នុងព្រៃ ការបរិភោគបច្ច័យ ៤ ដោយមិនពិចារណា ដូចម្រឹគជាប់អន្ទាក់ហើយដេកសង្កត់អន្ទាក់នោះឯង ។

៧- **ចូឡហត្ថិបទោបមសូត្រ** សម្តែងអំពីព្រះញាណរបស់ព្រះដ៏មានព្រះភាគ ប្រៀបទៅនឹងស្នាមជើងដំរីដ៏ធំក្នុងព្រៃដំរី ។

អរិយសាវ័កឃើញគុណនៃព្រះរតនត្រ័យ ប្រៀបដូចជាព្រានដំរីក្នុងកាលដែលបានឃើញស្នាមជើងដំរីព្រៃធំឡើងៗ ដោយឡែកពីគ្នារហូតដល់ទៅបានឃើញទាំងដំរីដ៏ធំមែនទែននោះទៀតផង ។

៨- **មហាហត្ថិបទោបមសូត្រ** សម្ដែងអំពីកុសលធម៌ទាំងឡាយឯណានីមួយ កុសលធម៌ទាំងអស់នោះ តែងសង្គ្រោះចូលក្នុងអរិយសច្ច ៤ ប្រៀបដូចស្នាមជើងទាំងឡាយរបស់ពួកសត្វនៅលើផែនដី តែងប្រជុំចុះក្នុងស្នាមជើងដំរី ដូច្នោះឯង ។

៩- **មហាសារោបមសូត្រ** សម្ដែងអំពីព្រហ្មចរិយធម៌ប្រៀបដូចជាដើមឈើមួយដើម មានខ្លឹម មានស្រាយ មានសំបក មានក្រមរ និងមានមែកមានសន្លឹក ទាំងអស់ ៥ មុខ ។ លាភសក្ការៈ និងសេចក្ដីសរសើរ គឺជាមែកសន្លឹកនៃព្រហ្មចរិយធម៌ ១ សីល-សម្បទា គឺជាក្រមរនៃព្រហ្មចរិយធម៌ ១ សមាធិសម្បទា គឺជាសំបកនៃព្រហ្មចរិយធម៌ ១ ញាណទស្សនៈ បានដល់ទិព្វចក្ខុ គឺជាស្រាយនៃព្រហ្មចរិយធម៌ ១ ឯចំណែកអរហត្តផល គឺជាខ្លឹមនៃព្រហ្មចរិយធម៌នៅក្នុងមហាសារោបមសូត្រនេះ ១ ទៀត ជាគម្រប់ ៥ ។

១០- **ចូឡសារោបមសូត្រ** សម្ដែងអំពីខ្លឹមនៃព្រហ្មចរិយ-ធម៌ មានបឋមជ្ឈានជាដើម ជាបាទនៃវិបស្សនា និងជាបាទនៃ

និរោធសមាបត្តិ ព្រោះជាបាទដូច្នេះ ទើបរាប់ចូលក្នុងខ្លឹមនៃព្រហ្ម-ចរិយធម៌ ។ ខ្លឹមនៃព្រហ្មចរិយធម៌ជាទីបំផុត គឺព្រះអរហត្តផល ។

## ឃ-**មហាយមកវគ្គ** មាន ១០ ព្រះសូត្រ គឺ

១-**ចូឡគោសិង្គសាលសូត្រ** សម្ដែងអំពីព្រះដ៏មាន-ព្រះភាគ ទ្រង់យាងចូលកាន់ព្រៃគោសិង្គសាលវ័ន ជួបនឹងព្រះអនុរុទ្ធជាដើម ព្រះអង្គប្រទានសាធុការចំពោះការព្រមព្រៀងស្រុះស្រួល មិនទាស់ទែងគ្នា ដូចជាទឹកដោះលាយទឹក រមិលមើលគ្នាទៅវិញទៅមកដោយចក្ខុគួរឲ្យស្រឡាញ់ ។

២-**មហាគោសិង្គសាលសូត្រ** សម្ដែងអំពីព្រៃគោសិង្គ-សាលវ័ន រុងរឿងដោយភិក្ខុអង្គណា ដែលក្នុងពេលនោះ ព្រះ-ដ៏មានព្រះភាគ ទ្រង់គង់នៅជាមួយនឹងព្រះថេរៈ សុទ្ធតែមានព្រះនាមល្បីៗជាច្រើនព្រះអង្គ មានព្រះអគ្គសាវ័កជាដើម ព្រមដោយភិក្ខុសង្ឃប្រមាណជាបីម៉ឺនអង្គ ។

៣- **មហាគោបាលសូត្រ** សម្ដែងអំពីអង្គ ១១ នៃអ្នកគង្វាលគោ ដែលមិនអាចដើម្បីរក្សាហ្វូងគោឲ្យចម្រើនបានឡើយ ហើយអង្គ ១១ ផ្ទុយគ្នាក៏ព្រះអង្គទ្រង់សម្ដែង ។

៤- **ចូឡគោបាលសូត្រ** សម្តែងអំពីគង្វាលគោល្ងង់ខ្លៅ ចម្លងគោកាត់ទន្លេគង្គា ធ្វើឲ្យហ្វូងគោដល់នូវសេចក្តីវិនាស និង គង្វាលគោជាអ្នកមានប្រាជ្ញា ចម្លងគោឲ្យហែលឆ្លងកាត់ទន្លេគង្គា យ៉ាងមានសុវត្ថិភាព ។

៥- **ចូឡសច្ចកសូត្រ** សម្តែងអំពីនិគន្ថបុត្រឈ្មោះសច្ចកៈ ជាអ្នកពោលនូវតិរច្ឆានកថា អួតខ្លួនថាជាអ្នកប្រាជ្ញ មានការលើក វាទៈប្រកាន់យកតួខ្លួន ឆ្លើយឆ្លងជាមួយនឹងព្រះដ៏មានព្រះភាគ ។

៦- **មហាសច្ចកសូត្រ** សម្តែងអំពីកាយភាវនា និងចិត្ត-ភាវនាដល់សច្ចកនិគន្ថបុត្រ ដែលមិនទាន់អស់ចិត្តក្នុងការលើក វាទៈ ។ ពីរព្រះសូត្រនេះ ធ្វើឲ្យសច្ចកនិគន្ថបុត្រ មានឧបនិស្ស័យ សម្រេចព្រះអរហត្តក្នុងជាតិក្រោយ ក្នុងពុទ្ធសករាជជាងពីររយ ជា ព្រះមហាខីណាស្រព ព្រះនាមពុទ្ធរក្ខិត នៅចេតិយបព៌តមហាវិហារ នាតម្ពបណ្ណិទ្វីប ។

៧- **ចូឡតណ្ហាសង្ខយសូត្រ** សម្តែងអំពីភិក្ខុជាអ្នកមាន ចិត្តបង្អោនទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហា ចាប់ផ្តើមនៅ ត្រង់ភិក្ខុក្នុងសាសនានេះ បានស្តាប់ពាក្យថា **សព្វេ ធម្មា នាលំ អភិនិវេសាយាតិ** បុគ្គលមិនគួរប្រកាន់នូវធម៌ទាំងពួង ( ឧបាទាន-

ក្ខន្ធ ៥ ) ដោយអំណាចនៃតណ្ហានិងទិដ្ឋិដែលជាអភិនិវេសៈ ។

៨- **មហាតណ្ហាសង្ខយសូត្រ** សម្ដែងអំពី វិញ្ញាណកើតឡើងអំពីបច្ច័យ ព្រមដោយធម៌បដិបត្តិបង្អោនចិត្តទៅរកការអស់តណ្ហា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឲ្យភិក្ខុទាំងឡាយចាំទុកនូវសាតិភិក្ខុកេវដ្ដបុត្ត ថាជាអ្នកជាប់ក្នុងសំណាញ់ដ៏ចង្អៀតគឺមហាតណ្ហានេះ ដូច្នេះឯង ។

៩- **មហាអស្សបុរសូត្រ** សម្ដែងអំពីការប្រព្រឹត្តខ្លួនឲ្យសមនឹងឈ្មោះថាសមណៈ ឲ្យសមនឹងសេចក្ដីជ្រះថ្លារបស់អ្នកស្រុកក្នុងអស្សបុរនិគម ដែនអង្គៈ ។

១០- **ចូឡអស្សបុរសូត្រ** សម្ដែងអំពីបដិបទាដ៏សមគួររបស់សមណៈ ព្រោះប្រតិបត្តិលះបង់នូវមន្ទិលរបស់សមណៈ ១២ យ៉ាង មានអភិជ្ឈា និងព្យាបាទ ជាដើម ។

## ខ~**ចូឡយមកវគ្គ** មាន ១០ ព្រះសូត្រ គឺ

១- **សាលេយ្យកសូត្រ** សម្ដែងអំពីហេតុដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ស្លាប់ទៅកើតក្នុងអបាយភូមិ និងពួកខ្លះទៀតកើតក្នុងសុគតិភូមិ តាមដែលអ្នកស្រុកសាលគ្រាមបានក្រាបទូលសួរ

ព្រះដ៏មានព្រះភាគ ។

២- **វេរញ្ជកសូត្រ** សម្តែងអំពីហេតុដែលនាំឲ្យបដិសន្ធិក្នុងទុគ្គតិភព និងសុគតិភពដូចសាលេយ្យកសូត្រដែរ តាមដែលអ្នកស្រុកវេរញ្ជានាំគ្នាក្រាបទូលសួរព្រះដ៏មានព្រះភាគ គ្រាន់តែព្រះសូត្រមុនទ្រង់សម្តែងជាធម្មាធិដ្ឋាន ចំណែកវេរញ្ជកសូត្រនេះ ព្រះអង្គទ្រង់ត្រាស់សម្តែងជាបុគ្គលាធិដ្ឋានប៉ុណ្ណោះ ។

៣- **មហាវេទល្លសូត្រ** សម្តែងឆ្លើយបញ្ហាធម៌ ៣២ ចំណុច ដែលមានសេចក្តីប្រាកដច្បាស់ដល់អ្នកសួរ និងនាំមកនូវសេចក្តីត្រេកអរ ទាំងធ្វើឲ្យមានការសាកសួរជាបន្តនូវសំណួរល្អិតល្អន់ជ្រាលជ្រៅ ហៅថា **វេទល្ល:** ។

៤- **ចូឡវេទល្លសូត្រ** សម្តែងឆ្លើយបញ្ហាធម៌ ៣៤ ចំណុច ដែលវិសាខឧបាសកសាកសួរចំពោះព្រះនាងធម្មទិន្នាភិក្ខុនីជាបណ្ឌិត ។

៥- **ចូឡធម្មសមាទានសូត្រ** សម្តែងអំពីធម្មសមាទាន ៤ យ៉ាង គឺ១- សុខក្នុងបច្ចុប្បន្នប៉ុន្តែមានវិបាកជាទុក្ខតទៅ ២-ទុក្ខក្នុងបច្ចុប្បន្នទាំងមានវិបាកជាទុក្ខតទៅ ៣-ទុក្ខក្នុងបច្ចុប្បន្នប៉ុន្តែមានវិបាកជាសុខតទៅ ៤-សុខក្នុងបច្ចុប្បន្នទាំងមានវិបាកជាសុខតទៅ។

៦- **មហាធម្មសមាទានសូត្រ** សម្តែងអំពីបំណងប្រាថ្នារបស់សត្វទាំងឡាយ គឺប្រាថ្នាឲ្យអារម្មណ៍ល្អៗ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត គប្បីចម្រើនឡើង ប៉ុន្តែទោះជាសត្វទាំងឡាយប្រាថ្នាដូច្នេះក៏ដោយ ក៏មិនបានសម្រេចដូចប្រាថ្នា បែរទៅជាបានតែអារម្មណ៍មិនល្អទៅវិញ តើព្រោះហេតុអ្វី ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងនូវធម្មសមាទាន ៤ យ៉ាង ។

៧- **វីមំសកសូត្រ** សម្តែងអំពីការពិចារណាបីយ៉ាង គឺ ១-ពិចារណាអត្ត ២-ពិចារណាសង្ខារធម៌ ៣-ពិចារណារកគ្រូ ។ នៅក្នុងព្រះសូត្រនេះ សំដៅយកការពិចារណារកគ្រូជាខ្លឹមសារ រកកល្យាណមិត្តដែលត្រូវសេពគប់ ។

៨- **កោសម្ពិយសូត្រ** សម្តែងអំពីសារាណីយធម៌ ៦ ប្រការ និងញាណ ៧ យ៉ាងរបស់ព្រះសោតាបន្នបុគ្គល គឺព្រះបរមសាស្តាទ្រង់ត្រាស់សម្តែងធម៌នេះ នៅឯ **ឃោសិតារាម នគរកោសម្ពី** សម័យដែលពួកភិក្ខុឈ្លោះទាស់ទែងគ្នា ។

៩- **ព្រហ្មនិមន្តនិកសូត្រ** សម្តែងអំពីព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ព្រហ្មលោកសម្តែងធម៌ប្រោសពកព្រហ្ម ញ៉ាំងព្រហ្មប្រមាណ ១ ម៉ឺនអង្គឲ្យបានលុះលោកុត្តរធម៌ ។

១០- **មារតជ្ជនីយសូត្រ** សម្តែងអំពីព្រះមហាមោគ្គល្លាន-ត្ថេរបណ្តេញមារ និងទូន្មានមារ កុំឲ្យបៀតបៀនព្រះតថាគត កុំឲ្យបៀតបៀនសាវ័ករបស់ព្រះតថាគតឡើយ ។ មានប្រវត្តិរឿងរ៉ាវរបស់ទូសីមារ ដែលជាអតីតជាតិនៃព្រះមហាមោគ្គល្លានត្ថេរហ្នឹងឯង ។

# ចំណាំព្រះសូត្រក្នុងបិដក

បិដកលេខ ២០ មានពីរវគ្គ គឺ មូលបរិយាយវគ្គ និងសីហនាទវគ្គ ត្រូវជា ២០ ព្រះសូត្រ ។

បិដកលេខ ២១ មានមួយវគ្គ គឺ ឱបម្មវគ្គ សុទ្ធតែសម្តែងដោយឧបមាទាំង ១០ ព្រះសូត្រ ។

បិដកលេខ ២២ មានពីរវគ្គ គឺមហាយមកវគ្គ និងចូឡយមកវគ្គ ត្រូវជា ២០ ព្រះសូត្រ ដោយមានព្រះសូត្រជាគូៗហៅថាយមកៈ ។

# ព្រះសុត្តន្តបិដកខ្មែរលេខ ២៣

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក
## គហបតិវគ្គ
## មាន ១០ ព្រះសូត្រ គឺ

| | |
|---|---|
| ១- កន្ទរកសូត្រ | ២- អដ្ឋកនាគរសូត្រ |
| ៣- សេក្ខប្បដិបទាសូត្រ | ៤- បោតលិយសូត្រ |
| ៥- ជីវកសូត្រ | ៦- ឧបាលិវាទសូត្រ |
| ៧- កុក្កុរោវាទសូត្រ | ៨- អភយរាជកុមារសូត្រ |
| ៩- ពហុវេទនីយសូត្រ | ១០- អបណ្ណកសូត្រ |

# ១.កន្ទរកសូត្រ

ព្រះដ៏មានព្រះភាគទ្រង់គង់នៅជិតឆ្នេរស្រះគគ្គរា ក្បែរក្រុងចម្ប៉ា ជាមួយនឹងភិក្ខុសង្ឃច្រើនអង្គ មិនមានកំណត់ចំនួន គ្រានោះឯង ឧបាសកឈ្មោះបេស្សៈកូនទមម័កដំរី និងកន្ទរកបរិព្វាជក នាំគ្នាចូលគាល់ព្រះដ៏មានព្រះភាគ ។

កន្ទរកបរិព្វាជក ចាប់ផ្តើមទូលព្រះដ៏មានព្រះភាគ អំពីភិក្ខុសង្ឃដែលគង់នៅស្ងៀមស្ងាត់ ហើយបានពោលសរសើរព្រះដ៏មាន-ព្រះភាគ ក្នុងការទូន្មានភិក្ខុសង្ឃឲ្យប្រតិបត្តិដោយល្អ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីភិក្ខុសង្ឃទាំងអស់នេះមានពួកភិក្ខុខ្លះជាព្រះអរហន្ត និងមានពួកភិក្ខុខ្លះជាព្រះសេក្ខបុគ្គលមានសីលជាប់ជានិច្ច មានបញ្ញាខ្ជាប់ខ្ជួន តម្កល់ចិត្តស៊ប់ក្នុងសតិប្បដ្ឋាន ៤ ។

ជាបន្ត បេស្សឧបាសកបានក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ឯពួកខ្ញុំព្រះអង្គជាគ្រហស្ថស្លៀកពាក់ស តែងមានចិត្តតាំងល្អក្នុងសតិប្បដ្ឋានទាំង ៤ តាមកាលដ៏សមគួរដែរ ។

**ភាលេន ភាលំ** អដ្ឋកថាពន្យល់ថា ឱកាសតាមកាលដ៏សមគួរហើយ ទើបធ្វើទុកក្នុងចិត្តដោយយោនិសោមនសិការ ក្នុងសេចក្តីដែលថា សូម្បីតែពួកខ្ញុំព្រះអង្គធ្វើនូវការងារជាគ្រហស្ថ ក៏មិនលះបង់នូវកម្មដ្ឋានដោយប្រការទាំងពួង ។

បេស្សឧបាសក បានឧទានថា ជាការអស្ចារ្យចម្លែកណាស់ត្រង់ដែលមនុស្សមានចិត្តសាំញ៉ាំ ស្រកេកស្រកាកមិនបរិសុទ្ធ មានកិច្ចកលប្រព្រឹត្តទៅយ៉ាងនេះ ព្រះដ៏មានព្រះភាគគង់ជ្រាបនូវការប្រព្រឹត្តជាប្រយោជន៍ និងមិនជាប្រយោជន៍ នៃមនុស្សទាំងនោះជាប្រាកដ ។

សតិប្បដ្ឋានប្បដិបត្តិ ជាធម៌អប់រំចិត្ត ធ្វើបុគ្គលដែលសៅហ្មងដោយកិលេស ឲ្យបានជាបុគ្គលបរិសុទ្ធ រលត់ទុក្ខ ដូច្នេះហើយទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងនូវបុគ្គល ៤ ពួក ដែលតែងតែមានក្នុងលោក។ ៤ ពួកគឺ

ពួកទី ១- ព្យាយាមដុតកម្តៅខ្លួនឯង បានដល់ ពួកធ្វើខ្លួនឲ្យទុក្ខលំបាកឥតប្រយោជន៍ ។

ពួកទី ២- ព្យាយាមដុតកម្តៅអ្នកដទៃ បានដល់ ពួកអ្នកកាប់សម្លាប់ បៀតបៀនមនុស្សសត្វទាំងឡាយ ។

ពួកទី ៣- ព្យាយាមដុតកម្ដៅទាំងខ្លួនឯង ទាំងអ្នកដទៃ បានដល់ ពួកអ្នកដែលធ្វើខ្លួនឯងឲ្យទុក្ខលំបាកឥតប្រយោជន៍ ព្រោះការប្រកាន់ក្នុងសីលព្វតបរាមាសៈ ព្រមទាំងធ្វើការបូជាយញ្ញសម្លាប់សត្វទៀតផង ។

ពួកទី ៤- មិនព្យាយាមដុតកម្ដៅខ្លួនឯង និងអ្នកដទៃ ជាអ្នកអស់សេចក្ដីស្រេកឃ្លានក្នុងបច្ចុប្បន្ន ជាអ្នករលត់ទុក្ខ មានភាពត្រជាក់ទទួលនូវសេចក្ដីសុខ មានខ្លួនដ៏ប្រសើរ ។

បុគ្គលបីពួកខាងដើមនោះឯង ដែលព្រះអង្គទ្រង់ជ្រាបថា មិនជាប្រយោជន៍ក្នុងការប្រព្រឹត្តនៃពួកមនុស្សទាំងនោះ ចំណែកបុគ្គលពួកទី ៤ គឺព្រះអង្គទ្រង់ជ្រាបថា ជាប្រយោជន៍ក្នុងការប្រព្រឹត្តពិតៗនៃបុគ្គលពួកនេះ ។

បុគ្គលពួកទី ៤ នេះឯង ដែលអប់រំចម្រើនសតិប្បដ្ឋាន មានអានិសង្សដូចដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្ដែង ហើយអដ្ឋកថាពន្យល់ដូចតទៅ ៖

បទថា **ទិដ្ឋេវ ធម្មេ** គឺក្នុងអត្តភាពបច្ចុប្បន្ននេះ ។

បទថា **និច្ឆាតោ** គឺមិនមានការស្រេកឃ្លាន ។ តណ្ហាលោកហៅថា **ឆាត** ឈ្មោះថា **និច្ឆាតោ** ព្រោះមិនមានតណ្ហា ។

បទថា **និព្វុតោ** គឺរលត់កិលេសបានទាំងអស់ ។

បទថា **សីតីភូតោ** គឺជាបុគ្គលត្រជាក់ ព្រោះមិនមានកិលេសដែលធ្វើឲ្យក្តៅក្រហាយជាខាងក្នុង ។

បទថា **សុខប្បដិសំវេទី** គឺសោយសុខដែលកើតអំពីឈាន មគ្គផលនិងនិព្វាន ។

បទថា **ព្រហ្មភូតេន អត្តនា** គឺមានខ្លួនដ៏ប្រសើរ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលបេស្សៈ បណ្តាបុគ្គលទាំង ៤ ពួកនេះ តើបុគ្គលពួកណា ធ្វើចិត្តអ្នកឲ្យត្រេកអរបាន ។ បេស្សឧបាសក ក្រាបទូលព្រះដ៏មានព្រះភាគសំដៅយកបុគ្គលពួកទី ៤ នេះឯង ។

កាលដែលបេស្សឧបាសក បានក្រាបថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ចេញទៅមិនទាន់បានយូរប៉ុន្មាន គ្រានោះព្រះបរមសាស្តាទ្រង់ត្រាស់ទៅនឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បេស្សហត្ថារោហបុត្ត ជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ បេស្សហត្ថា-រោហបុត្ត ជាអ្នកមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបេស្សហត្ថារោហបុត្ត អង្គុយនៅមួយស្របក់ទៀត ទម្រាំតថាគតនឹងចែកនូវបុគ្គលទាំង ៤ ពួកនេះ ដោយពិស្តារសិន គាត់មុខជានឹងបានសម្រេចនូវប្រយោជន៍ច្រើន ( ដល់សោតាបត្តិផល ) ម្នាលភិក្ខុ

ទាំងឡាយ ទោះជាដូច្នោះ បេស្សហត្ថារោហបុត្តក៏នៅតែបានប្រកប ដោយប្រយោជន៍ច្រើនដែរ ( គឺបានសេចក្តីជ្រះថ្លាក្នុងភិក្ខុសង្ឃផង កើតសេចក្តីយល់ជាថ្មីបន្ថែមឡើងទៀត ក្នុងការចម្រើនសតិប្បដ្ឋាន)។

បទថា **បណ្ឌិតោ** ក្នុងទីនេះ គប្បីពោលថា ជាបណ្ឌិតព្រោះ ធ្វើកម្មក្នុងសតិប្បដ្ឋាន ( **សតិប្បដ្ឋានេសុ បន កម្មំ ករោតីតិ បណ្ឌិតោតិ វត្តុំ វដ្ដតិ** ) ។

បទថា **មហាបញ្ញោ** ក្នុងទីនេះដែរ គួរពោលថា ជាបុគ្គល មានបញ្ញាច្រើន ព្រោះប្រកបដោយបញ្ញាកំណត់កាន់យកសតិប្បដ្ឋាន ( **សតិប្បដ្ឋានបរិគ្គាហិកាយ បន បញ្ញាយ សមន្នាគតត្តា មហាបញ្ញោតិ វត្តុំ វដ្ដតិ** ) ។

បេស្សឧបាសក ប្រញាប់ក្រាបទូលលាព្រះដ៏មានព្រះភាគ ចេញទៅ ធ្វើឲ្យខកខានមិនបានសម្រេចសោតាបត្តិផលពេលនោះ ព្រោះកិរិយារបស់ខ្លួនហ្នឹងឯង ។ អន្តរាយមគ្គផល អដ្ឋកថា ពន្យល់ ថាមានពីរយ៉ាង គឺ ១- ដោយកិរិយា និង ១ទៀត ដោយការសេពគប់ នឹងបាបមិត្ត ។ ដោយកិរិយា ចែកទៅតាមកិរិយាអ្នកសម្តែងធម៌ប្រាប់ និងកិរិយាអ្នកស្តាប់ ប៉ុន្តែដោយកិរិយាអ្នកសម្តែងធម៌ ត្រូវវៀរ ព្រះសម្មាសម្ពុទ្ធចេញ ឯកិរិយាអ្នកស្តាប់គឺដូចបេស្សឧបាសកជា ដើម កាលទេសនានៅមិនទាន់ចប់ ឬមិនទាន់ស្តាប់ឲ្យពិស្តារ ក៏

បានលាចេញទៅ ។ ចំណែកអន្តរាយព្រោះបាបមិត្ត មានព្រះបាទ-អជាតសត្តុ ជាដើម ។

នៅខាងចុងនៃព្រះសូត្រនេះ កាលភិក្ខុទាំងឡាយ ក្រាបទូលអារាធនាហើយ ព្រះដ៏មានព្រះភាគបានសម្តែងចែកបុគ្គល ៤ ពួកឲ្យពិស្តារ ធ្វើឲ្យពួកភិក្ខុទាំងនោះ មានចិត្តត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ។

**សូមអនុមោទនា !**

# សតិរលឹកដឹងត្រូវ

គំនិតមនុស្សយើងសំខាន់ខ្លាំងណាស់ ប៉ុន្តែដែលច្បាស់នៅលើសតិ
ដឹងនូវគំនិតគិតល្អសុចិ ឬជាទិដ្ឋិគំនិតយល់ខុស ។
បើនឹងនិន្ទាទោសអ្នកដទៃ ត្រូវលៃឲ្យចំសមនឹងកំហុស
កុំព្រោះតែស្អប់កប់គុណកាយទោស គំនិតយល់ខុសទ្រុស្តនឹងអ្នកចេះ។
កុំចង់បានល្អពីគ្នាសព្វគ្រប់ មនុស្សកើតក្នុងភពជាប់ដោយកិលេស
បើយើងគ្រាន់បើប្រសើរវិសេស ត្រូវលះកិលេសពីចិត្តខ្លួនឯង ៕

ដោយ **ច.ស.ទ.**

# មនុស្សស្អាតមនុស្សល្អ

| | | |
|---|---|---|
| មនុស្សដែលស្អាត | ស្អាតចរិយា | វាចាផ្អែម |
| ផ្សំបន្ថែម | នូវចំណេះ | ចេះកោតក្រែង |
| មនុស្សដែលល្អ | ល្អទឹកចិត្ត | ឥតហួងហែង |
| ចេះលើកលែង | ឲ្យអភ័យ | លែលោះលាយ ។ |
| មនុស្សអ្នកមាន | មានទានសីល | មន្ទិលខ្វាត់ |
| មានសម្បត្តិ | បុណ្យខ្លួនឯង | ពីព្រេងនាយ |
| មនុស្សបានសុខ | សុខស្ងប់ចិត្ត | ជីវិតងាយ |
| រស់រីករាយ | មានសំណាង | សាងព្រហ្មយាន ។ |
| មនុស្សធំខ្ពស់ | ខ្ពស់ឧត្តម | សមជាព្រហ្ម |
| ថ្វាយបង្គំ | ត្រៃរតនៈ | សរណញ្ញាណ |
| មនុស្សចំណាស់ | ចាស់បញ្ញា | ទៅនិព្វាន |
| ឈប់ស្រែកឃ្លាន | រំលត់ទុក្ខ | សុខបរម ៕ |

ដោយ **ច.ស.ទ.**

# ពាក្យរំលឹក

បើយើងចេះរង្កៀសចំពោះអកុសលមូល និងអកុសលកម្ម យើងប្រាកដជាមិនចេះស្អប់បុគ្គលណាឡើយ ព្រោះក្នុងបុគ្គលម្នាក់ៗ កាលដែលប្រាសចាកអកុសលធម៌ទាំងនោះហើយ ក៏រមែងបានដល់នូវភាពជាបុគ្គលបរិសុទ្ធដ៏ក្រៃលែង មានអ្វីដែលគួរឲ្យយើងស្អប់នោះ ។

ក្រៅអំពីកុសលធម៌ជាទីពឹងហើយ យើងមិនគួរឲ្យសេចក្តីសំខាន់ទៅលើអ្វីៗសម្រាប់យើងពេកនោះទេ ព្រោះការព្រាត់ប្រាសចំពោះអ្វីនោះរមែងមានជាប្រាកដ ក្នុងពេលណា ថ្ងៃណាមួយជាមិនខាន ។

បើយើងមានពេលសម្រាប់គិតស្អប់អ្នកនេះ អ្នកនោះ យើងគួរតែយកពេលវេលានោះមកមើលថែខ្លួនឯងវិញ ឲ្យបានល្អឡើងចម្រើនដោយសេចក្តីសុខស្ងប់ មិនប្រសើរទេឬ ? ចំពោះការស្អប់អ្នកដទៃ ក្នុងរឿងនេះ រឿងនោះ ពិតជាឥតប្រយោជន៍មែន ទាំងដែល

ក្នុងរឿងនោះ សុទ្ធតែមានការពិតត្រឹមត្រូវដោយបរមត្ថមួយរយភាគរយទៀតផង ។

ពេលណាមួយនោះ យើងនឹងនៅសល់ត្រឹមតែការចងចាំរបស់អ្នកដទៃក្នុងលោកនេះប៉ុណ្ណោះ ព្រោះយើងត្រូវបានលះចាកលោកនេះទៅហើយ ដូច្នេះយើងគួរតែធ្វើអំពើល្អឲ្យបានច្រើន និងរក្សាឲ្យគង់វង្ស ដើម្បីឲ្យបានជាអារម្មណ៍ល្អនៃការចងចាំរបស់អ្នកដទៃនោះៗ ។

បើយើងប្រាថ្នាឲ្យអ្នកដទៃល្អមករកយើង នោះយើងរមែងមានការស្រឡាញ់ឬស្អប់ត្រឡប់ទៅរកអ្នកដទៃនោះៗវិញ គឺថា បើបានដូចចិត្តក៏ស្រឡាញ់ តែបើមិនបានដូចចិត្តដែលប្រាថ្នាទេ ក៏រមែងស្អប់...។ ដោយឡែកពីគ្នា គឺថា បើយើងប្រាថ្នាឲ្យអ្នកដទៃល្អ ដើម្បីអ្នកដទៃនោះឯងបានសុខ បានដល់នូវសេចក្ដីបរិសុទ្ធ នេះ គឺពិតជាមេត្តាព្រហ្មវិហារ ឬក៏ជាករុណាធម៌សុទ្ធៗ ។

ត្រូវប្រឹងប្រែងឲ្យបានខ្លួនឯងជាមនុស្សល្អ ព្រោះបើយើងជាមនុស្សល្អ យើងរមែងឃ្លាតចាកពីសភាវៈដែលមិនល្អ ទាំងមនុស្ស

ណាដែលមិនល្អក៏ចេញចាកពីជីវិតយើងទៅផងដែរ ប៉ុន្តែត្រូវប្រយ័ត្ន ឲ្យណាស់ កុំឲ្យខ្លួនឯងជាមនុស្សមិនល្អ ព្រោះបើយើងជាមនុស្សមិនល្អហើយ គឺយើងប្រាកដជាត្រូវឃ្លាតពីសភាវៈល្អ ទាំងឃ្លាតឆ្ងាយពីមនុស្សល្អ មិត្តភក្តិល្អ ដែលគួរឲ្យសង្វេគ ។

## ស្លឹកចេកប្រើហើយបោះចោល

មានរឿងទោមនស្សទាំងរអ៊ូរទាំថា ប្រើខ្ញុំដូចស្លឹកចេក ប្រើហើយបោះចោល...។ តាមពិត យើងគួរតែប្រើខ្លួនឯងក្នុងអត្តភាពនេះឲ្យដូចជាប្រើស្លឹកចេកអ៊ីចឹងដែរ ប្រើហើយលះបង់ចោល ប៉ុន្តែសូមឲ្យប្រើក្នុងការសន្សំបុណ្យ បំពេញបារមីទៅរកត្រើយគឺព្រះនិព្វាន ។

# ២.អដ្ឋកនាគរសូត្រ

ក្នុងពេលមួយ ដែលព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងវេឡុវ-គ្រាម ឋិតនៅទិសខាងត្បូងមិនឆ្ងាយពីក្រុងវេសាលីប៉ុន្មានឡើយ ក្នុងកាលនោះ ទសមគហបតី អ្នកនគរអដ្ឋកៈ បានមកថ្វាយបង្គំទូលសួរព្រះអានន្ទដ៏មានអាយុអំពីធម៌ឯក ដែលភិក្ខុអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់ផុតស្រឡះក៏បានផុតស្រឡះ អាសវធម៌ទាំងឡាយដែលមិនទាន់អស់ទៅ ក៏ដល់នូវការអស់ទៅផង ទាំងបានដល់នូវធម៌ក្សេមចាកយោគៈ ជាអនុត្តរធម៌ ដែលខ្លួនមិនធ្លាប់បានដល់ផង តើធម៌ឯកនោះ ព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសម្ដែង ហើយ មានដែរឬទេ ?

កាលដែលព្រះអានន្ទឆ្លើយប្រាប់ថាមានដូច្នេះហើយ ទសម-គហបតី បានទូលសួរថា តើដូចម្ដេចខ្លះ ។

ព្រះអានន្ទដ៏មានអាយុ បានលើកយកធម៌ ១១ យ៉ាង គឺ

រូបជ្ឈាន ៤ អប្បមញ្ញា ៤ និង អរូបជ្ឈាន ៣ មកប្រកាសរួមតែមួយ ក្នុងបដិបទាទៅកាន់ព្រះនិព្វាន ទើបធម៌ទាំង ១១ យ៉ាងនេះ ឈ្មោះថាជាធម៌ឯក ដោយអត្ថថា ធ្វើឲ្យកើតនូវអមតធម៌ ( **អមតុប្បត្តិយ-ត្ថេន ខោ សព្វានិបិ ឯកធម្មោតិ វត្តុំ វដ្ដតិ** ) ។

**សោ តត្ថ ឋិតោ** ដោយសេចក្ដីថា គហបតីនោះ តាំងនៅហើយក្នុងធម៌គឺសមថៈ និង វិបស្សនានោះ ។ ធម៌ទាំង ១១ ជាសមថៈ បុគ្គលនោះពិចារណាដឹងច្បាស់ដូច្នេះថា សមថៈនេះឯងអាត្មាអញបានតាក់តែងហើយ ( **អភិសង្ខតំ** ) បានបង្កើតហើយ ( **អភិសញ្ចេតយិតំ** ) ជាធម្មជាតិមិនទៀង តែងរលត់ទៅវិញជាធម្មតា បុគ្គលនោះ ក៏ឋិតនៅក្នុងធម៌នោះ ហើយក៏ដល់នូវការអស់ទៅនៃអាសវៈ បើមិនទាន់ដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់នឹងទៅកើតជាឱបបាតិកៈ ព្រោះការអស់ទៅនៃសញ្ញោជនធម៌ទាំង ៥ ប្រការ ជាចំណែកខាងក្រោម ដោយសេចក្ដីត្រេកអរក្នុងធម៌នោះ និងសេចក្ដីរីករាយក្នុងធម៌នោះ ( **ធម្មរាគេន ធម្មនន្ទិយា** ) ហើយនឹងបរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់មកអំពីព្រហ្មលោកនោះវិញឡើយ ។

បទថា **អភិសង្ខតំ** ប្រែថា ដែលបច្ច័យធ្វើហើយ ឲ្យកើតហើយ ។

បទថា **អភិសម្ភោគយិតំ** ដោយសេចក្តីថា បង្កឲ្យសម្រេចហើយ ។

ពីរបទថា **ធម្មរាគេន ធម្មនន្ទិយា** បានដល់ឆន្ទរាគៈក្នុងសមថៈ និងវិបស្សនា ។ ពិតណាស់ បុគ្គលដែលអាចលះបង់នូវឆន្ទរាគៈដោយប្រការទាំងពួង ទាំងឆន្ទរាគៈក្នុងសមថៈ និងវិបស្សនា រមែងជាព្រះអរហន្ត កាលបើមិនអាចទេ ក៏ជាព្រះអនាគាមី កើតក្នុងសុទ្ធាវាសព្រហ្ម ដោយចេតនាដែលសម្បយុត្តដោយចតុត្ថជ្ឈាន ( ឈានចតុក្កន័យ ) ព្រោះនៅលះបង់ឆន្ទរាគៈក្នុងសមថៈ និងវិបស្សនាមិនទាន់បាន ។

ទសមគហបតី សរសើរព្រះធម៌ទេសនា ដោយប្រៀបទៅនឹងបុរសកាលស្វែងរកកំណប់តែមួយ ស្រាប់តែបានកំណប់ ១១ ដោយព្យាយាមតែមួយពេល មានឧបមាយ៉ាងណាមិញ ខ្ញុំព្រះករុណាកាលស្វែងរកនូវទ្វារនៃព្រះនិព្វានតែមួយសោះ ស្រាប់តែបាននូវទ្វារនៃព្រះនិព្វាន ដល់ទៅ ១១ ដោយការស្តាប់ត្រឹមតែមួយពេលប៉ុណ្ណោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ម្យ៉ាងទៀត ដូចជាផ្ទះដែលមានទ្វារ ១១ កាលភ្លើងឆេះផ្ទះនោះហើយ ម្ចាស់ផ្ទះ អាចនឹងធ្វើខ្លួនឲ្យមានសួស្តីដោយទ្វារតែមួយៗក៏បាន មានឧបមាដូចម្តេចមិញ បពិត្រព្រះអានន្ទដ៏ចម្រើន បណ្តាទ្វារនៃព្រះនិព្វានទាំង ១១ នេះ ខ្ញុំ

ព្រះករុណានឹងអាចធ្វើខ្លួនឲ្យមានសួស្តី ដោយទ្វារនៃព្រះនិព្វានតែមួយៗបាន ក៏មានឧបមេយ្យដូច្នោះឯងដែរ ។

ទសមគហបតី បានថ្វាយទានដល់ភិក្ខុសង្ឃ ក្នុងក្រុង-បាតលិបុត្ត និងក្រុងវេសាលី ហើយបានបូជាចំពោះព្រះអានន្ទ ដោយសេចក្តីរីករាយជ្រះថ្លា ។

សូមអនុមោទនា !

# ពាក្យរំលឹកផ្សេងៗ

## កុំចោលបីយ៉ាង

កុំធ្វើរឿងអ្វីមិនមែនជាសិទ្ធិ កុំពោលប្រតិដ្ឋសាងរឿងមុសា
កុំគិតខ្វល់ចិត្តក្នុងរឿងធម្មតា កាយចិត្តវាចាកុំចោលឲ្យសោះ ។

ដោយ **ប.ស.ច.**

## មេត្តាភាវនា

គ្រប់គ្នាស្រឡាញ់សុខ ខ្លាចទុក្ខ ដូច្នេះមនុស្សយើងមិនគួរ

មានគំនិតត្រឹមតែថា ធ្វើអ្វីៗដើម្បីឲ្យខ្លួនឯងបានសុខប៉ុណ្ណឹងទេ គប្បីមានគំនិតបន្ថែមទៀតថា ធ្វើយ៉ាងណាដើម្បីឲ្យអ្នកដទៃបានសុខ រួចផុតចាកទុក្ខទៀតផង ។

## រៀនរស់នៅឲ្យសប្បាយចិត្ត

១- **រលឹកដល់អំពើល្អដែលយើងបានធ្វើ** ។ បើនឹកឃើញដល់អំពើមិនល្អ កុំបន្ទោសខ្លួនឯង ត្រូវយល់ដឹងថា វាជាវដ្តសង្សារ មិនមានអ្នកណាធ្វើកិលេសឲ្យខ្លួនឯងទេ យើងដឹងតែខំប្រឹងហែល អាស្រ័យបុណ្យកុសលជាក្បូនរកកោះរកត្រើយជាទីពឹង ក្នុងមង្គលសូត្រព្រះអង្គទ្រង់ត្រាស់សម្ដែងថា កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ជាមង្គលដ៏ឧត្ដម ។

២- **កុំចូលចិត្តរអ៊ូរទាំ** ។ វាជាការទាស់ចិត្តជាមួយនឹងសេចក្ដីពិត ហើយសម្ដែងចេញមកជាពាក្យសម្ដី ក្រៅអំពីធ្វើឲ្យអ្នកដទៃទទួលអារម្មណ៍មិនល្អហើយ វានៅធ្វើឲ្យខ្លួនយើងក្លាយជាអ្នកមានទម្លាប់រអ៊ូរទាំ ជាប់ឧបនិស្ស័យក្នុងចិត្តឥតប្រយោជន៍ ។ ការទាស់ចិត្តវាជាមេរមាស់ដោយពិត ប៉ុន្តែមិនត្រូវយកការរអ៊ូរទាំមកអេះ

ឬយកមកដោះស្រាយនោះឡើយ គឺត្រូវអាស្រ័យមេត្តាធម៌ និងបញ្ញាចូលឲ្យដល់ការពិតក្នុងរឿងនោះៗ ទើបអាចរំងាប់នូវការទាស់ចិត្តបាន ។

៣- **រៀនឲ្យកម្លាំងចិត្តដល់អ្នកដទៃ** ។ វាមិនមានអ្វីលំបាកនោះទេ បើយើងបានអប់រំនូវមេត្តាចិត្ត និងតាំងខ្លួនធ្វើជាកល្យាណមិត្តនៃអ្នកដទៃនោះៗ គឺអាចធ្វើបានងាយ ទាំងដែលជារបស់សំខាន់ណាស់ ជាអាយុជីវិតរស់នៅផង ជាអាយុជីវិតនៃការងារផង ព្រោះមនុស្សអស់កម្លាំងចិត្ត អាចសម្លាប់ខ្លួនបាន ។ យើងគួរតែរកឱកាសសរសើរលើកទឹកចិត្តអ្នកដទៃ ឲ្យត្រូវទៅតាមសេចក្ដីពិត និងសមគួរតាមកាលៈទេសៈ ( ដោយមិនត្រូវចេះតែបញ្ជោរខុសរឿងនោះទេ ) ព្រោះការសរសើរឲ្យកម្លាំងចិត្ត មិនមែនត្រឹមតែធ្វើឲ្យអ្នកដទៃមានសេចក្ដីសុខប៉ុណ្ណោះឡើយ នៅធ្វើឲ្យយើងឃើញសេចក្ដីសំខាន់នៃខ្លួនយើង ត្រង់ដែលមានសមត្ថភាពឲ្យសេចក្ដីសុខ សេចក្ដីចម្រើនកើនប្រយោជន៍ដល់អ្នកដទៃទៀតផងទុកដូចជាវត្ថុដ៏ស័ក្ដិសិទ្ធិមួយផងដែរ ។

៤- **ស្ដាប់ព្រះធម៌តាមអធ្យាស្រ័យ** ។ បានអានព្រះ-ត្រៃបិដកហើយ គប្បីកត់ទុកនូវចំណុចដែលយើងពីរោះ ជាពាក្យ

ដូចជាអុជប្រទីបក្នុងទីងងឹត មានខ្លឹមសារបើកផ្ទារ គឺកត់ទុកក្នុងសៀវភៅមួយ សម្រាប់អានដាស់តឿនចិត្តពេលក្រោយៗ ។

៥- **នឹកដល់អ្នកដែលលំបាកជាងយើង** ។ បាននៅរស់ហើយ គួរតែចេះស្កប់ស្កល់ មានមនុស្សច្រើនណាស់ដែលសុខចិត្តអស់ប្រាក់ច្រើនប៉ុនណាៗ ឲ្យតែបានជីវិតនៅរស់ ទីបំផុតបានបាត់បង់ជីវិតទៅហើយ ខ្លះទៀតកំពុងតែលំបាកព្រោះឈឺ ខ្លះលំបាកព្រោះក្ររហេមរហាម ខ្លះលំបាកព្រោះបញ្ហាក្រុមគ្រួសារ ។ល។ យើងគួរតែមានស្មារតីប្រើប្រាស់របស់ដែលនៅមាន ដូចជាភ្នែកត្រចៀក ជើងដៃ ពាក្យសម្ដីចិត្តគំនិតជាដើម ឲ្យកើតប្រយោជន៍ដល់ខ្លួនយើងផង ដល់អ្នកដទៃផង ទាន់ពេលដែលរបស់ទាំងអស់នេះនៅប្រើប្រាស់បាន ។ ត្រូវចេះគិតឲ្យយល់ថា ក្នុងលោកនេះ មិនមានអ្វីដែលសំខាន់សម្រាប់យើង ឲ្យដូចជាខ្លួនយើងជាមនុស្សល្អនោះឡើយ បើចេះគិតយល់ដូច្នេះ ទើបយើងមិនក្រវាយក្រវល់ច្រើនទៅរកការមានបានអ្វីៗ ក្រៅអំពីសន្សំបុណ្យនោះឯង ។

៦- **ចេះជួយអ្នកដទៃ** ។ មិនថារឿងងាយៗ រហូតដល់ទៅការងារជួយជីវិត សុទ្ធតែជាការងារឲ្យយើងសប្បាយចិត្តតាមក្រោយក្រៃលែងណាស់ ហើយជាបុណ្យកុសលធំដុំទៀតផង ។

ដូចជាការឲ្យទាន បើអ្នកទទួលក៏សប្បាយចិត្ត អ្នកឲ្យក៏បានសប្បាយចិត្តទាំងអស់គ្នា ដូច្នេះ តើយើងគួរឲ្យឱកាសដ៏ល្អបែបនេះកន្លងទៅទទេៗឬ ។ សីលក្តី អភយទានក្តី សុទ្ធតែជាការងារឲ្យខ្លួនឯងបានសុខទាំងអស់ ត្រូវចាំថា បើឲ្យអភ័យគេមិនបានទេ ក៏គួរគិតឲ្យអភ័យដល់ខ្លួនឯង ។

៧- **ចេះឲ្យពរអ្នកដទៃ** ។ ត្រូវតែជាវាចាចេញពីមេត្តាចិត្តពិតៗ កាលដែលមានមេត្តាចិត្តគិតឲ្យអ្នកដទៃបានសុខ មានសំណាងល្អ យើងក៏រលឹកដល់ហេតុនៃសេចក្តីសុខនោះៗ ហើយសាងសេចក្តីល្អឲ្យដល់ខ្លួនឯង មិនបៀតបៀនអ្នកដទៃដោយកាយឬដោយពាក្យសម្តីបញ្ឈឺចិត្តអ្វីៗឡើយ ។ បុគ្គលគួរបដិបត្តិក្នុងសេចក្តីនេះថា រក្សាខ្លួនឯងដោយខន្តី រក្សាអ្នកដទៃដោយមេត្តា ។

រក្សាខ្លួនឯងដោយខន្តី រក្សាអ្នកដទៃដោយមេត្តា
រក្សាស្រុកដីដោយសិក្សា រក្សាសាស្នាដោយបដិបត្តិ ។

៨- **បញ្ឈប់គំនិតដែលគិតខ្វល់** ។ តាមពិត គំនិតដែលគិតឲ្យបានសុខ មានដែរតើ ចេះតែគិតឲ្យកើតទុក្ខធ្វើអ្វី ។ ដូច្នេះ ដើម្បីឲ្យសម្បូណ៌គំនិតល្អៗ ចេះគិតឲ្យសុខស្ងប់ ត្រូវខំអានព្រះត្រៃ-បិដក និងខំស្តាប់ធម៌ ស្រង់យកចំណុចសំខាន់ៗមកគិតពិចារណា

ឲ្យយល់ មានសទ្ធា មានសីល និងមានបញ្ញាចម្រើនឡើង ។ កាល ណា បើយើងស្វែងរកជួបនូវខ្លឹមសារនៃជីវិតហើយ យើងនឹងបាន រស់នៅយ៉ាងរីករាយជាមួយនឹងសម្បត្តិខ្លឹមសារក្នុងជីវិត រីឯគំនិតគិត ខ្វល់ ជាទុក្ខក្នុងរឿងផ្សេងៗក៏រសាយទៅៗ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ សម្តែងថា អ្នកប្រាជ្ញរក្សាសេចក្តីមិនប្រមាទ ដូចជាគេរក្សានូវទ្រព្យដ៏ ប្រសើរ ។

៩- **ចេះគិតឲ្យតម្លៃនៃជីវិតខ្លួនឯង** ។ នេះមិនមែន ជាការលើកតម្កើងខ្លួនដោយមានះ ឬខំប្រឹងអួតខ្លួនឯងនោះទេ ព្រោះ ពាក្យថា តម្កល់ខ្លួនឲ្យប្រពៃក្តី ស្រឡាញ់ខ្លួនក្តី រក្សាខ្លួនក្តី ពឹងខ្លួន ឯងក្តី ឲ្យតម្លៃខ្លួនឯងក្តី ពាក្យថាខ្លួនក្នុងន័យទាំងអស់នេះ បានដល់ កុសលធម៌ជាលោកិយ និងលោកុត្តរដែលជារបស់ខ្លួនឯង មិនមែន ជាកុសលធម៌របស់អ្នកដទៃនោះឡើយ ។ បុគ្គលធ្វើអំពើអាក្រក់ ឈ្មោះថា មិនចេះឲ្យតម្លៃនៃជីវិតខ្លួនឯង មិនបានតម្កល់ខ្លួនឲ្យប្រពៃ ដូច្នេះពាក្យថា ចេះគិតឲ្យតម្លៃនៃជីវិតខ្លួនឯង គឺចេះគិតតម្កល់ខ្លួនឲ្យ ប្រពៃក្នុងសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា ក៏គឺជាគំនិតដែលគិត រៀបចំឲ្យរង្វាន់ដល់ខ្លួនឯង ឲ្យខ្លួនឯងរួចពីសភាពថោកទាប រួចពី ទុក្ខកង្វល់ បានដល់បរមសុខ ។

១០- **សេពគប់ជាមួយនឹងអ្នកអត់បញ្ហា** ។ គឺបាន សេចក្តីថា អ្នកណាដែលចេះជួយដោះស្រាយបញ្ហា ឲ្យយើង បានសុខស្ងប់ ឲ្យយើងមានបញ្ញា អ្នកនោះមិនដែលនាំរឿងខ្វាយខ្វល់ ចង្អៀតចង្អល់មកដល់យើង គឺនាំឲ្យតែយើងសប្បាយក្នុងផ្លូវព្រះធម៌ អ្នកនោះហើយដែលយើងគប្បីសេពគប់ ចំណែកបុគ្គលដែលមាន លក្ខណៈផ្ទុយអំពីនេះ ក៏គប្បីជ្រាបតាមសមគួរ ហើយបដិបត្តិឲ្យបាន សមរម្យសម្រាប់ប្រយោជន៍ទាំងអស់គ្នា ។

## ត្រូវចេះនៅជាមួយនឹងលោកនេះ

| | |
|---|---|
| នៅជាមួយនឹងខ្លួនឯង... | ឲ្យចេះស្ងប់ចិត្ត |
| នៅជាមួយនឹងញាតិមិត្ត... | ឲ្យមានមេត្តា |
| នៅជាមួយនឹងការពិត... | ឲ្យមានបញ្ញា |
| នៅជាមួយនឹងកិច្ចការ... | ឲ្យចេះរីករាយ ។ |
| នៅជាមួយនឹងសៀវភៅ... | ឲ្យចេះសិក្សា |
| នៅជាមួយនឹងបញ្ហា... | ឲ្យចេះដោះស្រាយ |
| នៅជាមួយនឹងព្រះធម៌... | ឲ្យចេះសប្បាយ |

នៅជាមួយនឹងចិត្តកាយ... ឲ្យមានកម្មដ្ឋាន ។
នៅជាមួយនឹងម៉ែឪ... ឲ្យមានកតញ្ញូ
នៅជាមួយនឹងអាចារ្យគ្រូ... ឲ្យចេះតាមដាន
នៅជាមួយនឹងបណ្ឌិត... ឲ្យចេះជិតប្រាណ
នៅជាមួយនឹងមិត្តកល្យាណ... ឲ្យចេះរក្សា ។
នៅជាមួយនឹងអ្នកធំ... ឲ្យចេះកោតក្រែង
នៅជាមួយនឹងគ្នាឯង... ឲ្យចេះករុណា
នៅជាមួយនឹងបញ្ចក្ខន្ធ... ឲ្យចេះវិបស្សនា
នៅជាមួយនឹងសង្ខារ... ឲ្យចេះលះបង់ ៕

ដោយ **ប.ស.ទ.**

## កុំតែកើតទុក្ខទៅបានសុខហើយ

មនុស្សយើង ប្រើប្រាស់ពេលវេលាមួយជីវិត ដើម្បីស្វែងរកសេចក្តីសុខ ដោយមិនបានដឹងថា ត្រឹមតែការមិនកើតទុក្ខប៉ុណ្ណោះ សេចក្តីសុខក៏នៅនឹងមុខស្រេចទៅហើយ ចូរពិចារណាតាមកំណាព្យខាងក្រោមនេះ ។

សឹងមួយជីវិតគិតរកសុខ ធម៌នៅនឹងមុខមិនគិតអាន
តាមពិតលះទុក្ខបានប៉ុន្មាន ក្តីសុខក្សេមក្សាន្តបានប៉ុណ្ណោះ។
ទុក្ខសច្ចដាច់មុខលើតណ្ហា កើតទុក្ខពេលណាវិចារណ៍ចុះ
ព្រោះតែចំណង់ក្នុងស្រីប្រុស ខ្វល់ចិត្តដូចព្យុះលុះមរណា ។
បរមសុខមិនមែនជាលោកីយ៍ ប៉ុន្តែផុតភ័យពីលោកា
ព្រោះបានកម្ចាត់នូវតណ្ហា និរោធសច្ចប្រែថារលត់ទុក្ខ ៕

ដោយ **ម.ស.ទ.**

# របស់ល្អមិនចុះថោក

របស់ល្អពិតប្រាកដ មានតម្លៃថ្លៃមិនចុះថោកយ៉ាងណា មនុស្សល្អមានគុណធម៌ ជាមនុស្សមានតម្លៃ រមែងមិនធ្វើអ្វីឲ្យចុះតម្លៃខ្លួនឯងឡើយ ក៏យ៉ាងនោះដែរ ។

# ៣.សេក្ខប្បដិបទាសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលវត្ថុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ពួកសក្យៈអ្នកក្រុងកបិលវត្ថុ បានកសាងនូវសណ្ឋាគារថ្មី មិនទាន់មានមនុស្សណាចូលទៅអាស្រ័យឡើយ ។ សណ្ឋាគារនេះ គឺជាសាលាដ៏ធំសម្រាប់ប្រជុំគ្នាធ្វើការ វិចិត្ររចនាយ៉ាងស្អាត ហាក់ដូចជាវិមានទេវតា ទាំងពួកទេវតាក៏បានអាស្រ័យនៅហើយស្រេចដែរ ។

ពួកសក្យៈអ្នកក្រុងកបិលវត្ថុ បានអារាធនាព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឃឲ្យទ្រង់ប្រើប្រាស់ជាមុន សឹមពួកសក្យៈប្រើប្រាស់តាមក្រោយ ដូច្នេះរមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងដើម្បីសេចក្ដីសុខអស់កាលជាយូរអង្វែងដល់ពួកសក្យៈនោះឯង ។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ព្រមទាំងភិក្ខុសង្ឃ ទ្រង់និមន្តចូលទៅកាន់សណ្ឋាគារសាលា លុះចូលទៅដល់ហើយ ទ្រង់ឲ្យលាងព្រះបាទា រួចទើបយាងចូលទៅគង់ប្រថាប់ត្រង់សសរកណ្ដាល បែរព្រះភក្ត្រទៅទិសខាងកើត ឯភិក្ខុសង្ឃ

គង់ខាងក្រោយព្រះពុទ្ធអង្គហ្នឹងឯង ចំណែកពួកសក្យៈនាំគ្នាអង្គុយផ្នែកខាងកើត បែរមុខមកខាងលិចឆ្ពោះព្រះដ៏មានបុណ្យ និងភិក្ខុសង្ឃ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់បានពន្យល់ណែនាំពួកសក្យៈអ្នកក្រុងកបិលវត្ថុ ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យអាចហ៊ានឲ្យរីករាយ ដោយធម្មីកថាក្នុងវេលារាត្រីនោះ អស់ជិតបីយាម ញ៉ាំងពួកសក្យៈអ្នកក្រុងកបិលវត្ថុឲ្យរីករាយដោយធម្មីកថានោះ ប្រៀបដូចជាព្រះអង្គទ្រង់នាំឲ្យហោះទៅក្នុងអាកាសវេហា ឆ្លងមហាសមុទ្រ និងឲ្យសេពសោយនូវរសទឹកឃ្មុំដូច្នោះឯង គឺថាមហាបពិត្រ ការថ្វាយសេនាសនៈ ជាមហាទាន សណ្ឋាគារសាលារបស់មហាបពិត្រនេះតថាគតក៏បានប្រើប្រាស់ហើយ ភិក្ខុសង្ឃក៏បានប្រើប្រាស់ហើយដូច្នេះ សេនាសនៈឯណា ដែលតថាគតនិងភិក្ខុសង្ឃបានប្រើប្រាស់ហើយ សេនាសនៈនោះគឺព្រះធម្មរតនៈបានប្រើប្រាស់ហើយផងដែរពោលគឺព្រះរតនៈទាំងបីបានប្រើប្រាស់ហើយ ។ កាលដែលពួកមហាបពិត្រ បានថ្វាយនូវអាវាសជាទានដូច្នេះ ទានទាំងពួងក៏ឈ្មោះថាបានថ្វាយហើយដូចគ្នាដែរ អ្នកណាៗ ក៏មិនអាចកំណត់នូវអានិសង្សនៃសេនាសនទាននេះបានឡើយ ។ វិហារ រមែងការពារនូវក្ដៅត្រជាក់ សត្វកាចទាំងឡាយ ពស់តូច ពស់ធំ សម្ផស្សរបោមមូស

ខ្យល់ភ្លៀង និងទឹកសន្សើមក្នុងរដូវត្រជាក់ខ្លាំង ។ ការថ្វាយវិហារដល់សង្ឃដើម្បីជ្រកនៅ ដើម្បីសេចក្តីសុខ ដើម្បីអភិរមសំងំនៅដោយព្រះកម្មដ្ឋាន ព្រះពុទ្ធទាំងឡាយ ទ្រង់សរសើរថាជាអគ្គទាន ព្រោះហេតុដូច្នោះ បុគ្គលដែលជាបណ្ឌិត កាលដែលបានពិចារណាឃើញសេចក្តីសុខរបស់ខ្លួន គប្បីសាងវិហារដ៏ជាទីរីករាយឲ្យដល់ពួកភិក្ខុជាពហុស្សូតបានអាស្រ័យនៅ ។ ម្យ៉ាងទៀត គប្បីថ្វាយបាយទឹក ចីវរ និងសេនាសនៈផ្សេងទៀតដោយចិត្តជ្រះថ្លាដល់ភិក្ខុទាំងនោះ ដែលជាអ្នកបដិបត្តិដោយត្រង់ ចេះដឹងក្នុងធម្មវិន័យ ជាព្រះខីណាស្រពរំលត់កិលេសអស់អាសវៈ ទាំងដែលភិក្ខុជាពហុស្សូតទាំងនោះ បានសម្តែងធម៌ជាគ្រឿងកម្ចាត់បង់នូវទុក្ខទាំងពួង ជាបដិការទៀតផង ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវធម្មីកថាដ៏ច្រើន មានន័យជាអនេកប្បការ ទើបព្រះអង្គទ្រង់ត្រាស់ទៅនឹងព្រះអានន្ទដ៏មាន-អាយុថា ម្នាលអានន្ទ ចូរអ្នកសម្តែងនូវសេក្ខប្បដិបទា ដល់ពួកសក្យៈអ្នកក្រុងកបិលវត្ថុចុះ ដ្បិតតថាគតរួយខ្នងណាស់ តថាគតនឹងសម្រាកខ្នងបន្តិច ។

ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់មានព្រះពុទ្ធបំណង ដើម្បីឲ្យព្រះអានន្ទសម្តែងព្រះធម៌ ទើបត្រាស់ថា ម្នាលអានន្ទ អ្នកចូរសម្តែងនូវសេក្ខប្បដិបទា... ។ សួរថា កាលបើព្រះអសីតិមហាសាវ័ក ដូច

ជាព្រះអគ្គសាវ័កទាំងពីរ និងព្រះមហាកស្សបត្ថេរជាដើម គង់នៅដែរនោះ ហេតុអ្វីបានជាព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ប្រគល់នូវភារៈសម្ដែងធម៌នេះឲ្យដល់ព្រះអានន្ទត្ថេរដូច្នេះ ? ឆ្លើយថា ព្រោះអំណាចនៃអធ្យាស្រ័យនៃបរិស័ទ ។ ពិតណាស់ ព្រះអានន្ទត្ថេរ មានកេរ្តិ៍ឈ្មោះប្រាកដដល់ពួកសក្យៈថា ជាកំពូលលើភិក្ខុទាំងឡាយ ផ្នែកខាងពហុស្សូត ទាំងសម្ដែងធម៌ពីរោះដោយបទព្យញ្ជនៈ ពីរោះទាំងសំឡេង ទាំងជាព្រះញាតិដ៏ប្រសើររបស់ពួកយើងផង ពួកយើងមានបំណងនឹងស្ដាប់ព្រះអានន្ទត្ថេរ សម្ដែងព្រះធម៌បន្ទាប់អំពីព្រះដ៏មាន-ព្រះភាគ ដោយប្រការដូច្នេះឯង ។

ព្រោះហេតុអ្វី បានជាព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់កំណត់នូវ **សេក្ខប្បដិបទា** ឲ្យដល់ព្រះអានន្ទត្ថេរសម្ដែងដូច្នេះ ? ព្រោះហេតុច្រើនយ៉ាង ៖

ព្រោះបរិស័ទក្នុងពួកសក្យៈ ប្រាថ្នានូវមង្គលសិរីសួស្ដី សេចក្ដីចម្រើន ក្នុងការឡើងសណ្ឋាគារសាលាថ្មីនេះ ចំណែកសេក្ខប្បដិបទាជាមង្គលប្បដិបទា គឺជាបដិបទារបស់បុគ្គលដែលមានសេចក្ដីចម្រើននៅក្នុងព្រះពុទ្ធសាសនា ។

ព្រោះក្នុងពួកសក្យៈនោះ មានបរិស័ទច្រើនទៅដោយព្រះសេក្ខបុគ្គល ដូច្នេះសេក្ខប្បដិបទាសូត្រនេះឋិតនៅក្នុងឋានៈដែល

បរិស័ទអ្នកស្តាប់ចាក់ធ្លុះដោយខ្លួនឯង ទើបមិនលំបាកក្នុងការកំណត់ដឹងធម៌ ។

ព្រោះព្រះអានន្ទត្ថេរ បានសម្រេចនូវសេក្ខប្បដិសម្ភិទា ( បដិសម្ភិទារបស់ព្រះសេក្ខបុគ្គល ) ម៉្លោះហើយ ការសម្តែងធម៌បិតនៅក្នុងឋានៈដែលចាក់ធ្លុះដោយអង្គឯងហើយ ក៏មិនលំបាកក្នុងការសម្តែងឲ្យអ្នកស្តាប់យល់នោះឡើយ ។

ព្រោះសិក្ខាទាំងបី ( ត្រៃសិក្ខា = សីល សមាធិ បញ្ញា ) ក៏រួមនៅក្នុងសេក្ខប្បដិបទានេះឯង ក្នុងសិក្ខាទាំងបីនោះ កាលដែលព្រះ-អានន្ទត្ថេរសម្តែងអំពីអធិសីលសិក្ខា ក៏ជាការសម្តែងនូវវិន័យបិដកទាំងអស់ហ្នឹងឯង កាលដែលសម្តែងអំពីអធិចិត្តសិក្ខា ក៏ជាការសម្តែងនូវសុត្តន្តបិដកទាំងអស់ និងកាលសម្តែងនូវអធិប្បញ្ញាសិក្ខា ក៏ជាការសម្តែងនូវអភិធម្មបិដកទាំងអស់ហ្នឹងដែរ ។ ព្រះអានន្ទត្ថេរ ជាពហុស្សូតទ្រទ្រង់នូវព្រះត្រៃបិដក អាចសម្តែងនូវសិក្ខាទាំងបីដោយបិដកទាំងបីបាន កាលបើដូច្នេះ សេក្ខប្បដិបទាសូត្រនេះ ក៏សម្រេចបានជាមង្គល មានសិរីសួស្តីសេចក្តីចម្រើនដល់ពួកសក្យៈអ្នកក្រុងកបិលវត្ថុ ដោយប្រការដូច្នេះឯង ។

ក្នុងរឿងដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីការចុករួយនូវព្រះប្រឹស្នាង្គ ( ខ្នងរបស់ព្រះអង្គ បាលីថា បិដ្ឋិ ) គ្រាន់តែជាហេតុ

បន្តិចបន្តួចប៉ុណ្ណោះ ព្រោះព្រះអង្គអាចគ្របសង្កត់នូវទុក្ខវេទនា ហើយគង់ប្រថាប់អង្គុយអស់មួយសប្តាហ៍ ឬពីរសប្តាហ៍ក៏បាន តែក្នុងរឿងនេះ ព្រោះអធ្យាស្រ័យនៃពួកសក្យៈ បានរៀបបន្ទប់ដ៏ស្អាតប្រណីតមួយរួចជាស្រេច ចងពិដានប្រដាប់ដោយផ្កាយមាស ភួងផ្កាក្រអូបនៅពីខាងលើ អុជប្រទីបប្រេងក្រអូប ដោយគិតថាធ្វើដូចម្តេចហ្ន៎ ! ព្រះសាស្តាទ្រង់ក្រោកឡើងចាកធម្មាសនៈ ហើយបានយាងមកសម្រាកបន្តិច ទ្រង់ព្រះបន្ទំក្នុងទីនេះ កាលបើដូច្នេះ សណ្ឋាគារនេះគឺព្រះបរមសាស្តា ទ្រង់បានប្រើប្រាស់ដោយព្រះឥរិយាបថ៤ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកយើង អស់កាលយូរអង្វែង ។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបអធ្យាស្រ័យនៃពួកសក្យៈ ដើម្បីអនុគ្រោះដល់ពួកព្រះញាតិ ទើបទ្រង់ក្រាលសង្ឃាដីជា៤ជាន់ ហើយសម្រេចនូវសីហសេយ្យាសន៍ផ្អៀងខាងស្តាំ គងព្រះបាទ ដោយព្រះបាទ មានសតិនិងសម្បជញ្ញៈកំណត់ទុកក្នុងព្រះ-ហឫទ័យ នូវឧដ្ឋានសញ្ញាគឺសេចក្តីសម្គាល់ថា នឹងក្រោកឡើងវិញក្នុងពេលវេលាថ្មើរណោះ ។

ក្នុងទីនោះ ព្រះសក្យមហានាម ជាព្រះប្រធានដ៏ខ្ពង់ខ្ពស់ចំពោះបរិស័ទ កាលដែលព្រះអនន្ទត្ថេរសង្គ្រោះដល់ព្រះមហានាមនោះហើយ ក៏ជាការសង្គ្រោះដល់បរិស័ទដទៃផងដែរ ទើប

ព្រះអានន្ទត្ថេរ មានព្រះថេរដីកាហៅចំពោះតែព្រះសក្យមហានាម មួយព្រះអង្គនោះឯង ដូចក្នុងការចាប់ផ្តើមនៃមាតិកាធម៌ ព្រះអានន្ទ-ត្ថេរបានសម្តែងថា

បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសីល ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកស្គាល់ប្រមាណក្នុងភោជន ជាអ្នកប្រកបនូវការភ្ញាក់រលឹក ជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង៧ប្រការ និងជាអ្នកបានដូចប្រាថ្នានូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាហេតុនៃកិរិយានៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយ ។

បន្ទាប់អំពីសេចក្តីអធិប្បាយក្នុងធម៌មួយៗ គ្រប់ចរណៈទាំង ១៥ ចប់ហើយ ព្រះដ៏មានព្រះភាគ ទ្រង់យាងក្រោកឡើងហើយត្រាស់នឹងព្រះអានន្ទត្ថេរថា ម្នាលអានន្ទ ពីរោះណាស់ៗ ម្នាលអានន្ទ អ្នកសម្តែងសេក្ខប្បដិបទា ដល់ពួកសក្យៈ អ្នកក្រុងកបិលវត្ថុពេញហៅពីរោះពិតមែន ។ ព្រះដ៏មានព្រះភាគ ទ្រង់ពុំបានផ្ទំលក់ឡើយ គឺទ្រង់ព្រះសណ្តាប់ព្រះសូត្រនេះតាំងអំពីដើម រហូតដល់ព្រះអានន្ទចាប់យកកំពូលនៃសេក្ខប្បដិបទា គឺវិជ្ជាបីមកប្រកាសសម្តែង ទើបព្រះអង្គទ្រង់ស្តេចយាងក្រោកឡើងប្រថាប់គង់អង្គុយសមាធិ ហើយបានប្រទាននូវសាធុការរ៉ាប់រងព្រះធម៌ ដូច្នេះព្រះសូត្រ

នេះ ដោយព្រះវាចានៃព្រះពុទ្ធអង្គត្រឹមតែប៉ុណ្ណោះ ទើបឈ្មោះថាជាភាសិតរបស់ព្រះដ៏មានព្រះភាគ ដោយប្រការដូច្នេះឯង ។

សូមអនុមោទនា !

## ពាក្យរំលឹកផ្សេងៗ

នៅពេលដែលយើងជួបអ្វី បានអ្វី ត្រូវនឹករលឹកឲ្យរឿយៗថា អ្វីៗគ្រប់យ៉ាងសុទ្ធតែមានអាយុក្ខ័យគឺការអស់អាយុហ្នឹងឯង ដូច្នេះ សេចក្តីសំខាន់គឺនៅត្រង់ការដែលយើងចេះមើលថែគ្នា ធ្វើល្អដោយការសង្គ្រោះគ្នា និងចាត់ចែងប្រើប្រាស់អ្វីៗឲ្យបានសម្រេចជាប្រយោជន៍ ទាន់ពេលវេលា ។

យើងមិនអាចធ្វើល្អហើយ មានការគាប់ចិត្តដល់មនុស្សគ្រប់គ្នាបានឡើយ ព្រោះអ្នកដែលគេមិនចូលចិត្តយើង គេតែងទាស់ចិត្ត និងពោលបង្អាប់យើងជានិច្ច ទោះជាយើងខំធ្វើល្អបានយ៉ាងណាក៏ដោយ គឺក្នុងលោកនេះ មានអ្នកដែលត្រេកអរក្នុងការធ្វើខ្លួនឯងឲ្យជាសត្រូវនឹងអ្នកដទៃ ជាមនុស្សច្រើនដោយអំនួតអួតអាង ។ ដូច្នេះ ការងារណាឲ្យតែគាប់គួរនឹងសតិសម្បជញ្ញៈខ្លួនឯង ព្រមទាំងត្រឹម-

ត្រូវតាមធម៌របស់សប្បុរសផងនោះ យើងគប្បីធ្វើការងារនោះឲ្យបាន ល្អជាទីបំផុតទៅ ចំណែកអ្នកណាដែលមើលមកថាមិនល្អទេនោះ យើងត្រូវឲ្យអភ័យ ហើយលែងគេចោលទៅ ពោលគឺកុំយកចិត្ត ទុកដាក់គិតឲ្យកើតទុក្ខកង្វល់ ក្តៅក្រហាយ ខូចខាតនូវកុសលធម៌ របស់ខ្លួនឯងនោះឡើយ ។

ពាក្យថា សូន្យទទេ ក្នុងលោកបុថុជ្ជនបានសេចក្តីថា អត់ មានបានអ្វីទាំងអស់ គឺជារឿងខ្វះខាត សោកស្តាយ... ប៉ុន្តែក្នុងភាសា ធម៌ ឬក្នុងអរិយវិន័យវិញពាក្យថា សូន្យទទេ នេះ គឺអ្វីៗមានគ្រប់ យ៉ាង ត្រឹមត្រូវតាមហេតុ មិនលើស មិនខ្វះ គ្រាន់តែមិនមានម្ចាស់ និងប្រាសចាកការប្រកាន់ប៉ុណ្ណោះឯង ។ កាលបើមិនមានសេចក្តី ប្រកាន់ ឲ្យយ៉ាងនេះវិញ ឬឲ្យយ៉ាងនោះវិញដូច្នេះហើយ ចិត្តក៏រមែង ស្ងប់ គឺស្ងប់នូវទុក្ខកង្វល់ ស្ងប់ការខកចិត្ត ។ ចិត្តស្ងប់របស់ព្រះ-ខីណាស្រព គឺជាចិត្តទំនេរមិនមានសកម្មភាពជាអភិសង្ខារឡើយ ។ ត្រង់ដែលកម្មភពនិងឧបបត្តិភពមិនមាន គឺជាព្រះនិព្វាន។

គ្រប់គ្នាមានទុក្ខ ព្រោះមានបញ្ចក្ខន្ធ ប៉ុន្តែបើបានសិក្សា មាន

បញ្ញាដឹងនូវបញ្ចក្ខន្ធតាមសេចក្តីពិត នោះជីវិតពិតជារស់នៅយ៉ាងសប្បាយ ។ មនុស្សយើង មានទុក្ខតាមផ្លូវចិត្ត សុទ្ធតែមកអំពីសេចក្តីប្រាថ្នាអ្វីៗដោយតណ្ហាទាំងអស់ តណ្ហាកើតមានព្រោះហេតុដែលមិនដឹងនូវបញ្ចក្ខន្ធហ្នឹងឯង គឺថាកាលបើមិនដឹងដោយអវិជ្ជាហើយ ក៏រមែងប្រកាន់នូវបញ្ចក្ខន្ធថាជាយើង ថាជាខ្លួនយើង ទើបត្រូវការប្រាថ្នាអ្វីៗគ្រប់យ៉ាងឲ្យខ្លួនឯង ដែលជាតួខ្វះខាតរហេមរហាមសព្វគ្រប់នោះៗ ម្ល៉ោះហើយ លទ្ធផលជាក់ស្តែង គឺទុក្ខសោក ចង្អៀត-ចង្អល់ផ្លូវចិត្ត ។ ដែលថា ជីវិតពិតជារស់នៅយ៉ាងសប្បាយ ព្រោះមិនមានតួខ្វះខាតរហេមរហាមនោះឯង នេះឈ្មោះថា សប្បាយ-បដិបទា ជាបដិបទាទៅកាន់ព្រះនិព្វាន ។

ក្នុងរឿងមួយ មនុស្សល្ងង់ដេកកើតទុក្ខអស់កម្លាំងចិត្ត មិនចេះកែខៃធ្វើឲ្យចិត្តរឹងប៉ឹងមានកម្លាំងវិញឡើយ ចំណែកមនុស្សឆ្លាតចេះជួយខ្លួនឯងឲ្យរួចពីបាប ទាំងចេះសាងកម្លាំងឲ្យចិត្តប្រព្រឹត្តទៅក្នុងកុសលធម៌ផ្សេងៗបានទៀតផង ។

មកពីរបស់ល្អ ទើបយើងពេញចិត្ត ឬមកអំពីការពេញចិត្តទើបមានរបស់ល្អ ? បើរបស់នោះពិតជាល្អដោយខ្លួនឯងមែន ហេតុ

ដូចម្តេចបានជាអ្នកដទៃ មានការទាស់ចិត្តទាំងស្អប់ទៀតផងយ៉ាង នេះ ? ចំណែកវិបស្សនាថ្នាក់និព្វិទាញាណ រមែងនឿយណាយចំពោះ សង្ខាររលោក ហើយបង្អោនទៅត្រេកអរចំពោះព្រះនិព្វានវិញ ។ ដូច្នេះ កាលបើយើងបានរកឃើញថា របស់ល្អគឺមកអំពីយើងពេញ ចិត្តពិតហើយ យើងគប្បីអប់រំចិត្តឲ្យមានសន្តោសចំពោះ បច្ច័យ៤ បែបនេះ យើងនឹងបានរស់នៅដោយសប្បាយជាមួយនឹងរបស់ដែល យើងមាន ទាំងត្រេកអរចំពោះព្រះនិព្វានដែលមិនមាននូវបញ្ចក្ខន្ធ ទៀតផង ។

មនុស្សយើងជួបគ្នា តាមឧបនិស្ស័យដែលធ្លាប់មានជាមួយគ្នា មក ឯការដែលបានស្គាល់គ្នានិងរាប់អានគ្នា ទៅតាមការតាំងចិត្តផ្សំ ថែមទៀត ចំណែកការបែកចាកគ្នាទៅវិញនោះ វាជារឿងធម្មតានៃ ការជួប មិនចាំបាច់បន្ទោសហេតុក្នុងបច្ចុប្បន្ន ថាមកពីហេតុអ្វីនោះ ឡើយ ។ អ្នកចាស់កន្លងទៅ អ្នកថ្មីមកដល់ កុំភ្លេច ស្រឡាញ់និង មើលថែខ្លួនឯង ព្រោះមិនមានអ្នកណាមកហើយមិនទៅនោះទេ ទី បំផុតយើងត្រូវរស់នៅជាមួយនឹងខ្លួនឯងជាមនុស្សល្អ ជាអ្នកមាន បុណ្យបានធ្វើទុកហើយ ទើបបាននូវទីពឹងពិតប្រាកដ ។

គ្រប់គ្នាប្រាថ្នាសេចក្តីសុខ ត្រូវតែសិក្សាអំពីហេតុនៃសេចក្តីសុខនោះៗ ជឿទុកចិត្តលើសេចក្តីល្អថាពិតជាហេតុនៃសេចក្តីសុខមែន ទាំងសុខក្នុងបច្ចុប្បន្នទាំងសុខក្នុងបរលោក ទាំងជាឧបនិស្ស័យនៃលោកុត្តរធម៌ទៀតផង ដាច់ខាតកុំជឿកិលេសនាំឲ្យប្រព្រឹត្តបាបកម្មផ្សេងៗឡើយ ។

កុំមិនហ៊ានធ្វើអាក្រក់ ព្រោះដោយសារខ្លាចគេដឹង ត្រឹមតែប៉ុណ្ណឹងនោះ គឺត្រូវអប់រំសេចក្តីថ្លៃថ្នូរ ឲ្យចេះខ្ពើមបាបពិតៗ ឃើញការវៀរចាកបាបបានជាជ័យជម្នះ មានអានិសង្សឲ្យយើងបានរស់នៅជាមួយនឹងសេចក្តីល្អក្នុងបច្ចុប្បន្ន ដែលគួរឲ្យសប្បាយចិត្តពិតៗ ។

យើងបានដឹងរឿងក្នុងលោកនេះដូច្នេះថា ផែនដីវិលជុំវិញខ្លួនឯង ហើយវិលជុំវិញព្រះអាទិត្យទៀត នេះគ្រាន់តែលើកយកមកជាបទសិក្សា គឺឲ្យយើងចេះពិចារណាខ្លួនដោយខ្លួនឯង ចេះស្រឡាញ់ខ្លួនឲ្យបានល្អដូចជាផែនដីវិលជុំវិញខ្លួនឯងអ៊ីចឹង ជាមួយគ្នានឹងការចេះស្រឡាញ់អ្នកដទៃ រក្សាអ្នកដទៃ ដូចជាផែនដីវិលជុំវិញព្រះ-អាទិត្យដូច្នោះឯង ។ ត្រូវចងចាំនិងយល់ឲ្យច្បាស់ថា ក្នុងលោកនេះមិនមានអ្វីដែលសំខាន់សម្រាប់យើង ឲ្យដូចជាយើងដែលជាមនុស្ស

ល្អនេះទេ បើយើងអស់ល្អក្នុងខ្លួនឯងហើយ មិនមានអ្វីក្នុងលោកនេះមកជំនួសបានឡើយ ។

កុំធ្វើសេចក្ដីល្អ ដោយគ្រាន់តែចង់ឲ្យគេដឹងប៉ុណ្ណឹងនោះ គឺត្រូវសិក្សាឲ្យស្គាល់សេចក្ដីល្អពិតប្រាកដ សេចក្ដីល្អជាកល្យាណធម៌ដូចជាកល្យាណមិត្ត ដែលតែងតែជួយទំនុកបម្រុងនិងថែរក្សា ឲ្យយើងបានជួបប្រសព្វតែនឹងសេចក្ដីសុខ សេចក្ដីចម្រើន ឆ្លាតឈ្លាសវាងវៃ សមជាមនុស្សដែលខ្លួនឯងគួរគោរព គាប់គួរនឹងសតិ-សម្បជញ្ញៈរបស់ខ្លួន ទាំងស័ក្ដិសមធ្វើជាកូនរបស់ព្រះសម្មាសម្ពុទ្ធពិតៗទៀតផង ។

យើងមិនមែនជាព្រះអរហន្ត តែក៏អាចសិក្សាអំពីព្រះអរហន្តបានដែរ ទាំងដែលយើងមិនអាចដឹងគុណធម៌ដ៏ខ្ពង់ខ្ពស់របស់ព្រះ-អរហន្ត តែក៏អាចសិក្សាស្ដាប់យល់បានថា ព្រះអរហន្តមិនមានកើតទុក្ខផ្លូវចិត្តជាពិតប្រាកដ ។ ការសិក្សាយល់បានដូច្នេះ នាំឲ្យយើងបានដឹងច្បាស់អំពីចិត្តខ្លួនយើងហ្នឹងឯងជាតួកើតទុក្ខ ព្រោះតែកិលេសក្នុងចិត្តខ្លួនឯង ប្រសិនបើមានអ្នកដទៃសាងសេចក្ដីទុក្ខឲ្យម៉្លេះសមគេស្អប់ព្រះអរហន្ត គេក៏អាចសាងទុក្ខឲ្យព្រះអរហន្តអង្គ

នោះៗកើតទុក្ខផ្លូវចិត្តបានដែរ ។ កាលបើយើងយល់ច្បាស់ហើយ គប្បីមានស្មារតីរក្សាចិត្តខ្លួនឯងឲ្យបានល្អ មិនមែនព្រោះបានសម្បត្តិអ្វីៗក្នុងលោក ហើយក៏មិនមែនជាការទៅឈ្នះព្រោះចង់ឈ្នះអ្នកដទៃនោះទេ ការមិនកើតទុក្ខព្រោះឈ្នះកិលេសក្នុងចិត្តខ្លួនឯងតែប៉ុណ្ណោះ ហើយការដែលមិនកើតទុក្ខនេះឯងដែលជាបរមសុខ គឺព្រះនិព្វានទៀតផង ។

រឿងរ៉ាវពេញពិភពលោក កង្វល់មានក្នុងចិត្តមនុស្សម្នាក់ៗរៀងៗខ្លួន ប៉ុន្តែ ទាំងរឿងរ៉ាវនោះៗ ពេញភូមិស្រុក ពេញទាំងពិភពលោក ចំណែកចិត្តស្ងប់ គឺមិនមានកង្វល់អ្វីឡើយ មានតែភាពទំនេរក្នុងចិត្តប៉ុណ្ណោះ ។ ភាពទំនេរក្នុងចិត្ត មិនមែនបានសេចក្តីថាមិនធ្វើការងារជាប្រយោជន៍ដល់អ្នកដទៃនោះទេ មានតែប្រយោជន៍សំខាន់ៗទៀតផង ព្រោះជាប្រយោជន៍ដែលសម្រេចបានមកអំពីចិត្តស្ងប់របស់សប្បុរស ។

# ៤. ពោតលិយសូត្រ

សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅអាបណនិគម ( និគមដែលសម្បូណ៌ផ្សារលក់ដូរ ) នៃពួកជនអង្គុត្តរាបៈ ក្នុងអង្គុត្ត-រាបជនបទ ( និគមនោះ នៅជិតទន្លេមហី ដែលបត់ទៅទិសខាងជើង ) ។ នៅពេលដែលព្រះអង្គទ្រង់បំពេញពុទ្ធកិច្ច បិណ្ឌបាតប្រោសសត្វ ព្រមដោយភិក្ខុសង្ឃហើយ និងក្រោយអំពីភត្តកិច្ច ទ្រង់បានបញ្ជូនភិក្ខុសង្ឃទៅកាន់ទីរៀងៗអង្គ ព្រះដ៏មានព្រះភាគតែមួយព្រះអង្គឯងបានយាងចូលក្រោមម្លប់មហាវ័ន គង់ប្រថាប់នៅនាមាត់ទន្លេមហី មិនឆ្ងាយអំពីនិគមនោះឡើយ ។

សម័យនោះ ពោតលិយគហបតីស្លៀកដណ្តប់សំពត់សមគួរ ប្រដាប់ឆត្រនិងស្បែកជើង ដើរត្រាច់ទៅរឿយៗដើម្បីសម្រួលស្មុង ហើយក៏ដើរសំដៅទៅកាន់ដងព្រៃដែលព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅ ទាំងបានចូលទៅរកព្រះអង្គ ធ្វើនូវសេចក្តីរីករាយ ហើយឈរនៅក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់មាននូវព្រះពុទ្ធ-ដីកាដូច្នេះថា ម្នាលគហបតី អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការ

ចូរអង្គុយចុះ ។ បោតលិយគហបតី នៅស្ងៀមទាំងនឹកអន់ចិត្ត ដោយសេចក្ដីក្រោធ ត្រង់ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ហៅគាត់ដោយពាក្យថាគហបតី ។ ព្រះអង្គទ្រង់ត្រាស់ហៅដោយពាក្យថាគហបតីដូច្នេះ ជាលើកទី ២ ទាំងជាលើកទី ៣ ទៀតផង បោតលិយគហបតីមានចិត្តខឹងដល់ថ្នាក់ទ្រាំមិនបាន នៅពេលដែលព្រះអង្គទ្រង់ត្រាស់ហៅជាលើកទី ៣ ទើបបានពោលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គហៅខ្ញុំដោយពាក្យថាគហបតីណា ពាក្យនោះមិនសមគួរឡើយ ពាក្យនោះមិនសុភាពឡើយ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលគហបតី អាការ ភេទ និងនិមិត្តរបស់អ្នក នៅប្រាកដជារបស់គហបតីនៅឡើយទេតើ ។

ទោះជាបោតលិយគហបតី ទូលព្រះអង្គថា ខ្លួនលាលែងអំពីការងារគ្រប់ជំពូក ប្រគល់មរតកឲ្យដល់កូនចៅអស់ហើយ មិនមានជំនួញជួញដូរអ្វីទៀតឡើយ ដូច្នេះក៏ដោយ ក៏ព្រះដ៏មានព្រះភាគទ្រង់ត្រាស់អំពីការផ្ដាច់បង់ នូវជំនួញក្នុងអរិយវិន័យដោយឡែកផ្សេងដែរ ។ កាលដែលបោតលិយគហបតីក្រាបទូលសួរហើយ ទើបព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីធម៌ ៨ ប្រការ រមែងប្រព្រឹត្តទៅដើម្បីផ្ដាច់បង់នូវជំនួញក្នុងអរិយវិន័យ ធម៌ ៨ ប្រការគឺ

១- **អបាណាតិបាតំ និស្សាយ បាណាតិបាតោ**

**បហាតព្វោ** ព្រោះអាស្រ័យការមិនសម្លាប់សត្វ ទើបលះបង់ការសម្លាប់សត្វចេញបាន ។

២- **ទិន្នាទានំ និស្សាយ អទិន្នាទានំ បហាតព្វំ** ព្រោះអាស្រ័យការកាន់យកតែទ្រព្យដែលគេឲ្យ ទើបលះបង់ការកាន់យកទ្រព្យដែលគេមិនបានឲ្យចេញបាន ។

៣- **សច្ចំ វាចំ និស្សាយ មុសាវាទោ បហាតព្វោ** ព្រោះអាស្រ័យសច្ចវាចា ទើបលះបង់ការពោលពាក្យកុហកចេញបាន ។

៤- **អបិសុណំ វាចំ និស្សាយ បិសុណា វាចា បហាតព្វា** ព្រោះអាស្រ័យពាក្យមិនញុះញង់ ទើបលះបង់ពាក្យញុះញង់ចេញបាន ។

៥- **អគិទ្ធិលោភំ និស្សាយ គិទ្ធិលោភោ បហាតព្វោ** ព្រោះអាស្រ័យសេចក្តីមិនលោភលន់ ទើបលះបង់សេចក្តីលោភលន់ចេញបាន ។

៦- **អនិន្ទារោសំ និស្សាយ និន្ទារោសោ បហាតព្វោ** ព្រោះអាស្រ័យការមិននិន្ទាគ្នាន់ក្នាញ់ ទើបលះបង់ការនិន្ទាគ្នាន់ក្នាញ់ចេញបាន ។

៧- **អក្កោធុបាយាសំ និស្សាយ កោធុបាយាសោ បហាតព្វោ** ព្រោះអាស្រ័យសេចក្ដីមិនក្រោធចង្អៀតចង្អល់ ទើបលះបង់ការចង្អៀតចង្អល់ដោយសេចក្ដីក្រោធចេញបាន ។

៨- **អនតិមានំ និស្សាយ អតិមានោ បហាតព្វោ** ព្រោះអាស្រ័យសេចក្ដីមិនមើលងាយគេ ទើបលះបង់ការមើលងាយគេចេញបាន ។

ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងចែកធម៌ ៨ ប្រការនេះឲ្យពិស្ដារនៅក្នុងព្រះសូត្រនេះ ។ ធម៌ ៨ ប្រការនេះគឺជាសីលនៅក្នុងព្រះបាដិមោក្ខសំវរសីលសម្រាប់ភិក្ខុក្នុងព្រះពុទ្ធសាសនា ។ ធម៌ទី ១ និងទី ២ ជាសីលផ្លូវកាយ ធម៌ទី ៣ និងទី ៤ ជាសីលផ្លូវវាចា ធម៌ទី ៥ ទី ៧ និងទី ៨ ជាសីលផ្លូវចិត្ត ឯចំណែក **អនិន្ទារោសៈ** គឺធម៌ ទី ៦ ជាសីលផ្លូវកាយក៏មាន សីលផ្លូវវាចាក៏មាន ។

ធម៌ទាំង ៨ ប្រការនេះ ទាក់ទងទៅនឹងការពិចារណា ហើយនិងការលះបង់របស់ព្រះអរិយសាវ័ក មានជាដើមដូចដែលព្រះអង្គទ្រង់ត្រាស់នៅក្នុងធម៌ទី ១ ដូច្នេះថា

ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញជាអ្នកសម្លាប់សត្វ ព្រោះហេតុតែសំយោជនៈ

ទាំងឡាយណា អាត្មាអញបានប្រតិបត្តិដើម្បីលះបង់ ដើម្បីផ្ដាច់បង់នូវសំយោជនៈទាំងនោះចេញហើយ ម្យ៉ាងទៀត បើអាត្មាអញជាអ្នកសម្លាប់សត្វហើយ សូម្បីខ្លួនឯង ក៏ដើម្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុតែការសម្លាប់សត្វនោះ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយៗហើយ ក៏គប្បីតិះដៀលអាត្មាអញបាន ព្រោះហេតុតែការសម្លាប់សត្វនោះដែរ លុះអាត្មាអញទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈទៅ ទុគ្គតិនឹងមានជាប្រាកដ ព្រោះហេតុតែការសម្លាប់សត្វនោះឯង ។ ធម្មជាតិនេះ គឺការសម្លាប់សត្វ ឈ្មោះថាសំយោជនៈ ឈ្មោះថានីវរណៈ ម្យ៉ាងទៀត អាសវៈទាំងឡាយណាមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុតែការសម្លាប់សត្វ អាសវៈដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលវៀរចាកការសម្លាប់សត្វយ៉ាងនេះឯង ។

ការសម្លាប់សត្វជាដើម ពោលគឺអកុសលធម៌ទាំង ៨ ព្រះអង្គទ្រង់ត្រាស់ថា ជាសំយោជនៈ ជានីវរណៈ ។ ទោះជាមិនរាប់នៅក្នុងសំយោជនៈ ១០ នីវរណៈ ៥ ប៉ុន្តែទ្រង់ត្រាស់ដោយអំណាចនៃទេសនាថា ជាគ្រឿងចងទុក និងជាគ្រឿងរារាំងបិទឃាំងទុកក្នុងវដ្ដៈដោយប្រការដូច្នេះឯង ។

អវិជ្ជាសវៈ កើតឡើងនៅក្នុង **បាណាតិបាត និន្ទារោសៈ** និង **ភោគុបាយាសៈ** ។ កាមាសវៈ ទិដ្ឋាសវៈ និងអវិជ្ជាសវៈ កើតឡើងនៅក្នុង **អទិន្នាទាន មុសាវាទ** និង **បិសុណាវាចា** ។ ទិដ្ឋាសវៈ និងអវិជ្ជាសវៈ កើតឡើងនៅក្នុង **គិទ្ធិលោភៈ** ។ ភវាសវៈ និងអវិជ្ជាសវៈ កើតឡើងនៅក្នុង **អតិមានះ** ។

## សំណួរ

១- ហេតុដូចម្ដេច បានជាអាសវៈ ៣ ( វៀរអវិជ្ជាសវៈ ) មិនកើតក្នុងបាណាតិបាតជាដើម ?

២- ភវាសវៈ មិនកើតក្នុងអទិន្នាទានជាដើម ?

៣- កាមាសវៈ និងភវាសវៈ មិនកើតក្នុងគិទ្ធិលោភៈ ?

៤- កាមាសវៈ និងទិដ្ឋាសវៈ មិនកើតក្នុងអតិមានះ ?

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងអំពីការផ្ដាច់បង់ជំនួញដោយសព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យ ដទៃផ្សេងទៀត គឺអរិយសាវ័ក តែងពិចារណានូវទោសរបស់កាមទាំងឡាយតាមដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងហើយ ដោយឧបមាផ្សេងៗ មានឧបមាដូចជារាងឆ្អឹងជាដើម ថាកាមទាំងឡាយមានទុក្ខ

ច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសរបស់កាមទាំងនោះ មានច្រើនក្រៃលែង ។ អរិយសាវ័ក បានឃើញសេចក្ដីនេះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងដូច្នេះហើយ ក៏លះបង់នូវឧបេក្ខាដែលមាន អារម្មណ៍ផ្សេងៗ គឺឧបេក្ខាក្នុងបញ្ចកាមគុណដែលមានសភាពផ្សេង គ្នា ហើយចម្រើននូវឧបេក្ខាក្នុងចតុត្ថជ្ឈាន ដែលមានសភាពតែមួយ អាស្រ័យអារម្មណ៍តែមួយ ( គឺចតុត្ថជ្ឈាន ចតុក្កន័យ អាស្រ័យ អារម្មណ៍ណាហើយ ក៏អាស្រ័យអារម្មណ៍តែមួយនោះ សូម្បីតាំងនៅ ក្នុងឈាននោះពេញមួយថ្ងៃក៏ដោយ ) បានដល់ឧបេក្ខាជាទីរលត់ទៅ នូវឧបាទានដែលអាស្រ័យលោកាមិសៈ មិនមានសេសសល់ ដោយ ប្រការទាំងពួង ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់វិជ្ជាបីជាបន្ត រួច ហើយទើបត្រាស់សួរដល់បោតលិយគហបតី អំពីការផ្ដាច់បង់នូវ ជំនួញក្នុងអរិយវិន័យ ដែលមានសភាពដូចដែលព្រះអង្គទ្រង់ត្រាស់ សម្ដែងមកនេះ តើមានក្នុងខ្លួនគហបតីដែរឬទេ ។

បន្ទាប់អំពីបោតលិយគហបតី ក្រាបទូលព្រះដ៏មានព្រះភាគ អំពីភាពឆ្ងាយគ្នារវាងខ្លួនគាត់ ជាមួយនឹងការផ្ដាច់បង់ជំនួញក្នុង អរិយវិន័យហើយ គាត់បានប្រកាសគុណព្រះភិក្ខុសង្ឃថាជាបុរស- អាជានេយ្យដោយពិត ព្រោះព្រះដ៏មានព្រះភាគ បានធ្វើឲ្យគាត់ចេះ គោរពស្រឡាញ់ដោយសេចក្ដីជ្រះថ្លាចំពោះពួកសមណៈដែលជាអ្នក

បួសដោយប្រពៃក្នុងព្រះពុទ្ធសាសនា ទាំងបានសរសើរព្រះធម៌ទេសនា ជាចុងបញ្ចប់ក៏ប្រកាសខ្លួនជាឧបាសកដល់សរណៈស្មើដោយជីវិត ។

សូមអនុមោទនា !

## ខ្លឹមសារនៃមហាកុសល

យើងគប្បីស្វែងរកភាពរីករាយស្រស់ស្រាយនៃជីវិតក្នុងបុណ្យកុសលហ្នឹងតែម្ដង ដោយមិនចាំបាច់រង់ចាំពេលណាទៀតឡើយ ។ បើចិត្តជាបុណ្យហើយ គឺអារម្មណ៍ល្អហើយ ដែលអារម្មណ៍មិនល្អមកអំពីចិត្តសៅហ្មង ចិត្តបាបអកុសលទេតើ បើមិនអប់រំកុសលភាវនាទេ ចង់បានអារម្មណ៍ល្អៗស្រាប់ៗមិនមានឡើយ ។

មនុស្សយើងតែងស្វែងរកសុភមង្គលនៃជីវិត ដោយមើលរំលងមហាកុសលក្នុងបុញ្ញកិរិយាវត្ថុ ១០ ហើយអន្ទះអន្ទែងស្វែងរកវត្ថុដែលត្រូវការទៅតាមចំណង់ ។

មនុស្សយើងមានរូបកាយហើយនិងចិត្ត រូបកាយជាធាតុមិនដឹងអារម្មណ៍ មានតែចិត្តទេដែលដឹងអារម្មណ៍ បើចិត្តដឹងអារម្មណ៍នោះជាមហាកុសលចិត្តទៅហើយ មានយើងឯណាអ្នកកើតទុក្ខទៀតនោះ ។

គេធ្វើឆត្រដើម្បីបាំងថ្ងៃ ឬបាំងភ្លៀងមិនមែនដើម្បីមិនឲ្យថ្ងៃរះ ឬមិនឲ្យភ្លៀងនោះទេ យ៉ាងណា អារម្មណ៍ដែលជារឿងរ៉ាវផ្សេងៗ ជាអំពើឬជាពាក្យសម្ដីអ្នកដទៃ គឺប្រៀបដូចជាថ្ងៃក្ដៅ ឬភ្លៀងដូច្នោះដែរ បើយើងប្រព្រឹត្តធម៌ មានសេចក្ដីអត់ធន់ និងមានមេត្តាជាដើម ក៏ដូចជាយើងមានឆត្របាំងដូច្នោះឯង គឺថាធម៌រមែងរក្សានូវអ្នកប្រព្រឹត្តធម៌ ដូចជាបុគ្គលកាន់ឆត្របាំងដើរទៅក្នុងវេលាថ្ងៃក្ដៅ ឬក្នុងពេលភ្លៀងអ៊ីចឹងឯង ។

កុំព្រោះតែពពកមួយដុំបាំងថ្ងៃ ធ្វើឲ្យយើងគិតថា ពិភពលោកនេះមិនមានភាពភ្លឺស្វាងនោះ យ៉ាងណា កុំព្រោះតែអ្នកណាម្នាក់ ឬព្រោះតែរឿងអ្វីមួយ ធ្វើឲ្យយើងគិតថា ជីវិតនេះសៅហ្មងខ្មៅងងឹតពេញមួយជីវិតនោះឡើយ មហាកុសលធ្វើឲ្យជីវិតភ្លឺស្វាង។

នៅពេលកើតទុក្ខ គប្បីសិក្សាថា អ្វីៗប្រព្រឹត្តទៅតាមហេតុ មិនមែនប្រព្រឹត្តទៅតាមការទាមទារទេ ជាក់ស្តែងត្រង់សេចក្តីទុក្ខហ្នឹងឯង ។ នេះជាប្រយោជន៍ដែលទទួលបាននៅពេលមានទុក្ខ ពោលគឺសេចក្តីទុក្ខបង្រៀនយើងឲ្យដឹងការពិត សេចក្តីទុក្ខទោះជាមិនមានអ្នកណាត្រូវការក៏ដោយ ប៉ុន្តែទុក្ខកើតឡើងព្រោះមានហេតុមានបច្ច័យត្រឹមត្រូវ ។

មនុស្សយើងសេពគប់គ្នា ព្រោះតែមានការពេញចិត្តចំពោះចំណុចល្អអំពីគ្នា ឬក៏ត្រូវអធ្យាស្រ័យគ្នា នេះជារឿងរបស់មនុស្សធម្មតា ពេលដែលទាស់ចិត្ត ទាស់អធ្យាស្រ័យ ក៏បែកបាក់គ្នា ឈ្លោះគ្នា និយាយអាក្រក់ពីគ្នា... ចំណែកបណ្ឌិត រមែងយល់អំពីចំណុចខ្វះខាតរបស់អ្នកដទៃ តែងឲ្យអភ័យជានិច្ច ។ បណ្ឌិតមិនសម្លឹងទោសអ្នកដទៃ គឺនៅត្រង់យល់អំពីចំណុចខ្វះខាតរបស់អ្នកដទៃនេះឯង មិនថាអ្នកដទៃនោះ ជាភរិយា ស្វាមី បងប្អូនកូនចៅ ឬក៏អ្នកក្រៅសន្តានណាៗឡើយ ។ ពាក្យថា សម្លឹងទោសអ្នកដទៃ គឺជាការសម្លឹងចាប់ទោស ចាប់កំហុស សង្កត់អ្នកដទៃដើម្បីលើកខ្លួនឯង កើតទៅជារឿងឈ្លោះប្រកែកទាស់ទែងគ្នា ត្រង់នេះ ព្រះពុទ្ធអង្គទ្រង់សម្តែងក្នុងបិដកលេខ ៤៨ ទំព័រ ១៣៤ អំពីកម្លាំង ៨ យ៉ាង គឺ

១- **ទេណ្ណពលា ភិក្ខវេ ទារកា** ម្នាលភិក្ខុទាំងឡាយ ពួកក្មេងមានការយំជាកម្លាំង ។

២- **កោធពលា មាតុគ្គាមា** ពួកមាតុគ្រាម មានសេចក្តីក្រោធជាកម្លាំង ។

៣- **អាវុធពលា ចោរា** ពួកចោរ មានគ្រឿងអាវុធជាកម្លាំង ។

៤- **ឥស្សរិយពលា រាជានោ** ពួកព្រះរាជា មានឥស្សរិយជាកម្លាំង ។

៥- **ឧជ្ឈត្តិពលា ពាលា** ពួកជនពាល មានការលើកទោស ( សម្លឹងទោស ) ជាកម្លាំង ។

៦- **និជ្ឈត្តិពលា បណ្ឌិតា** ពួកបណ្ឌិត មានការរំពឹងគិត ( មិនសម្លឹងទោស ) ជាកម្លាំង ។

៧- **បដិសង្ខានពលា ពហុស្សុតា** ពួកពហុស្សូត មានការពិចារណាជាកម្លាំង ។

៨- **ខន្តិពលា សមណព្រាហ្មណា** ពួកសមណ-ព្រាហ្មណ៍ មានការអត់ធន់ជាកម្លាំង ។

ពោលដោយបរមត្ថ ក្នុងលោកនេះ មិនមានអ្នកណាធ្វើទោសកំហុសឲ្យខ្លួនឯងទេ គឺព្រោះអកុសលមូល លោភៈ ទោសៈ

មោហៈ ជាបច្ច័យ ទើបមានអកុសលកម្មកើតឡើង ។ បណ្ឌិត មិនមែនមិនដឹងទោសថាជាទោសតាមពិតនោះទេ ប៉ុន្តែបណ្ឌិតរមែងសម្លឹងរកប្រយោជន៍ឲ្យបានសម្រេចដល់ខ្លួនឯង និងអ្នកដទៃ ប្រយោជន៍គឺសេចក្ដីសុខស្ងប់ និងសេចក្ដីចម្រើនទៅដោយបញ្ញា ។

មិនមានការរក្សាអ្វីណា ឲ្យបាននូវទីពឹង ដូចជាការរក្សានូវសេចក្ដីល្អរបស់ខ្លួនឯងឡើយ ។ អ្វីៗណាដែលមកដល់ជីវិតយើងតាមរយៈទ្វារទាំង ៦ មានទ្វារភ្នែកជាដើម គឺអ្វីៗនោះ មកដើម្បីឲ្យសិក្សាប៉ុណ្ណោះ មិនមែនមកដើម្បីឲ្យហួងហែងទេ ។ ជនទាំងឡាយតែងសោកសៅ ព្រោះហេតុតែហួងហែងអ្វីៗជារបស់ខ្លួនហ្នឹងឯង ។ បើដឹងខ្លួនថាលំបាកក្នុងចិត្តជាមួយនឹងអ្វីៗជុំវិញខ្លួន នេះជាសញ្ញាដាស់តឿនបញ្ជាក់ប្រាប់ថា ត្រូវប្រញាប់ចម្រើនចិត្តស្ងប់ក្នុងកុសលធម៌ ឲ្យចិត្តតាំងនៅក្នុងអារម្មណ៍ត្រជាក់និងភ្លឺស្វាង ។

ព្រះអាទិត្យពេលរះឡើងក៏ភ្លឺស្វាងរុងរឿង មានតេជះរស្មីត្រចះត្រចង់ ដល់ពេលលិចក៏ល្អស្អាតគួរឲ្យគយគន់ ទាំងក្នុងរវាងការរះនិងការលិច ព្រះអាទិត្យបានញុំាងប្រយោជន៍យ៉ាងអស្ចារ្យក្នុងភពផែនដី យ៉ាងណា មនុស្សយើងកើតមក ធ្វើខ្លួនឯងឲ្យមានសេចក្ដីសុខ និងមានប្រយោជន៍ដល់អ្នកដទៃជុំវិញខ្លួន ដល់ពេល

ចាកលោកនេះទៅ ក៏ទៅយ៉ាងល្អស្អាត មានការចងចាំទុកថាជាមនុស្សគំរូល្អ សម្រាប់អ្នកជំនាន់ក្រោយ យ៉ាងនោះឯង ។ សេចក្ដីសុខរបស់មនុស្សយើង មិនមែនស្ថិត នៅលើអ្នកណាម្នាក់ ដែលអត់ពីគាត់ទៅ យើងត្រូវកើតទុក្ខរហូតនោះទេ មិនមែនអ្នកបែកពីយើងទៅនោះ បានយកចិត្តបុណ្យអស់ពីខ្លួនយើងទៅឡើយ ដូច្នេះ យើងត្រូវតែរស់នៅ ជាមួយនឹងចិត្តបុណ្យរបស់យើងឲ្យបានល្អតទៅទៀត ហើយនឹងផ្ញើទុកនៅក្នុងការចងចាំរបស់អ្នកដទៃ គឺជាមរតកដ៏សែនសំខាន់ ។

ក្នុងការរស់នៅជុំគ្នា ត្រូវយល់អំពីចំណុចខ្វះខាតទៅវិញទៅមក កុំចេះតែប្រកាន់ថា ត្រូវតែយ៉ាងនេះ យ៉ាងនោះ ទៅតាមច្បាប់ទម្លាប់ តាមសុជីវធម៌ ជាដើម ។ បើយើងយល់អំពីចំណុចខ្វះខាតរបស់អ្នកដទៃ នាំឲ្យមានមេត្តាករុណា ចម្រើនឡើងក្នុងចិត្ត តែបើប្រកាន់ដោយការផ្ទៀងផ្ទាត់តាមច្បាប់ទម្លាប់ នាំឲ្យក្រោធឬមើលងាយអ្នកដទៃទៅវិញ ដែលជាការប្រាសចាកមេត្តាករុណាក្នុងចិត្ត ។ ត្រូវចងចាំទុកថា មនុស្សយើងសព្វថ្ងៃ មិនមានអ្នកណាមានសេចក្ដីល្អសម្បូណ៌បែបគ្រប់មុខទៅនោះទេ ដូច្នេះមានតែការឲ្យអភ័យប៉ុណ្ណោះដើម្បីសេចក្ដីសុខក្នុងការរស់នៅជុំគ្នា ។

ការខ្វះខាតជារបស់មនុស្សធម្មតា បើយើងជាទេវតា ត្រូវចេះឲ្យអភ័យ តែបើយើងប្រកាន់ខឹង ស្អប់ មើលងាយអ្នកដទៃ ក៏មិនមានអ្វីខុសពីមនុស្សធម្មតាដែរ ។

មនុស្សតែងខ្វះខាតជារឿងលោកា យើងជាទេវតាត្រូវឲ្យអភ័យ
បើយើងប្រកាន់ស្អប់អ្នកដទៃ ក៏មិនខុសអ្វីពីមនុស្សធម្មតា ។

## យល់ដឹង ៤ យ៉ាង

យល់ដឹងពីមនុស្សបានញាតកា យល់ដឹងកិច្ចការបានជាប្រមុខ
យល់ពីជីវិតរមែងបានសុខ យល់ដឹងពីទុក្ខឃើញសច្ចធម៌ ។

ដោយ **ប.ស.ថ.**

# ៥.ជីវកសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅក្នុង ជីវកម្ពវ័ន របស់ពេទ្យជីវកកោមារភច្ច ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ពេទ្យ ជីវកកោមារភច្ចបានចូលគាល់ព្រះដ៏មានព្រះភាគ ហើយ បានក្រាបទូលសួរព្រះអង្គដូច្នេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះ-អង្គបានឮមកយ៉ាងនេះថា ពួកជនតែងសម្លាប់សត្វ ចំពោះព្រះ-សមណគោតម ព្រះសមណគោតម បើទុកជាជ្រាបហេតុនោះហើយ ក៏រមែងសោយ សាច់ដែលគេធ្វើចំពោះ គឺសាច់ដែលគេធ្វើឧទ្ទិស ចំពោះខ្លួននោះ ឯង ។ បពិត្រព្រះអង្គដ៏ចម្រើន តើជនទាំងនោះ និយាយត្រូវតាមពាក្យដែលគេពោលចំពោះព្រះដ៏មានព្រះភាគ មិន មែននិយាយបង្កាច់ព្រះដ៏មានព្រះភាគ ដោយពាក្យមិនពិតផង និយាយនូវហេតុ សមគួរដល់ហេតុផងឬទេ ម្យ៉ាងទៀត វាទានុវាទ ( ការពោលឬការ ពោលតាម ) ប្រកបដោយធម៌ មិនគួរដល់នូវការ តិះដៀល ឬ ព្រះអង្គ ?

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ជនទាំងនោះ មិនបាន

និយាយឲ្យត្រឹមត្រូវតាមពាក្យដែលគេពោលចំពោះតថាគតឡើយ គឺពួកជននោះ និយាយបង្កាច់តថាគតដោយពាក្យមិនពិត ។ ម្នាលជីវកៈ តថាគតពោលនូវសាច់ដែលមិនគួរបរិភោគដោយហេតុ បីប្រការ គឺដោយការឃើញ ១ ដោយការឮ ១ និងដោយការរង្កៀស ១ ម្នាលជីវកៈ តថាគតពោលនូវសាច់ដែលមិនគួរបរិភោគដោយហេតុបីយ៉ាងនេះឯង ។ ម្នាលជីវកៈ តថាគតពោលនូវសាច់ដែលគួរបរិភោគដោយហេតុទាំងបី គឺមិនឃើញ មិនឮ និងមិនរង្កៀស ម្នាលជីវកៈ តថាគតពោលនូវសាច់ដែលគួរបរិភោគ ដោយហេតុទាំងបីនេះឯង ។

១- ដោយការឃើញច្បាស់នឹងភ្នែកខ្លួនឯង

២- ដោយការឮប្រាកដនឹងត្រចៀកខ្លួនឯង

៣- ដោយការរង្កៀសសង្ស័យ ព្រោះឃើញតែមិនប្រាកដយ៉ាងណា ព្រោះឮតែមិនប្រាកដយ៉ាងណាដែរ និងដោយការរង្កៀសក្រៅពីបានឃើញ បានឮ នេះហៅថា **បរិសង្កិតំ** រង្កៀសសង្ស័យ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីភិក្ខុក្នុងសាសនានេះ ចម្រើនអប្បមញ្ញា មានមេត្តាជាដើម ផ្សាយទៅគ្រប់ទិស ជាចិត្តទូលាយ ដល់នូវសភាពធំជាមហគ្គតចិត្ត ប្រមាណមិនបាន មិនមាន

ពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ។ កាលដែលភិក្ខុនោះឯង ទទួលបិណ្ឌបាតដ៏ប្រណីតផ្ចិតផ្ចង់ ក៏មិនបានផ្តេកផ្តួល មិនបានជ្រុលជ្រប់ មិនល្មោភ តែងឃើញទោស មានបញ្ញាជាគ្រឿងរលាស់ចេញចាកទុក្ខ ក្នុងការឆាន់បិណ្ឌបាតនោះ ដោយមិនបានគិតទុកថា ធ្វើម្តេចហ្ន៎ បានគេប្រគេនបណីតភោជនដូច្នេះទៀត នោះឡើយ ។ នេះគឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់បញ្ជាក់ប្រាប់ពេទ្យជីវកកោមារភច្ច អំពីភិក្ខុឆាន់អាហារដោយមិនមានទោស ឆាន់ដោយមិនគិតបៀតបៀនខ្លួនឯង មិនគិតបៀតបៀនអ្នកដទៃ ។

ពេទ្យជីវកៈ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគ្រាន់តែបានឮមកយ៉ាងនេះថា ព្រហ្មមានកិរិយានៅដោយមេត្តា បពិត្រ ព្រះអង្គដ៏ចម្រើន ពាក្យនោះ ខ្ញុំព្រះអង្គ គ្រាន់តែបានឮមកប៉ុណ្ណោះ ប៉ុន្តែឥឡូវនេះ ខ្ញុំព្រះអង្គបានឃើញព្រះដ៏មានព្រះភាគច្បាស់នឹងភ្នែករបស់ខ្លួនហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះដ៏មានព្រះភាគ មានកិរិយានៅដោយមេត្តាពិតៗ គឺពេទ្យជីវកៈ ពោលសំដៅដល់បុគ្គលដែលមានព្យាបាទដោយរាគៈទោសៈមោហៈណា រាគៈទោសៈនិងមោហៈនោះព្រះតថាគត បានលះបង់អស់ហើយ ដោយសមុច្ឆេទប្បហាន ។

ជាចុងក្រោយនៃព្រះពុទ្ធដីកាក្នុងព្រះសូត្រ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលជីវកៈ បុគ្គលណាសម្លាប់សត្វ ចំពោះតថាគត ឬសាវ័ករបស់តថាគត បុគ្គលនោះតែងទទួលបាបច្រើន ដោយឋានៈ ៥ យ៉ាង គឺ

១- បុគ្គលនោះនិយាយយ៉ាងនេះថា អ្នកទាំងឡាយចូរទៅនាំយកសត្វឯណោះមកដោយឋានៈណា តែងទទួលនូវបាបច្រើន ដោយឋានៈនេះឯង ។

២- សត្វនោះ កាលដែលគេយកខ្សែទាក់កដឹកយកមក ក៏ទទួលទុក្ខទោមនស្សដោយឋានៈណា... ។

៣- បុគ្គលនោះ និយាយយ៉ាងនេះថា អ្នកទាំងឡាយចូរទៅសម្លាប់សត្វនេះដោយឋានៈណា... ។

៤- សត្វនោះ កាលដែលគេកំពុងសម្លាប់ ក៏ទទួលនូវទុក្ខទោមនស្សដោយឋានៈណា... ។

៥- បុគ្គលនោះ ធ្វើឲ្យគេតិះដៀលតថាគត ឬសាវ័ករបស់តថាគត ដោយអកប្បិយមំសៈ ដោយឋានៈណា បុគ្គលនោះ តែងទទួលបាបច្រើន ដោយឋានៈនោះឯង ។

ពេទ្យជីវកកោមារភច្ច បានពោលសរសើរព្រះធម៌ទេសនា

ទាំងដែលបានពោលថា អស្ចារ្យណាស់ ពួកភិក្ខុឆាន់តែអាហារជាកប្បិយហ្ន៎ ចម្លែកណាស់ ពួកភិក្ខុឆាន់តែអាហារដែលមិនមានទោសហ្ន៎ ។

សូមអនុមោទនា !

## សូមសេចក្តីល្អពីខ្លួនឯង

សព្វថ្ងៃនេះ មិនមានអ្នកណាដឹងរឿងរបស់យើង ជាងខ្លួនយើងនោះឡើយ ទស្សន៍ទាយឲ្យខ្លួនឯងក៏បាន គឺថា ធ្វើល្អបានសេចក្តីល្អ បើធ្វើអាក្រក់ប្រាកដជាបានសន្សំបាបកម្ម ។ មនុស្សយើងបានដល់នូវភាពខ្ពង់ខ្ពស់ ឬថោកទាប ព្រោះអំពើកម្មខ្លួនឯង មិនបាច់បន់ស្រន់ទេ សូមពីខ្លួនឯងតែម្តងទៅ ។

អាក្រក់ឬល្អបង្កខ្លួនឯង គេមិនកោតក្រែងខ្លួនឯងអ្នកសាង
គេលើកតម្កើងព្រោះយើងស្អិតស្អាង ថ្ងៃល្អយើងសាងមិនបាច់ហោរទាយ។

# លះកាមលោកីយ៍ចូលកាន់ផ្នួស

អភយទានទើបបានឈ្នះ ទិដ្ឋិមានះលះកុំស្តាយ
ខឹងក្រោធប្រញាប់ឆាប់រសាយ នឿយកាយសុខចិត្តពិតជាល្អ។
អហោសិកម្មចាំឲ្យច្បាស់ វេរាកម្មក្រាស់កុំបន្ត
បញ្ចប់ត្រឹមនេះរឿងរឹករវរ សិក្សាព្រះធម៌លាលោកីយ៍ ។
អង្គុលីមាលយល់ពាក្យឈប់ បាបកម្មសព្វគ្រប់ដើម្បីអ្វី
កើតចាស់ឈឺស្លាប់កប់ក្នុងដី លះកាមលោកីយ៍ចូលកាន់ផ្នួស ៕

ដោយ **ម.ស.វ.**

# មហាកុសលសែនស័ក្តិសិទ្ធិ

និន្ទាគួរនាដូចពពក កុំបាច់ចាប់យកមកខ្វល់គិត
វានឹងរសាត់រសាយពិត ប្រឹងតែប្រព្រឹត្តល្អតទៅ ។
ជាតិមុខយើងជ្រើសរើសមិនបាន តែកម្មកល្យាណបានជាផ្លូវ
ជាតិនេះយើងអាចកែតម្រូវ ជ្រើសរើសរកត្រូវសាងជីវិត ។
ចូរធ្វើថ្ងៃនេះឲ្យបានល្អ ដើម្បីបន្តរស់គំនិត
គំនិតនៅរស់សង្ឃឹមពិត បើស្លាប់គំនិតពិតមរណា ។

គំនិតមនុស្សយើងសំខាន់ណាស់ កុំគិតផ្ដេសផ្ដាសរឿងកាមា
គិតឲ្យស្ងប់ចិត្តកើតបញ្ញា សូមថ្លែងអត្ថាមហាកុសល ។
អារោគ្យត្ថៈមិនមានរោគ កិលេសស្មោគគ្រោករោគខ្វាយខ្វល់
កំណាញ់ច្រណែនសែនរចល់ ថ្នាំមហាកុសលផលសុខចិត្ត ។
សុន្ទរត្ថៈជាក់ជាល្អ សោភ័ណបវរល្អប្រណីត
ល្អកាយវាចាព្រោះសុចរិត ល្អចេញពីចិត្តមហាកុសល ។
អនវជ្ជត្ថៈមិនមានទោស ត្រឹមត្រូវអត់ខុសលុះមគ្គផល
មិនមានអំនួតមាយាកល គឺមហាកុសលផលល្អស្អាត ។
ឆេកត្ថៈថាមហាសែនចេះ បុណ្យជាចំណេះចេះហើយឆ្លាត
លះបង់តណ្ហាមេខ្វះខាត ទានសីលសែនឆ្លាតមហាកុសល។
សុខវិបាកត្ថៈកថា ចុងក្រោយនេះណាជាមហាផល
សុខជាវិបាកមហាកុសល លោកីយ៍ឲ្យដល់លោកុត្តរា ។
ចារចងចែងចប់ទ្រព្យគឺបុណ្យ ទាំងក្រោយទាំងមុនប្រាំប្រការ
រឿងរ៉ាវជីវិតពិតបញ្ហា ដោះដោយបញ្ញាមហាកុសល ។
រឿងល្អប្រាកដក្នុងចិត្តគិត ដំណឹងល្អពិតចិត្តអស់ខ្វល់
កើតឡើងពីចិត្តមហាកុសល សម្រេចមគ្គផលដល់និព្វាន ៕

ដោយ **ម.ស.ទ.**

# គប្បីជាមនុស្សល្អរបស់ខ្លួនឯង

មនុស្សយើង គប្បីជាមនុស្សល្អរបស់ខ្លួនឯងឲ្យបានពិតប្រាកដផង កុំគ្រាន់តែជាមនុស្សល្អរបស់អ្នកដទៃនោះ ពោលគឺ គប្បីជាមនុស្សល្អពិតប្រាកដ មិនជាមនុស្សលាក់ពុត រស់នៅដោយសេចក្តីរីករាយ មិនក្តៅក្រហាយចិត្ត សុខស្ងប់ជាមួយនឹងខ្លួនឯងជាមនុស្សល្អ ។

មានពាក្យគេលើកឡើងថា ឈ្នះល្បែងទិញរបស់ ចាញ់ល្បែងអស់ លក់របស់លេងល្បែង... មានរឿងដែលគួរគិតក្នុងជីវិតមនុស្សយើងនេះ នៅត្រង់ដែលថា រស់នៅខំប្រឹងរកទ្រព្យសម្បត្តិ មិនហ៊ានឲ្យទាន ទាំងគ្មានសីលទៀត ដល់ពេលឈឺអ្វីមួយធំដុំ ក៏ត្រូវចំណាយទ្រព្យសម្បត្តិ ដែលរកបាននោះ ព្យាបាលជំងឺរហូតអស់ទ្រព្យទៅវិញ ហើយក៏ត្រូវស្លាប់... សួរថា ទ្រព្យមានតម្លៃជាងជីវិត ឬជីវិតមានតម្លៃជាងទ្រព្យ ? បើថា ជីវិតមានតម្លៃជាងទ្រព្យ ហេតុអ្វីក៏ត្រូវចំណាយជីវិតរាប់សិបឆ្នាំដើម្បីតែទ្រព្យសម្បត្តិ ហើយទីបំផុតទ្រព្យសម្បត្តិមិនអាចធានាអាយុជីវិតនេះទុកបានឡើយ ត្រូវស្លាប់ទៅជាខ្មោចអត់ឃ្លាន ព្រោះតែមិនបានធ្វើទានរក្សាសីល ។ ត្រូវសួរថែម

មួយទៀតថា ខំប្រឹងបរិភោគនិងចំណាយទ្រព្យសម្បត្តិដើម្បីព្យាបាលរោគ ត្រូវការជីវិតនៅរស់ តើដើម្បីអ្វី ? តាមពិត ជីវិតមនុស្សយើងមានតម្លៃពិសេស នៅត្រង់កុសលវិបាកបដិសន្ធិ ដែលជាដើមទុនសម្រាប់ធ្វើការឲ្យបានសម្រេចនូវប្រយោជន៍ដ៏ធំ ដែលជាប្រយោជន៍សម្រាប់ខ្លួនឯងឈ្មោះកិលេស និងប្រយោជន៍សុខស្ងប់ក្នុង ពិភពលោក ។ សម្បត្តិដើមទុនគឺកុសលវិបាកបដិសន្ធិរបស់មនុស្សយើងនេះ ជាសម្បត្តិដ៏ សំខាន់សម្រាប់សាងនូវគុណវិសេស ចាប់តាំងពីគុណធម៌លោកិយ រហូតដល់លោកុត្តរ ឲ្យសម្រេចបាន ប៉ុន្តែព្រោះការមិនបានយល់ មនុស្សយើងប្រើប្រាស់ដើមទុនដ៏សំខាន់នេះគ្រាន់តែដើម្បីសេពសោយនូវកាមគុណ សាងគ្រឿងញៀន គ្រឿងស្រវឹង ផ្សេងៗសម្រាប់ខ្លួនឯង មិនតែប៉ុណ្ណោះ នៅសាងអាវុធសង្គ្រាមដ៏ខ្លាំងក្លា គឺពាក្យសម្ដីបញ្ឈឺចិត្ត ញុះញង់ និងមុសាប្រហារកេរ្តិ៍ឈ្មោះអ្នកដទៃជាដើមទៀតផង ។

# ៦. ឧបាលិវាទសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅបាវារិកម្ពវ័ន ជិតស្រុកនាលន្ទាដែលជាស្រុកកំណើតរបស់ ព្រះអគ្គសាវ័កទាំងពីរអង្គ ។ សម័យនោះ និគន្ថនាដបុត្តក៏បាននៅអាស្រ័យ ក្នុងស្រុកនាលន្ទានោះដែរ ជាមួយនឹងនិគន្ថបរិស័ទជាច្រើននាក់ទៀត ក្នុងកាលនោះ មានការសន្ទនារវាងទីឃតបស្សីជាពួកនិគ្រន្ថ ជាមួយនឹងព្រះដ៏មានព្រះភាគ ដែលទីឃតបស្សីបានលើកឡើងថា និគន្ថនាដ-បុត្តបញ្ញត្តនូវកាយទណ្ឌៈ ( កាយកម្ម ) ថាមានទោសធំជាងគេ ក្នុងការធ្វើនូវបាបកម្ម មិនបញ្ញត្តនូវវចីទណ្ឌៈនិងមនោទណ្ឌៈ ថាមានទោសធំដូចជាកាយទណ្ឌៈនោះឡើយ ។ ចំណែកព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មនោកម្មមានទោសធំជាងគេ ក្នុងការធ្វើនូវបាបកម្ម។

ទីឃតបស្សី បាននាំសេចក្តីនេះមកប្រាប់ដល់និគន្ថនាដបុត្ត ក្នុងកាលនោះ ឧបាលិគហបតីជាប្រធានលើនិគន្ថបរិស័ទ បានសរសើរទីឃតបស្សី ហើយរ៉ាប់ខ្លួនទៅលើកវាទៈចំពោះព្រះដ៏មាន-ព្រះភាគ ទាំងនិគន្ថនាដបុត្តក៏យល់ព្រម ប៉ុន្តែទីឃតបស្សីចេះតែ

ពោលជំទាស់រឿយៗ ព្រោះក្នុងចិត្តក្រែងឧបាលិគហបតីកើតសេចក្តីជ្រះថ្លាចុះចូលជាបរិស័ទរបស់ព្រះដ៏មានព្រះភាគវិញ ។ បានជាទីឃ-តបស្សីក្រែងដូច្នេះ មកអំពីទីឃតបស្សីធ្លាប់បានឃើញព្រះវរកាយរបស់ព្រះដ៏មានព្រះភាគ និងធ្លាប់សន្ទនារឿយៗជាមួយនឹងព្រះអង្គ ចំណែកនិគន្ថនាដបុត្ត មិនទាំងធ្លាប់បានឃើញព្រះដ៏មានព្រះភាគម្តងផង ទើបមិនព្រមស្តាប់ពាក្យរបស់ទីឃតបស្សី ទាំងទុកចិត្តថា ឧបាលិគហបតី មិនចុះចូលជាសាវ័ករបស់ព្រះសមណគោតមឡើយ មានតែព្រះសមណគោតមទេ ដែលគប្បីចុះចូលជាសាវ័ករបស់ឧបាលិគហបតីវិញ ។

ឧបាលិគហបតី ទទួលពាក្យរបស់និគន្ថនាដបុត្ត ហើយក្រោកចាកទីអង្គុយ សំពះនិគន្ថនាដបុត្តធ្វើប្រទក្សិណរួចបានចូលទៅរកព្រះដ៏មានព្រះភាគ នៅក្នុងបាវារិកម្ពវ័ន ថ្វាយបង្គំព្រះដ៏មាន-ព្រះភាគ ។ ឧបាលិគហបតី មិនមែនថ្វាយបង្គំព្រះអង្គព្រោះសុជីវធម៌ ឬព្រោះព្រះអង្គជាត្រកូលក្សត្រនោះទេ តែព្រោះឧបាលិគហបតីឃើញព្រះដ៏មានព្រះភាគភ្លាម ក៏កើតសេចក្តីជ្រះថ្លាភ្លាម ទើបថ្វាយបង្គំព្រះពុទ្ធអង្គដោយសេចក្តីជ្រះថ្លា ។ កាលដែលបានស្តាប់ព្រះធម៌ទេសនា របស់ព្រះដ៏មានព្រះភាគ អំពីមនោកម្មមានទោសធំជាងគេ ក្នុងការប្រព្រឹត្តបាបកម្ម ឧបាលិគហបតី បានដឹងក្នុងចិត្តថា

ពាក្យណែនាំរបស់និគន្ថនាដបុត្តជាសាស្តាធំរបស់យើង មិនអាចនាំសត្វឲ្យរួចផុតចាកទុក្ខបានឡើយ ចំណែកព្រះធម៌ទេសនារបស់ព្រះដ៏មានព្រះភាគ ទើបនាំសត្វឲ្យរួចផុតចាកទុក្ខបានមែន ។ ឧបាលិគហបតីបានពោលសរសើរព្រះធម៌ទេសនា ហើយសូមដល់ព្រះត្រៃសរណគមន៍ស្មើដោយជីវិត ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី អ្នកចូរធ្វើនូវការពិចារណារឿយៗចុះ ព្រោះការពិចារណារឿយៗនៃមនុស្សដែល គេស្គាល់ប្រាកដដូចជាខ្លួនអ្នក ជាការប្រពៃពេក។ ព្រះដ៏មាន-ព្រះភាគ ត្រាស់ឲ្យឧបាលិគហបតីពិចារណាក្នុងការដែលដល់នូវព្រះត្រៃសរណគមន៍ ព្រោះខ្លួនអ្នកក៏បានយកនិគន្ថនាដបុត្តជា សរ-ណៈហើយដែរ ដូច្នេះត្រូវពិចារណាក្នុងការដល់នូវសរណៈនេះឲ្យបានច្បាស់លាស់ ។ ឧបាលិគហបតី រឹតតែជ្រះថ្លានឹងព្រះពុទ្ធដីកា មានចិត្តត្រេកអររីករាយជាពន់ពេក បានក្រាបទូលព្រះដ៏មានព្រះភាគ អំពីកាលដែលពួកនិគ្រន្ថបានខ្ញុំព្រះអង្គជាសាវ័កនោះ បានលើកទង់សំពត់ក្នុងស្រុកនាលន្ទាទាំងអស់ ដោយអំណរថា ឧបាលិគហបតីចុះចូលមកជាសាវ័ករបស់ពួកយើងហើយ ចំណែកព្រះដ៏មានព្រះភាគវិញ នៅពេលដែលខ្ញុំព្រះអង្គសូមដល់ត្រៃសរណគមន៍ស្មើដោយជីវិត ព្រះអង្គបានរំលឹកដល់ខ្ញុំព្រះអង្គឲ្យមានការពិចារណារឿយៗ ។

ឧបាលិគហបតី បានសូមដល់ព្រះត្រៃសរណគមន៍ជាគម្រប់ពីរដង ដោយសេចក្ដីជ្រះថ្លា ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់បន្តថា ម្នាលគហបតី ត្រកូលរបស់អ្នកតាំងនៅដូចជាអណ្ដូងនៃពួកនិគ្រន្ថ ជាយូរអង្វែងមកហើយ អ្នកគប្បីសម្គាល់នូវបិណ្ឌបាត ដែលអ្នកគប្បីឲ្យដល់ពួកនិគ្រន្ថនោះដែលបានចូលមកដល់ផងចុះ ។ ឧបាលិគហបតី រឹងរឹតតែបន្ថែមសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធដីកា ព្រោះធ្លាប់តែបានឮពីសម្នាក់នៃពួកនិគ្រន្ថមកថា ព្រះសមណគោតមហាមឃាត់ទានចំពោះគ្រូដទៃ សាវ័កដទៃ គួរឲ្យចំពោះតែតថាគត និងសាវ័ករបស់តថាគតទើបមានផលច្រើន ក៏ប៉ុន្តែឥឡូវនេះ ព្រះអង្គបានណែនាំដល់ខ្ញុំព្រះអង្គឲ្យធ្វើទានដល់ពួកនិគ្រន្ថដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងសម្គាល់កាលដ៏សមគួរក្នុងការឲ្យទាននេះ រួចហើយក៏បានសូមដល់ព្រះត្រៃសរណគមន៍ជាគម្រប់បីដង ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងនូវអនុបុព្វីកថា គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា កាមាទីនវកថា និងនេក្ខមានិសង្សកថា ដល់ឧបាលិគហបតី ។ កាលដែលព្រះដ៏មាន-ព្រះភាគ ទ្រង់ជ្រាបនូវឧបាលិគហបតីថា មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លា

ដូច្នេះហើយ ទើបព្រះអង្គទ្រង់ប្រកាសសម្ដែងនូវអរិយសច្ចទាំង ៤ ។ ជាធម្មតាសំពត់ស្អាត ប្រាសចាកវត្ថុមានពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយល្អបាន មានឧបមាដូចម្ដេចមិញ ធម្មចក្ខុគឺសោតាបត្តិ-មគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល បានកើតឡើងដល់ឧបាលិ-គហបតី ក្នុងទីអង្គុយនោះឯងថា ធម្មជាតិណានីមួយ ដែលកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ ឧបាលិគហបតី បានដឹងច្បាស់នូវអរិយសច្ចធម៌ ឆ្លងផុតសេចក្ដីសង្ស័យ ដល់នូវសេចក្ដីក្លៀវក្លាក្នុងសាសនានៃព្រះដ៏មានព្រះភាគ ហើយបានក្រាបថ្វាយបង្គំលាព្រះដ៏-មានព្រះភាគ ក្រោកចាកអាសនៈ ធ្វើប្រទក្សិណគោរពចំពោះព្រះអង្គជាព្រះបរមសាស្ដា រួចទើបចូលទៅកាន់លំនៅរបស់ខ្លួន ។

ទីឃតបស្សី បានដឹងរឿងហើយប្រាប់ដល់និគន្ថនាដបុត្ត អំពីឧបាលិគហបតីចុះចូលជាសាវ័ករបស់ព្រះសមណគោតម ប៉ុន្ដែនិគន្ថនាដបុត្តមិនជឿជាដាច់ខាត ដើម្បីឲ្យប្រាកដច្បាស់ក៏បាននាំបរិស័ទរបស់ខ្លួនមកកាន់ផ្ទះឧបាលិគហបតី ។ កាលដែលបានសួរនាំដឹងរឿងច្បាស់ដោយខ្លួនឯងហើយ និគន្ថនាដបុត្តមិនអាចអត់ទ្រាំនឹងការបាត់បង់នូវអ្នកដែលធ្លាប់ទំនុកបម្រុងពួកខ្លួន ដ៏សែនសំខាន់ដូច្នេះបានឡើយ ម្ល៉ោះហើយ សេចក្ដីសោកដ៏ខ្លាំងក្លាក៏បានកើតឡើង

រហូតដល់ក្អួតឈាមក្តៅៗប្រមាណជាមួយបាត្រ ហើយទន់ជើងលុតជង្គង់ចុះ ដួលក្នុងភូមិគ្រឹះរបស់ឧបាលិគហបតី ត្រូវបរិស័ទសែងចេញទៅ ហើយក៏ត្រូវស្លាប់នៅឯនគរបាវា ។

អ្នកដែលមានបុណ្យបានធ្វើទុកមក ទាំងដែលមានឧបនិស្ស័យជាមួយនឹងព្រះរតនត្រ័យ ដូចជាឧបាលិគហបតី បានចូលក្នុងសំណាញ់ញាណនៃព្រះតថាគត ដែលព្រះអង្គទ្រង់បំពេញព្រះបារមីទាំងឡាយ ក៏ដើម្បីសង្គ្រោះនូវបុគ្គលអ្នកមានឧបនិស្ស័យដោយប្រការដូច្នេះឯង ។

សូមអនុមោទនា !

# គិតល្អជាពរដ៏ឧត្តម

គិតល្អជាពរដ៏ឧត្តម គិតអាក្រក់ចំជាបាបមិត្ត
ហួងហែងព្រោះតែរឿងអតីត[១] បច្ចុប្បន្នពិតមិនបានសុខ ។
រឿងខ្លះយើងដោះស្រាយមិនចេញ កុំយកម្នោម្នេញជាប្រមុខ

[១] អានថា អឌិត

តាំងចិត្តឲ្យស្ងប់កុំកើតទុក្ខ បុណ្យជាប្រមុខដោះបញ្ហា ។
យកដំណឹងល្អពីចិត្តបុណ្យ រឿងល្អពេកពន់គុណកុសលា
ឲ្យតែចិត្តបុណ្យរឿងម្ដេចម្ដា ក៏អត់បញ្ហាក្នុងជីវិត ។
កុំចង់បានប្រាក់តាមលោភៈ ក្រែងជាប់អន្ទាក់នៃបាបមិត្ត
ត្រូវស្វែងរកសុខឲ្យជីវិត សុខនៅយ៉ាងជិតគឺចិត្តស្ងប់ ។
លះបង់ជីវិតរាប់សិបឆ្នាំ ទាំងធ្វើបាបកម្មស្វែងរកទ្រព្យ
លុះមានជំងឺឈឺខ្លាចងាប់ យល់ព្រមលះទ្រព្យទុកជីវិត ។
តើយកជីវិតមកធ្វើអ្វី តើឲ្យតម្លៃអ្វីមែនពិត
ឲ្យតម្លៃទ្រព្យឬជីវិត គិតមើលឲ្យល្អិតកើតបញ្ញា ។
ជីវិតមនុស្សយើងសំខាន់ណាស់ ដើមទុនធំក្រាស់សាងកុសលា
កុំឲ្យជីវិតឥតខ្លឹមសារ កុំឲ្យមរណាកេរ្តិ៍អសោច ។
កុំចូលចិត្តគិតជំនួសគេ ហាក់ដូចពូកែតែមិនខ្មោច
បានត្រឹមតែគិតឥតប្រយោជន៍ ខំពោលប៉ោចៗឥតបានការ ។
ត្រូវចេះប្រយ័ត្នគំនិតគិត ព្រោះនាំប្រព្រឹត្តកាយវាចា
គំនិតប្រសើរព្រោះសិក្សា ហេតុផលយ៉ាងណាជាការពិត។
ឃើញគេមានបានមិនច្រណែន មាសប្រាក់រាប់សែនមិនស្មើចិត្ត
គឺចិត្តខ្លួនឯងដែលសុខពិត នេះហើយជីវិតមានខ្លឹមសារ ។
ម្យ៉ាងទៀតសន្ដោសទៅតាមមាន សុខលើសប្រាក់លានកោដិដុល្លារ
មិនបាច់ប្រជែងនឹងអ្នកណា ឈ្នះតែអាត្មាដល់ទិសដៅ ។

ចម្រើនមេត្តាឲ្យអភ័យ
ឃើញអ្នកដទៃដូចញាតិផៅ
លេបថ្នាំខន្តីកម្ចាត់ក្ដៅ
ចិត្តឥតហ្មងសៅសោយសុខា ។
ដំណាំខែប្រាំងត្រូវស្រោចទឹក
រស់ល្អមានស្លឹកចេញផ្លែផ្កា
ចង់ឲ្យទុក្ខស្រាកស្រោចកុសលា
ចិត្តរីកស្រស់ថ្លាលាលោកីយ៍ ។
ធម្មតាផែនដីគេដើរលើ
មិនមែនទល់ទើរទូលផែនដី
យ៉ាងណារឿងរ៉ាវក្នុងលោកីយ៍
ទុកដូចផែនដីសម្រាប់ដើរ ។
កុំរែកកុំទូលនូវរឿងរ៉ាវ
កុំក្រោធឆេវឆាវទើបប្រសើរ
បើដួលត្រូវក្រោកតដំណើរ
ខំព្យាយាមដើរដល់និព្វាន ៕

ដោយ **ប.ស.ឋ.**

# ស្ងប់ផ្លូវចិត្តជីវិតរស់ទាយ

កុំចេះតែបណ្ដោយឲ្យចិត្តគិតកើតទុក្ខទៅរឿយៗ ព្រោះការគិតឲ្យ ជាសុខទាំងជាកុសលចិត្តទៀតមានដែរតើ ម្យ៉ាងទៀត ពេលដែលកំពុងតែគិតកើតទុក្ខក្នុងចិត្តនោះ កុំភ្លេចរលឹកដឹងថា គ្រាន់តែជាចិត្តគិតប៉ុណ្ណោះ មិនមែនជាតួខ្លួនសត្វបុគ្គលណានោះទេ គឺជាធាតុសុទ្ធៗ ។

រៀនធ្វើ រៀនសន្សំសេចក្ដីសុខដែលប្រាសចាកទោសដាក់ក្នុងចិត្តខ្លួនឯង តាំងពីការងារបន្តិចបន្តួច ធម្មតាៗ ដូចជាពេលបរិភោគ ពេលអង្គុយ ពេលដើរជាដើម រហូតដល់ទៅការងារធំដុំដល់ថ្នាក់សង្គ្រោះជីវិតទៀតផង ។

## មានអ្វីដែលគួរឲ្យខ្លាចជាងបាបទៀត

អ្នកធ្វើបាប មិនអាចបាននូវសេចក្ដីស្ងប់ចិត្តឡើយ ទោះជាខំធ្វើមុខស្រស់ ក៏ក្រៀមខាងក្នុង ដួងចិត្តគ្រាំគ្រា លុះត្រាតែតាំងចិត្តឈប់ធ្វើបាបទាំងពួង ញុំាងចិត្តឲ្យត្រេកអរក្នុងកុសលធម៌ ទើបអាចអប់រំចិត្តបាន ។ អ្នកមានសតិសម្បជញ្ញៈ មានហិរិឱត្តប្បៈ ខ្លាចបាបជាងខ្លាចអ្វីៗទៀតទាំងអស់ មិនធ្វើអំពើអាក្រក់សូម្បីតែក្នុងទីកំបាំងមុខ ម្យ៉ាងទៀត មិនធ្វើនូវបាបទាំងពួង ព្រោះដើម្បីឲ្យកិត្តិយសខ្លួនឯង ដែលបានកើតមកជាមនុស្ស ។

# ៧-កុក្កុរោវាទសូត្រ

សម័យមួយ  ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅកោលិយជនបទ សម័យនោះ  កោលិយបុត្តឈ្មោះបុណ្ណៈ  ជាអ្នកសមាទាននូវគោវត្ត គឺប្រព្រឹត្តធ្វើដូចជាសត្វគោ  ពាក់ស្នែងមួយគូលើក្បាល  ដាក់កន្ទុយ ហើយដើរស៊ីស្មៅជាមួយនឹងហ្វូងគោ  មានម្នាក់ទៀត  ធ្លាប់ជាមិត្ត សម្លាញ់លេងដីជាមួយគ្នាឈ្មោះសេនិយៈ  ជាអចេលអត់ស្លៀកពាក់ ហើយប្រព្រឹត្តកុក្កុរវត្ត  គឺប្រព្រឹត្តធ្វើដូចជាសត្វឆ្កែគ្រប់បែបគ្រប់យ៉ាង ។ ទាំងពីរនាក់នេះ បានចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលព្រះអង្គអំពីកិច្ចវត្តរបស់ខ្លួន និងក្រាបទូលសួរអំពីគតិទៅបរលោក តើដូចម្ដេច ។

សីលព្វតបរាមាសៈ គឺជាទិដ្ឋិដែលស្ទាបអង្អែលនូវការប្រព្រឹត្ត របស់ខ្លួនរឿយៗ ដោយចំណូលចូលចិត្តនឹងប្រព្រឹត្ត ព្រមដោយការយល់ខុសក្នុងហេតុផលធម្មជាតិទៀតផង  ដូច្នេះបើសន្ដានពេញបរិបូណ៌ក្នុងសភាពជាគោ ក៏ត្រូវទៅកើតជាគោ បើពេញបរិបូណ៌ក្នុងសភាពជាឆ្កែ ក៏ត្រូវទៅកើតជាឆ្កែ ហើយបើសភាពនៃការយល់ខុស

នោះធ្ងន់ខ្លាំង ត្រូវទៅកើតក្នុងនរកទៀតផង ។

កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងប្រាប់សព្វគ្រប់ហើយ អ្នកទាំងពីរក៏ទ្រហោយំ ដោយការសោកស្តាយពេលវេលាក្នុងការប្រព្រឹត្តរឿងឥតប្រយោជន៍របស់ខ្លួន ហើយទូលសូមព្រះអង្គទ្រង់ត្រាស់ប្រាប់ការពិតយ៉ាងណា ដើម្បីខ្ញុំព្រះអង្គមានការយល់ត្រូវ ប្រព្រឹត្តទៅដើម្បីលះបង់នូវការប្រព្រឹត្តខុសទាំងនោះចោលចេញ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីកម្ម ៤ ប្រការ

១- កម្មខ្មៅមានវិបាកខ្មៅ គឺអកុសលកម្មឲ្យកើតក្នុងអបាយ-ភូមិ ជាពិសេសគឺនរក ដែលមានសេចក្តីទុក្ខតែម្យ៉ាង ( ឯកន្តទុក្ខំ )។

២- កម្មសមានវិបាកស គឺកុសលកម្មឲ្យកើតក្នុងសុគតិភព ជាពិសេសគឺព្រហ្មលោក ដែលមានសេចក្តីសុខតែម្យ៉ាង (ឯកន្តសុខំ)។

៣- កម្មខ្មៅនិងកម្មសមានវិបាកខ្មៅនិងស គឺកុសលកម្មឲ្យកើតជាមនុស្សឬទេវតា ដែលក្នុងបវត្តិកាលមានអកុសលកម្មឲ្យផលវិបាកផងដែរ ម្យ៉ាងទៀត អកុសលកម្មឲ្យកើតជាសត្វ ក្នុងអបាយភូមិពួកខ្លះ ដែលក្នុងបវត្តិកាលមានកុសលកម្មឲ្យផលវិបាកផងដែរ ។

៤- កម្មមិនខ្មៅមិនសមានវិបាកមិនខ្មៅមិនស រមែងប្រព្រឹត្តទៅដើម្បីអស់កម្ម គឺអរិយមគ្គទាំង ៤ មានសោតាបត្តិមគ្គ ជាដើម

ដែលមគ្គចេតនា ឲ្យមានវិបាកជាលោកុត្តរ ទាំងដែលមគ្គចេតនានេះឯងបានលះបង់នូវកម្មដែលជាអភិសង្ខារ គឺពួកកម្មទាំងបីខាងដើមហ្នឹងឯង ។

កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងចែកកម្មទាំង ៤ យ៉ាងនេះចប់ហើយ បុណ្ណកោលិយបុត្ត បានពោលសរសើរព្រះធម៌ទេសនា ហើយដល់នូវព្រះត្រៃសរណគមន៍ស្មើដោយជីវិតចំណែកសេនិយអចេល បានបព្វជ្ជានិងឧបសម្បទាក្នុងសម្នាក់ព្រះដ៏-មានព្រះភាគ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តជាព្រះអរហន្តមួយអង្គដែរទៅ ។

សូមអនុមោទនា !

# ជីវិតរបស់យើង

កើតមកជាអ្នកក្រក្រី កុំបន្ទោសមេឃកុំបន្ទោសដី កុំបន្ទោសម៉ែឪកុំបន្ទោសអ្នកដទៃ ក៏កុំមើលងាយខ្លួនឯងដែរ ត្រូវគិតថា សត្វលោកច្រើនណាស់ ដែលមិនទាំងបានកើតមកជាមនុស្សផង ។ បានជាក្រហើយ អកុសលវិបាកដទៃៗក៏សម្បូណ៌ដែរ ត្រូវតស៊ូ

ក្នុងជីវិត សាងសេចក្តីល្អកុំឲ្យក្រពុណ្យ ឲ្យកម្លាំងចិត្តដល់ខ្លួនឯង ត្រូវយល់ថា ជីវិតជារបស់យើង ។ ជីវិត ជារបស់យើងក្នុងន័យនេះ បានសេចក្តីថា ទោះបីយើងក្រីក្រទ្រព្យសម្បត្តិយ៉ាងណា ក៏ប៉ុន្តែ យើងក៏កំពុងតែរស់នៅដោយជីវិតរបស់យើងដែរ គឺមិន មែនរស់នៅ ដោយជីវិតអ្នកដទៃទេ ។ ឧទាហរណ៍ដូចយើងរកមួយថ្ងៃបាន ១ ម៉ឺនរៀល ចំណែកអ្នកដទៃនោះៗរកមួយថ្ងៃបាន ១ ម៉ឺនដុល្លារ ប៉ុន្តែ យើងមិនមែនរស់នៅដោយប្រាក់ ១ ម៉ឺនដុល្លាររបស់គេនោះទេ គឺពិត ជាដោយសារប្រាក់ ១ ម៉ឺនរៀលដែលយើងរកបានហ្នឹងឯង ម្យ៉ាង ទៀត ដូចជា ឪពុកម្តាយយើងទោះជាគាត់ក្រលំបាកពិត តែយើងរស់ ដោយសារគាត់ចិញ្ចឹម មិនមែនដោយសារមហាសេដ្ឋីណានោះទេ ជីវិតយើងក៏ដូច្នោះដែរ គឺយើងរស់នៅដោយជីវិតខ្លួនឯង ដូច្នេះត្រូវកុំ មើលងាយជីវិតខ្លួនឯងឲ្យ សោះ ត្រូវតែឲ្យតម្លៃដោយការតម្កល់ជីវិត ក្នុងគុណធម៌ ត្រូវចាំថា ទោះជាយ៉ាងណាៗ ជីវិតនេះជារបស់យើង គឺមិនមែនជារបស់អ្នកដទៃឡើយ ។

## មានទឹកចិត្តព្រោះសេចក្តីស្រឡាញ់

កាលដែលមនុស្សយើងមានរបស់ជាទីស្រឡាញ់ រមែងសប្បាយចិត្ត មានកម្លាំងចិត្ត ។ បុរសស្ត្រី កំលោះក្រមុំ ដែលទើបស្រឡាញ់គ្នាគ្រាដំបូង ក៏ដូច្នោះដែរ គឺរំភើបរីករាយ មានទឹកចិត្តក្នុងការងារ ត្រេកអរក្នុងជីវិត ពិតជាសប្បាយចិត្តណាស់ ។ អ្វីៗសុទ្ធតែប្រែប្រួល ទាំងសេចក្តីស្រឡាញ់ ទាំងរបស់ជាទីស្រឡាញ់ ដូច្នេះយើងគួរចេះប្រើប្រាស់សេចក្តីស្រឡាញ់ នាំគ្នាសាងកុសលធម៌ឲ្យបាននូវទីពឹងរៀងៗខ្លួន កុំឲ្យសេចក្តីស្រឡាញ់ប្រើយើងទៅធ្វើបាបកម្មផ្សេងៗឲ្យសោះ ។ ក្នុងចំណុចសំខាន់ គឺយើងត្រូវចេះសាងកម្លាំងចិត្តដោយការចេះស្រឡាញ់ខ្លួនឯង រីករាយជាមួយនឹងខ្លួនឯងដែលជាមនុស្សល្អ កុសលឆន្ទៈពេញពោរមិនចេះរីងស្ងួតឡើយ ដែលជាទីពឹងជួយខ្លួនឯងឲ្យរួចផុតចាកទុក្ខលំបាកបាន ។

## មេត្តាដល់គេ ចិត្តយើងបានត្រជាក់

មេត្តាដល់អ្នកដទៃ ចិត្តយើងបានបុណ្យ ខឹងស្អប់គេ ដូច

យកភ្លើងមកដុតខ្លួនឯង ឲ្យអភ័យបាន ចិត្តយើងខ្ពង់ខ្ពស់ ត្រជាក់ជាសុខ ។

## គ្រប់យ៉ាងសម្រាប់យល់ មិនមែនសម្រាប់ហួងហែងទេ

យើងតែងកើតទុក្ខ ឬទាស់ចិត្ត ព្រោះមិនបាននូវអ្វីដែលយើងចង់បាន ។ ត្រូវចេះគិតថា អ្វីៗដែលយើងចង់បាននោះ ប្រសិនបើបានមក វាមានតម្លៃដូចជាមហាកុសលដែរឬទេ ជាទីពឹងឲ្យយើងរួចផុតចាកទុក្ខដែរឬទេ ។ តាមពិត បើយើងកំណត់ទិសដៅនៃជីវិត កំណត់ការងារឲ្យប្រាកដ ដឹងខ្លួនច្បាស់ថា យើងរស់នៅដើម្បីអ្វី ដូច្នេះ វាមិនសូវមានរឿងអ្វីឲ្យខ្វាយខ្វល់កើតទុក្ខទៅក្នុងចិត្តនោះទេ ព្រោះទិសដៅនៃជីវិតរបស់យើងគឺការរលត់ទុក្ខ ចំណែកការងារគឺបំពេញបុណ្យ និងជីវិតរស់នៅដើម្បីសិក្សាឲ្យយល់ឡើងៗនូវអ្វីក្នុងលោកនេះ សប្បាយចិត្ត ព្រោះបានយល់ដឹងអំពីការពិតនៃលោកនេះ គ្រប់យ៉ាងគួរដល់ការសិក្សាឲ្យយល់ មិនមែនសម្រាប់ហួងហែងទេ ។

# ៨.អភយរាជកុមារសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ សម័យនោះ អភយរាជកុមារ ( ជាព្រះរាជឱរសរបស់ព្រះបាទពិម្ពិសារនិងនាងបទុមវតីស្រីស្អាតប្រចាំនគរឧជ្ជេនី ) នៅរាប់អាននិគន្ថនាដបុត្តជាគ្រូអាចារ្យ ហើយបានរ៉ាប់រងទទួលយកពាក្យរបស់និគន្ថនាដបុត្ត ទៅលើកវាទៈជាមួយនឹងព្រះដ៏មានព្រះភាគទៀតផង ។

ពាក្យនេះ និគន្ថនាដបុត្ត បានគិតអស់ ៤ ខែ ទម្រាំតែរកនឹកឃើញ ក្នុងបំណងសួរផ្ចាញ់ផ្ចាលព្រះដ៏មានព្រះភាគ ព្រោះហេតុតែតែមិនជ្រាបនូវព្រះពុទ្ធគុណ គឺឲ្យអភយរាជកុមារទូលសួរព្រះដ៏មាន-ព្រះភាគថា បពិត្រ ព្រះអង្គដ៏ចម្រើន វាចាណាមិនជាទីស្រឡាញ់មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តើព្រះតថាគតគប្បីពោលវាចានោះដែរឬទេ ? សំណួរដូច្នេះ ដើម្បីផ្ចាញ់ផ្ចាលព្រះអង្គត្រង់ដែលថា បើព្រះអង្គទ្រង់ត្រាស់ថា តថាគតពោលវាចានោះដែរ នឹងចោទព្រះអង្គថា ព្រះអង្គមានខុសអ្វីអំពីបុថុជ្ជន ព្រោះបុថុជ្ជនក៏

ពោលនូវវាចានោះដែរ តែបើព្រះអង្គទ្រង់ត្រាស់ថា តថាគតមិនពោលនូវវាចានោះទេ នឹងចោទព្រះអង្គថា បើដូច្នោះ ព្រោះហេតុអ្វីបានជាព្រះអង្គទ្រង់ព្យាករទេវទត្តថា ទេវទត្តកើតក្នុងអបាយ ទេវទត្តកើតក្នុងនរកឋិតនៅអស់មួយកប្ប សូម្បីព្រះពុទ្ធមួយពាន់ព្រះអង្គ ក៏មិនអាចជួយកែបានឡើយ ហើយទេវទត្តក៏ខឹងអាក់អន់ចិត្ត ដោយព្រះវាចារបស់ព្រះអង្គនោះឯង ។ និគន្ថនាដបុត្ត គិតថា បញ្ហានេះទោះបីព្រះដ៏មានព្រះភាគទ្រង់ឆ្លើយតបយ៉ាងណា ក៏នៅតែចាប់កំហុសដាក់ព្រះអង្គបានដែរ ។

អភយរាជកុមារ ទៅវត្តវេឡុវ័ន ក្រឡេកមើលព្រះអាទិត្យក៏គិតថា ឥឡូវល្ងាចណាស់ហើយ មិនមានពេលគ្រប់គ្រាន់សម្រាប់ព្រះសមណគោតមគិតគូរដើម្បីនឹងឆ្លើយតបបញ្ហាឡើយ ព្រោះបញ្ហានេះ អាចារ្យរបស់យើងបាននឹកគិតដល់ទៅ ៤ ខែឯណោះ ។ អភយ-រាជកុមារ បានអារាធនាព្រះដ៏មានព្រះភាគនិងភិក្ខុសង្ឃជាគម្រប់ ៤ អង្គ ទៅកាន់លំនៅរបស់ខ្លួន ដើម្បីនឹងលើកវាទៈក្នុងថ្ងៃស្អែកវិញ ។

ក្នុងការដោះស្រាយនូវបញ្ហា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលរាជកុមារ ការដោះស្រាយក្នុងបញ្ហានេះ មិនតែមួយចំណែកទេ ។

អដ្ឋកថា បានបញ្ជាក់ថា តថាគតពោលក្តី មិនគប្បីពោលក្តី

នូវវាចាដែលមានសភាពបែបនោះ គឺនៅត្រង់ថា បើតថាគតឃើញប្រយោជន៍ដោយបច្ច័យនៃភាសិត ទើបតថាគតពោល បើមិនឃើញប្រយោជន៍ទេ គឺតថាគតមិនពោលឡើយ ។

ព្រះដ៏មានព្រះភាគ ទ្រង់ចែកវាចាដែលមិនជាទីស្រឡាញ់មិនជាទីគាប់ចិត្តនៃពួកជនដទៃជាបីផ្នែកគឺ

១- វាចាមិនពិតប្រាកដ និងមិនប្រកបដោយប្រយោជន៍ គឺព្រះតថាគតមិនត្រាស់ពោលនូវវាចានោះ ។

២- វាចាពិតប្រាកដ តែមិនប្រកបដោយប្រយោជន៍ ក៏ព្រះតថាគតមិនត្រាស់ពោលនូវវាចានោះដែរ ។

៣- វាចាដែលពិតប្រាកដ ហើយប្រកបដោយប្រយោជន៍ទៀតទើបព្រះតថាគត ស្គាល់កាលគួរ នឹងត្រាស់ព្យាករ ពោលវាចានោះ ។

ទោះបី វាចាដែលជាទីស្រឡាញ់ជាទីគាប់ចិត្ត នៃពួកជនដទៃ ក៏ព្រះអង្គទ្រង់ចែកជាបី ហើយទ្រង់មានព្យាករណ៍ ត្រាស់ពោលតែព្រះវាចាណាដែលពិតប្រាកដហើយប្រកបដោយប្រយោជន៍ទាំងដែលព្រះអង្គទ្រង់ជ្រាបនូវកាលគួរទៀតផង ។

ពាក្យដែលមិនជាទីស្រឡាញ់ពេញចិត្តនៃពួកជនដទៃ ប៉ុន្តែ

ជាពាក្យពិតទាំងមានប្រយោជន៍ទៀត គឺជាពាក្យទូន្មានប្រៀនប្រដៅសម្រាប់មហាជន មានជាដើមយ៉ាងនេះថា ព្រោះអ្នកមិនបានធ្វើបុណ្យទុកមក ទើបក្រ ទើបលំបាក មានពណ៌សម្បុរអាក្រក់ ត្រកូលអាប់ឱន...សូម្បីឥឡូវតាំងនៅក្នុងអត្តភាពជាមនុស្សហើយ មិនធ្វើបុណ្យទៀត តើឲ្យអត្តភាពតទៅនឹងរួចផុតអំពីអបាយភូមិ ៤ យ៉ាងដូចម្ដេចទៅ ។ ក្នុងសេចក្ដីនេះ មានឧបមាដូចជាក្មេងតូចដែលស្លាក់អំបែងត្រង់ក ឪពុកបានយកដៃឆ្វេងចាប់ក្បាលកូន ហើយលូកម្រាមដៃស្ដាំចូលក្នុងមាត់ខ្វេះយកអំបែងមកដោយទាំងឈាមផង ព្រោះហេតុតែឪពុកនោះឯងមានសេចក្ដីអាណិតកូនរបស់ខ្លួន ។ ក្នុងសេចក្ដីឧបមានេះ យ៉ាងណា គឺព្រះតថាគតទ្រង់មាននូវសេចក្ដីអនុគ្រោះ ចំពោះសត្វទាំងឡាយ ទើបព្រះអង្គទ្រង់ត្រាស់ព្យាករពោលនូវព្រះវាចាដែលពិតប្រាកដ ទាំងមានប្រយោជន៍ ទោះមានអ្នកដទៃមិនពេញចិត្តក្ដី គឺព្រះអង្គទ្រង់ជ្រាបកាលគួរនឹងត្រាស់នូវព្រះវាចានោះ ជាព្រះវាចាដាស់តឿនដល់មហាជន ។

អភយរាជកុមារ បានក្រាបទូលសួរព្រះដ៏មានព្រះភាគ អំពីការដោះស្រាយបញ្ហា តើព្រះអង្គទ្រង់ព្រះតម្រិះទុកក្នុងព្រះហឫទ័យជាមុន ឬក៏ព្រះញាណកើតឡើងទាន់ពេលក្នុងការព្យាករបញ្ហា ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីធម្មធាតុគឺសព្វញ្ញុតញ្ញាណដែល

ព្រះតថាគតចាក់ធ្លុះហើយដោយប្រពៃ ទើបការព្យាករនូវបញ្ហានោះជាក់ច្បាស់ដល់ព្រះតថាគតទាន់ពេល ។

អភយរាជកុមារ បានពោលសរសើរព្រះធម៌ទេសនា ហើយបានសូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ដោយពាក្យជាចុងក្រោយក្នុងព្រះសូត្រថា សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសកដល់នូវព្រះត្រៃសរណគមន៍ស្មើដោយជីវិត ចាប់ផ្ដើមតាំងអំពីថ្ងៃនេះតទៅ ។

សូមអនុមោទនា !

## របៀបគិតរំខាប់សេចក្ដីក្រោធ

- បានជាអ្វីៗប្រាកដមកមិនឲ្យជាប់ជំពាក់ហើយ ក៏គួរតែសប្បាយចិត្ត មិនគួរខឹងស្អប់ប្រទូស្តទាស់នឹងអ្វីៗនោះឡើយ ព្រោះការជាប់ជំពាក់ចិត្តវាជាវិបត្តិធ្ងន់ធ្ងរ នាំមកនូវទុក្ខសព្វយ៉ាងក្នុងភពបី ។ អ្វីៗណា ដែលជាអារម្មណ៍នាំឲ្យភ័យខ្លាច កើតទុក្ខចង្អៀតចង្អល់ខ្វាយខ្វល់ ខឹងក្រោធក្នុងសភាពផ្សេងៗ អ្វីៗទាំងអស់នោះ យើង

តែងគិតថាវាជាសត្រូវក្នុងជីវិតរបស់យើង ប៉ុន្តែបើយើងគិតពិចារណាដោយល្អ គឺវាជាមិត្តដែលមកក្នុងរូបភាពជាសត្រូវ ព្រោះអ្វីៗនោះបានបង្ហាញប្រាប់យើងអំពីការពិត ប្រព្រឹត្តទៅតាមបច្ច័យ ហាមឃាត់មិនបាន បង្គាប់បញ្ជាទាមទារក៏មិនបាន ម្យ៉ាងទៀត អ្វីៗនោះឯងហើយ ដែលជាអារម្មណ៍រំលឹកដាស់តឿន កុំឲ្យយើងចេះតែត្រេកអរនៅក្នុងភព ឲ្យយើងគេចអំពីកាមគុណ រកទីពឹងអាស្រ័យក្នុងកុសលធម៌ រកសេចក្តីស្ងប់ស្ងាត់ប្រព្រឹត្តទៅដោយការលះបង់ មិនប្រណាំងប្រជែងជាមួយអ្នកណាៗ មិនឈ្លោះប្រកែក មិនប្រកែ-ប្រកាន់ ដូច្នេះយើងក៏អាចរស់នៅជាមួយនឹងអ្វីៗក្នុងលោកនេះបានដោយការមិនចង្អៀតចង្អល់ ទាំងដោយការមិនជាប់ជំពាក់ ។

- នៅពេលខឹងព្រោះដឹងថាគេខុស គួរពិចារណាការខ្វះខាតរបស់យើង លុះបានឃើញកិលេសក្នុងខ្លួនរបស់យើងហើយ ការខឹងក្រោធក៏ទន់ចុះ ព្រោះដឹងថាកំហុសនោះៗ វាអាស្រ័យលោភៈ ទោសៈ និងមោហៈជាមូលហេតុ ដែលអកុសលមូលទាំងបីនេះ ដោយបរមត្ថគឺ មិនមែនជារបស់អ្នកណាឡើយ សត្វលោកគឺជាអ្នករងគ្រោះទាំងអស់គ្នា គួរតែជួយគ្នាដោយការផ្តល់កម្លាំងចិត្តក្នុងការប្រព្រឹត្តល្អ រកទីពឹងរៀងៗខ្លួន ។

- ត្រូវពិចារណាឲ្យយល់ច្បាស់ថា អ្វីៗដែលយើងត្រូវការនោះ គឺមិនចេះតែបានសម្រេចទេ ព្រោះថាអ្វីៗដែលកើតមាននោះប្រព្រឹត្តទៅតាមហេតុត្រឹមត្រូវណាស់ ដូច្នេះគួរតែកំណត់កាន់យកតាមសេចក្តីពិតវិញ កុំតាមចំណង់របស់កិលេសឡើយ ។

- រៀនរស់នៅជាមួយនឹងកុសលធម៌ឲ្យបានប្រាកដប្រជា ត្រូវគិតថា អ្វីៗដែលយើងចង់បាននោះ វាមិនមានតម្លៃស្មើនឹងកុសល-កម្មដែលយើងធ្វើដោយខ្លួនឯងឡើយ បើមិនបានទេ ក៏មិនបានទៅប្រឹងប្រែងបំពេញតែបុណ្យកុសល ថែរក្សាចិត្តឲ្យស្ងប់ជាការស្រេច ។

- ចិត្តក្នុងមនោទ្វារ ដឹងរឿងមិនល្អផ្សេងៗ សុទ្ធតែកើតបន្តអំពីចិត្តក្នុងបញ្ចទ្វារ ជាពិសេសគឺបញ្ចវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដូច្នេះត្រូវរលឹកដឹងថាបញ្ចវិញ្ញាណឯណានីមួយ គឺសុទ្ធតែជាវិបាករបស់កម្ម ជាបច្ច័យឲ្យបានដឹងរឿងនោះៗ ។ ក្នុងលោក ៦ នេះមានលោកភ្នែកជាដើម តើមានអ្នកណាមកធ្វើអ្វីយើង ក្រៅអំពីអារម្មណ៍របស់ចិត្ត និងចិត្តចេតសិកដឹងអារម្មណ៍នោះៗ ។ វិបាករបស់កម្មមានការឃើញ ការឮជាដើម រលត់បាត់អស់ទៅហើយ នៅឡើយតែការចាំរឿង ដែលជាសញ្ញាកើតមកតាមក្រោយរឿយៗ នាំឲ្យខឹងក្រោធកាន់ខែកាន់ឆ្នាំ គួរឲ្យស្តាយពេលវេលាដែលបានកើត

មកជាមនុស្ស ។

- ត្រូវចេះពិចារណា គុណគឺសេចក្តីល្អរបស់អ្នកដទៃនោះៗ ឲ្យបានល្អផង ព្រោះជាធម្មតានៅពេលដែលសេចក្តីក្រោធគ្របសង្កត់ចិត្ត វាធ្វើឲ្យងងឹតបិទបាំងគុណគឺសេចក្តីល្អនៃអ្នកដែលយើងកំពុងតែស្អប់ ឬកំពុងតែខឹងក្រោធនោះ ។ តាមពិត គុណដែលយើងគួរដឹងមិនចំពោះតែគុណណាដែលអ្នកនោះបានធ្វើមកលើយើងទេ ឲ្យតែសេចក្តីល្អដែលអ្នកដទៃនោះមាន ដូចជាសទ្ធាក្នុងគុណព្រះរតន-ត្រ័យក្តី ទានសីលភាវនាក្តីជាដើមនេះ កាលបើពិចារណាឃើញហើយ ក៏បានធូរថយនូវសេចក្តីក្រោធ ចេះនឹកឲ្យអភ័យដល់អ្នកដទៃនោះៗ ចេះគិតថា ជាគ្នាយើង គឺជាអ្នកថែរក្សាព្រះពុទ្ធសាសនាជាមួយគ្នា ឬជាអ្នករួមទ្រុងមច្ចុរាជជាមួយគ្នា ។

- ពិចារណាឃើញបញ្ចក្ខន្ធប្រព្រឹត្តទៅជាវដ្តទុក្ខ ដូច្នេះ គ្រប់គ្នាសុទ្ធតែជាអ្នកមានទុក្ខ មិនមានអ្នកណាយកអ្វីបានពីក្នុងលោកនេះទេ ក្នុងលោកនេះមិនមានទីពឹងឡើយ ទើបគួរករុណាគ្នា សន្តោសប្រោសប្រណី នាំគ្នាសន្សំបុណ្យរកព្រះនិព្វានជាទីពឹងវិញ ។

- ពិចារណាឃើញថា គ្រប់គ្នាធ្លាប់ជាញាតិ មានការនឹករលឹកក្នុងការព្រាត់ប្រាសគ្នា ពីជាតិមុនមក ។

- ពិចារណាឃើញថា ស្អប់អ្នកដទៃ គឺស្អប់ខ្លួនឯងជាង ព្រោះដុតចិត្តខ្លួនឯងដោយភ្លើងទោសៈ វាជាការឥតប្រយោជន៍ទាំងអស់គ្នា ។

- អប់រំមេត្តាចិត្ត ពិចារណាឃើញថា មេត្តាអ្នកដទៃ ចិត្តយើងបានបុណ្យ ។

- ពិចារណាឃើញ អ្នកដែលយើងខឹងស្អប់នោះ មិនអាក្រក់ដាក់យើង ដូចចិត្តយើងដែលខឹងស្អប់គេនោះឡើយ គួររង្កៀសអកុសលចិត្តខ្លួនឯង ។

- ពិចារណាឃើញថា បើយើងអត់ធន់បានមួយថ្ងៃ គឺមួយថ្ងៃនោះបានជារបស់យើង បើអត់ធន់មិនបានទេ មួយថ្ងៃនោះពិតជារបស់បាបហើយ ព្រោះបាបដណ្តើមបាន គួរឲ្យស្តាយ ។

- ពិចារណាឃើញថា បុណ្យឲ្យយើងបានកើតមកជាមនុស្សទាំងដែលបានដល់នូវត្រៃសរណគមន៍ទៀត ដូច្នេះយើងមកដើម្បីប្រយោជន៍ណា ត្រូវឲ្យបានសម្រេចនូវប្រយោជន៍នោះ កុំឲ្យខូចប្រយោជន៍ ខាតពេលវេលាព្រោះហេតុតែការខឹងក្រោធ ដែលការខឹងក្រោធនេះជារបស់មនុស្សល្ងង់ ធ្វើជាសត្រូវនឹងខ្លួនឯង ។

- ពិចារណាឃើញគុណរបស់ព្រះអរិយបុគ្គល ដែលលោកមានចិត្តស្ងប់រំងាប់ផុតចាកលោក ផុតចាកកង្វល់ ។

## ស្ងប់ចិត្តគឺជាសុខ

បើយើងចេះតែសម្លឹងមើលទៅរករបស់ដែលយើងអត់ តើធ្វើដូចម្តេចទៅ ដើម្បីឲ្យឃើញនូវរបស់ដែលយើងមាន ណាមួយ របស់ដែលយើងមាននោះ ក៏ចេះតែបណ្តោយឲ្យបាបយកទៅប្រើប្រាស់រាល់ថ្ងៃទៀត បានសេចក្តីថា របស់ដែលមាន មិនប្រើឲ្យបានជាប្រយោជន៍ដល់ខ្លួនឯង ហើយចេះតែចង់បានរបស់ដែលអត់ នេះឯងជាសេចក្តីទុក្ខលំបាករបស់មនុស្សលោក ។ តាមពិត សេចក្តីសុខនៅនឹងចិត្តខ្លួនឯង មិនមែនត្រូវទៅស្វែងរកក្នុងរបស់ដទៃឡើយ ឲ្យតែចិត្តស្ងប់ស្ងាល់ហើយ គឺជាសុខ ។

# ៩.ពហុវេទនីយសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ក្នុងសម័យនោះ មានជាងឈើម្នាក់ឈ្មោះបញ្ចកង្គៈ និងព្រះឧទាយីដ៏មានអាយុ ជជែកគ្នាអំពីវេទនា គឺជាងឈើថាមាន ២ ចំណែកព្រះភិក្ខុឧទាយីថាវេទនាមាន ៣ ។

ព្រះអានន្ទដ៏មានអាយុ បានយកសេចក្ដីនេះក្រាបទូលព្រះដ៏មានព្រះភាគ ទើបព្រះអង្គទ្រង់ត្រាស់សម្ដែង វេទនា ២ វេទនា ៣ វេទនា ៤ វេទនា ៥ វេទនា ៦ វេទនា ១៨ វេទនា ៣៦ និងវេទនា ១០៨ គឺវេទនាទាំងនេះព្រះតថាគត បានសម្ដែងដោយបរិយាយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ណែនាំអ្នកសិក្សាព្រះធម៌ទាំងឡាយ ឲ្យមានការព្រមព្រៀងគ្នា ដូចសេចក្ដីតទៅ

ម្នាលអានន្ទ ធម៌គឺតថាគតបានសម្ដែងដោយបរិយាយយ៉ាងនេះឯង ម្នាលអានន្ទ កាលបើធម៌ដែលតថាគតសម្ដែងហើយដោយបរិយាយយ៉ាងនេះ ជនទាំងឡាយណា មិនដឹងតាម មិនយល់ព្រម មិនរីករាយ ចំពោះភាសិតនិងពាក្យចរចាដ៏ពីរោះ ដល់គ្នា

នឹងគ្នាហើយ ការបង្កហេតុ ការឈ្លោះ ការទាស់ទែង និងការពោលចាក់ដោតគ្នានឹងគ្នាដោយលំពែងគឺមាត់ ក៏នឹងប្រាកដដល់ជនទាំងនោះ ។ ម្នាលអានន្ទ កាលបើធម៌ ដែលតថាគតសម្តែងហើយដោយបរិយាយយ៉ាងនេះ ជនទាំងឡាយណា បានដឹងតាម យល់ព្រមតាម រីករាយតាមចំពោះភាសិតនិងពាក្យចរចាដ៏ពីរោះ ដល់គ្នានឹងគ្នាហើយ ការព្រមព្រៀងគ្នា រីករាយរាក់ទាក់រកគ្នា មិនទាស់ទែងគ្នា ដូចទឹកលាយដោយទឹកដោះស្រស់ មើលគ្នានឹងគ្នាដោយភ្នែកជាទីស្រឡាញ់ ក៏នឹងប្រាកដដល់ជនទាំងនោះ ដូច្នោះឯង ។

ដើម្បីជាការគាំទ្រដល់វាទៈរបស់ជាងឈើ ( ដែលជាងឈើបានលើកឡើងថា ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងតែវេទនាពីរ គឺសុខវេទនា ១ និងទុក្ខវេទនា ១ ឯអទុក្ខមសុខវេទនានោះ ព្រះដ៏-មានព្រះភាគ ទ្រង់សម្តែងថាជាសេចក្តីសុខដ៏ល្អិតឧត្តម ) ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងព្រះសូត្រជាបន្ត អំពីកាមសុខនិងឈានសុខទាំងរូបជ្ឈានទាំងអរូបជ្ឈាន រហូតដល់សញ្ញាវេទយិត-និរោធ ។ សូម្បីចតុត្ថជ្ឈាន ប្រកបដោយឧបេក្ខាវេទនា ( ចតុក្កន័យ ) ទាំងរូបជ្ឈានទាំងអរូបជ្ឈាន ក៏ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាជាសេចក្តីសុខដ៏ប្រសើរថ្លៃថ្លា ឧត្តមប្រណីត រហូតទីបំផុតព្រះអង្គទ្រង់

ប្រកាសសម្ដែងនិរោធសមាបត្តិ ថាជាសុខ ប៉ុន្តែសុខដោយមិនមានអ្នកសោយ ពោលគឺមិនមាននូវសុខវេទនា ចំណែកកាមសុខក្តី សុខក្នុងសមាបត្តិ ៨ ក្តី ឈ្មោះថាសុខមានអ្នកសោយ ។ ព្រះដ៏មានព្រះ-ភាគ ទ្រង់បញ្ញត្តភាវៈដែលមិនមានទុក្ខទាំងអស់នោះ ថាជាសុខតែម្យ៉ាង ទោះជាសុខមានអ្នកសោយក៏ដោយ សុខមិនមានអ្នកសោយក៏ដោយ ក្នុងព្រះសូត្រនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនិរោធ-សមាបត្តិឲ្យជាប្រធាន ហើយបញ្ចប់ដោយកំពូលធម៌គឺព្រះអរហត្តដោយអំណាចវេនេយ្យបុគ្គល ។

សូមអនុមោទនា !

## ខ្លួនយើងជាមនុស្សល្អ សំខាន់ជាង

ខ្លួនយើងជាមនុស្សល្អ សំខាន់ចាំបាច់សម្រាប់ខ្លួនឯង ជាងអ្វីៗទាំងអស់ក្នុងពិភពលោក ដូច្នេះចូរកុំជាមនុស្សអាក្រក់ ព្រោះហេតុតែចង់បានអ្វីៗនោះឲ្យសោះ វាមិនមានអ្វីដែលសំខាន់សម្រាប់យើង ជាងខ្លួនយើងជាមនុស្សល្អទៅទៀតនោះទេ ។

## ម្លប់នៃព្រះធម៌

អ្នកណាស្រឡាញ់ អ្នកណាស្អប់យើងក៏ដោយចុះ គេសរសើរ ឬនិន្ទាស្រេចតែគេ ចំណែកយើងមានសេចក្ដីអត់ធន់ ចម្រើនមេត្តា មានចិត្តស្ងប់ត្រជាក់ រស់នៅក្រោមម្លប់នៃព្រះធម៌ គឺសុខហើយ ។

## ចេតិយនៃជីវិត

ការមិនធ្វើបាបទាំងពួង គឺជាបុណ្យសំខាន់ផ្នែកចាក់គ្រឹះ រួចហើយទើបដល់ព្រមដោយការបំពេញនូវកុសល គឺជាតួកណ្ដាលនៃព្រះចេតិយ ជាទីបំផុតចិត្តយើងស្អាត គឺជាកំពូលនៃព្រះចេតិយដែលសម្រាប់តម្កល់ទុកនូវនិព្វានធាតុ គឺព្រះនិព្វានជាអារម្មណ៍នៃផលសមាបត្តិ នេះគឺចេតិយនៃជីវិត ។

## យល់អំពីកុំ នៅត្រង់គឺ

កុំត្រចៀកស្រាល គឺកុំអាលជឿគេថាពិត ។

| | |
|---|---|
| កុំស្រេចតែចិត្ត | គឺត្រូវពិនិត្យចិត្តនោះជាចិត្តអ្វី ។ |
| កុំចេះតែនិយាយខ្វះគំនិត | គឺត្រូវចេះគិតមុននឹងស្រដី ។ |
| កុំចេះតែចង់កែអ្នកដទៃ | គឺត្រូវលកលៃមើលទោសខ្លួនឯង ។ |
| កុំប្រឆាំងនឹងការពិត | គឺត្រូវសុខចិត្តដោយបញ្ញា ។ |
| កុំប្រមាទក្នុងសង្ខារ | គឺត្រូវពិចារណាការមិនទៀង ។ |
| កុំបំពានអ្នកដទៃ | គឺកុំវិនិច្ឆ័យក្តីលម្អៀង ។ |
| កុំទុកចិត្តមនុស្សមិនទៀង | គឺដូចចម្រៀងកុំទុកចិត្តមេឃ ។ |
| កុំប្រមាទក្នុងជីវិត | គឺត្រូវសុចរិតប្រព្រឹត្តធម៌ ។ |
| កុំខ្លាចសេចក្តីល្អ | គឺកុំរីករវនឹងថ្ងៃខែឆ្នាំ ។ |
| កុំចង់បានសព្វគ្រប់ពីអ្នកដទៃ | គឺត្រូវលកលៃកុំឲ្យប្រេះស្រាំ ។ |
| កុំយកខ្លួនទៅប្រចាំ | គឺកុំដេកត្រាំក្នុងភពបី ។ |
| កុំប្រកាន់ក្នុងសង្ខារ | គឺវិបស្សនាឃើញការពិត ។ |
| កុំសោកសៅក្នុងជីវិត | គឺចេះសុខចិត្តព្រមលះបង់ ។ |
| កុំប្រឆាំងនឹងធម្មជាតិ | គឺត្រូវចេះឃ្លាតពីចំណង់ ។ |
| កុំចេះតែតាមចិត្តខ្លួនចង់ | គឺត្រូវឃើញត្រង់សច្ចធម៌ ៕ |

ដោយ **ប.ស.ខ.**

# ព្រហ្មវិហារធម៌

ការកសាងសេនាសនទាន មានកុដិសាលាព្រះវិហារ របង ខ្លោងទ្វារ ទិញដីដាក់វត្ត ។ល។ ទាំងអស់នេះជាវិហារទានដ៏សំខាន់ ក្នុងបណ្តាបច្ច័យទាំង ៤ ហើយដែលសំខាន់ណាស់ទៅទៀត គឺ ព្រហ្មវិហារធម៌ ដែលជាជម្រកដ៏ប្រសើររបស់ចិត្ត នៅក្នុងអារម្មណ៍ ប្រមាណមិនបាន គឺសូមឲ្យសព្វសត្វទាំងអស់បានសេចក្តីសុខ រួច ផុតចាកទុក្ខ ។

# មរតករបស់កម្ម

ដំរីស្លាប់ទៅនៅសល់ភ្លុក ខ្លាព្រៃចូលស្រុកគេទុកស្បែក
មនុស្សស្លាប់សល់ឆ្អឹងមួយចំណែក គេរ៉ែឈ្មោះដោយឡែកចែកកូនចៅ។
មនុស្សល្អបរិសុទ្ធទោះមិនល្បី ក៏មានសិរីជាញាតិផៅ
បុណ្យចែកមរតកក្រោយស្លាប់ទៅ បានជាញាតិផៅព្រះឈ្មោះមារ ។
មនុស្សល្បីក្នុងអ្វីដែលមិនល្អ ជាប់ក្នុងលោកធម៌ល្បីខ្ចរខ្ចារ
ប៉ុន្តែគ្មានទានសីលភាវនា មរតកបាបមារជាសត្វប្រេត ។

ជាសត្វនរកឬតិរច្ឆាន មិនមែនតិចប្រាណលិចអណ្តែត
មច្ចុរង់ចាំកម្មជាហេតុ មនុស្សល្អគួរវែ្អតកម្មលោកីយ៍ ៕

ដោយ **ម.ស.វ.**

## មនុស្សមិនល្អ

មនុស្សមិនល្អ ចូលចិត្តនិយាយរឿងមិនល្អរបស់អ្នកដទៃ ទាំងដែលរឿងល្អរបស់គេមានដែរ តែមិននិយាយ នេះព្រោះចិត្តឥតមេត្តា តាំងទុកអ្នកដទៃនោះជាសត្រូវរបស់ខ្លួន មានគំនុំសងសឹកសង្កត់អ្នកដទៃដើម្បីលើកខ្លួនឯង ទាំងដែលមិនដឹងថាខ្លួនឯងកំពុងតែជាមនុស្សមិនល្អ ។

## ផឹកណាស់ស្រេកណាស់

ស្រេកទឹកហើយ ទៅផឹកទឹកអំបិល វារឹតតែស្រេក យ៉ាងណាមិញ ចិត្តក្រវាយក្រវល់ រមែងត្រូវការអរិយទ្រព្យដើម្បីសេចក្តី

ស្ងប់ បែរជានាំគ្នាទៅរកតែវត្ថុសម្បត្តិ ដែលជាសម្បត្តិសម្រាប់តែរូបកាយប៉ុណ្ណោះ ម្ល៉ោះហើយ ផ្លូវចិត្តរឹតតែក្រវល់ក្រវាយឡើងក៏យ៉ាងនោះដែរ ។

## ប្រយ័ត្នស្លាក់ឆ្អឹងត្រី

យើងចូលចិត្តបរិភោគត្រី តែយើងក៏មិនភ្លេចបេះឆ្អឹងចេញដែរ យ៉ាងណាមិញ កាលដែលយើងស្រឡាញ់អ្វីៗ យើងក៏ត្រូវចេះបេះចោលចេញនូវអ្វីដែលធ្វើឲ្យយើងកើតទុក្ខសោកក៏យ៉ាងនោះដែរ ។

## ក្រទ្រព្យតែមានបុណ្យ

ក្រទ្រព្យសម្បត្តិ មិនមែនបានសេចក្ដីថាថោកទាបនោះទេ រីឯការមានបាន ក៏មិនទាន់មានឈ្មោះថាខ្ពង់ខ្ពស់នោះដែរ ។ ក្រមែនពិត តែចិត្តប្រសើរ មានព្យាយាមក្នុងការងារត្រឹមត្រូវ មានទឹកចិត្តជាមួយញាតិមិត្តសន្ដាន ទាំងបដិបត្តិបានក្នុងគុណធម៌ ដូច្នេះជីវិតពិតជាមានតម្លៃ ។ មានសម្បត្តិស្ដុកស្ដម្ភមែន តែមិនបានបដិបត្តិល្អ

ខុសសីលធម៌ ដូច្នេះគឺមិនមែនជាភាពខ្ពង់ខ្ពស់អ្វីនោះឡើយ ហើយបើនៅតែប្រមាទក្នុងជីវិតយ៉ាងនេះ នឹងជួបប្រទះនឹងសេចក្តីទុក្ខក្នុងដំណើរផ្លូវទៅមុខ ជាពិតប្រាកដ ។

## ស្រវឹងនឹងជីវិតភ្លេចសេចក្តីស្លាប់

មើលការប្រព្រឹត្តរបស់មនុស្សទាំងឡាយ រីករាយសប្បាយក្នុងបាបកម្ម ហាក់ដូចអត់ចេះស្លាប់ មិនមែនមកអំពីមិនខ្លាចស្លាប់នោះទេ តែនេះព្រោះភ្លេចខ្លួនថាអាត្មាអញត្រូវស្លាប់ លុះដល់ពេលជិតស្លាប់ ទើបសៅសោកកន្ទក់កន្ទេញថា ម៉េចបានជាខ្ញុំឆាប់ស្លាប់ម្ល៉េះ នេះហៅថាស្រវឹងក្នុងជីវិត ។

## កើតទុក្ខផ្លូវចិត្តព្រោះខ្វះបុណ្យ

ការដែលមិនមានកុសលឆន្ទៈ ព្រោះបានដឹងមកថា បុណ្យគ្រាន់តែជាជំនឿមួយថា បន្ទាប់ពីស្លាប់បានទៅកើតឋានសួគ៌ដោយសារបុណ្យទានហ្នឹងឯង វាមិនមានអ្វីឲ្យជាក់ស្តែងសោះ ម្ល៉ោះ

ហើយទើបមិនមានឆន្ទៈ ។ តាមការពិត ក្នុងចិត្តមនុស្សយើងដែលមានទុក្ខ ព្រោះមកអំពីខ្វះបុណ្យ មិនមែនខ្វះប្រាក់ទេ ហើយក៏មិនមែនមកអំពីខ្វះអ្វីដទៃទៀតក្រៅអំពីបុណ្យនោះដែរ ។ ត្រូវយល់ថា បច្ច័យ ៤ សម្រាប់រូបកាយ ចំណែកអាហារសប្បាយសម្រាប់សុខភាពផ្លូវចិត្តគឺបុណ្យ រីឯបាបទាំងឡាយជាចំណីទាស់របស់ចិត្ត សីលកម្ចាត់បង់រោគទាស់ចំណីនោះៗ បើពោលឲ្យអស់គឺសមថៈ និងវិបស្សនា ជាឱសថកម្ចាត់រាគៈ ទោសៈ មោហៈដែលជាសមុដ្ឋានរបស់រោគចិត្ត សំខាន់ម្យ៉ាងទៀត គឺពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទុកជាគិលានុបដ្ឋាក សរុបមកគឺថា បុណ្យសំខាន់ចាំបាច់ណាស់សម្រាប់អ្នកដែលមានទុក្ខទាំងឡាយ ព្រោះបុណ្យនាំមកនូវសេចក្តីសុខ ដូច្នេះទើបគួរមាននូវកុសលឆន្ទៈ ។

## សេចក្តីសំខាន់នៃសេចក្តីល្អ

បើយើងជាមនុស្សអាក្រក់ទៅហើយ តើមានអ្វីដែលល្អសម្រាប់យើងទៀត គួរគិតឲ្យយល់ថា នៅក្នុងលោកនេះ មិនមានអ្វីដែលសំខាន់សម្រាប់យើង ជាងខ្លួនយើងជាមនុស្សល្អនោះឡើយ

ដូច្នេះត្រូវចេះថែរក្សាសេចក្ដីល្អក្នុងខ្លួនយើង ដែលជាគុណភាពនៃជីវិត ម្យ៉ាងទៀត ត្រូវចេះគិតថា សេចក្ដីល្អនេះមិនមែនសម្រាប់តែយើងម្នាក់ឯងទេ គឺរមែងបានជាប្រយោជន៍ដល់អ្នកដទៃច្រើនមុខណាស់ គួរតែឃើញសេចក្ដីសំខាន់នៃសេចក្ដីល្អ ឲ្យដូចជាខ្យល់អាកាសសម្រាប់ដកដង្ហើម ដូច្នោះដែរ ។

## មើលឃើញសេចក្ដីល្អខ្លួនឯង

មានរឿងមិនសប្បាយចិត្តត្រង់ដែលថា យើងធ្វើល្អប៉ុណ្ណឹងហើយ គេនៅតែមើលយើងមិនឃើញ ។ តាមពិត ឲ្យតែយើងមើលឃើញខ្លួនឯងទៅ ក្រែងតែយើងមើលមិនដឹងសេចក្ដីល្អខ្លួនឯងតាមពិតនោះ ទើបយើងមិនសប្បាយចិត្តហ្នឹងឯង ព្រោះមិនមានអ្វីដែលគួរឲ្យរីករាយជាងការមើលឃើញសេចក្ដីល្អក្នុងខ្លួនឯងឡើយ ។

# ១០-អបណ្ណកសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនកោសល មួយអន្លើដោយភិក្ខុសង្ឃច្រើន ក៏បានដល់ព្រាហ្មណគ្រាមឈ្មោះសាលា របស់ពួកអ្នកកោសល សម័យនោះពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកសាលា ក៏បានចូលគាល់ព្រះដ៏-មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងនូវអបណ្ណក-ធម៌ គឺធម៌មិនខុស ដល់អ្នកស្រុកទាំងនោះ ដែលអ្នកស្រុកទាំងនោះសុទ្ធតែធ្លាប់បានស្ដាប់នូវវាទៈនៃគ្រូទាំងឡាយ ជាវាទៈក្នុងទិដ្ឋិទាំង ៦២ ប៉ុន្តែមិនបានកាន់យកនូវវាទៈណាមួយនោះទេ ហើយក៏មិនទាន់មានគ្រូណាមួយឲ្យជាទីគាប់ចិត្តដោយសទ្ធានោះដែរ ។ ព្រះដ៏-មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតីទាំងឡាយ កាលបើអ្នកទាំងឡាយ មិនទាន់បាននូវគ្រូជាទីគាប់ចិត្តហើយ ត្រូវប្រព្រឹត្តសមាទាននូវអបណ្ណកធម៌នេះវិញ ម្នាលគហបតីទាំងឡាយ ព្រោះថាអបណ្ណកធម៌ ដែលអ្នកទាំងឡាយបានធ្វើឲ្យបរិបូណ៌ បានសមាទានហើយ ជាធម៌ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់

អ្នកទាំងឡាយ អស់កាលជាយូរអង្វែង ។

ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងអំពីការយល់ឃើញខុសនៃបុគ្គលមិច្ឆាទិដ្ឋិ មាន ៥ ចំណែកគឺ

១- **នត្ថិកទិដ្ឋិ** បដិសេធផលវិបាករបស់កម្ម

២- **អកិរិយទិដ្ឋិ** បដិសេធកម្ម

៣- **អហេតុកទិដ្ឋិ** បដិសេធទាំងកម្មទាំងវិបាក

៤- **នត្ថិ សព្វសោ អារុប្បាតិ** អរូបព្រហ្មមិនមានដោយប្រការទាំងពួង

៥- **នត្ថិ សព្វសោ ភវនិរោធោតិ** ការរលត់ភពដោយប្រការទាំងពួង គឺព្រះនិព្វាន មិនមាន ។

**អបណ្ណកធម៌** គឺធម៌មិនខុស បានដល់ការប្រព្រឹត្តកាន់យកចំណែកខាងអត្ថិកវាទ កិរិយវាទ ហេតុកវាទ ចម្រើនអរូបជ្ឈាន និងបដិបត្តិក្នុងវិបស្សនា ។

បន្ទាប់មកទៀត ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីបុគ្គល ៤ ពួក គឺ

១- **អត្តន្តបៈ** ព្យាយាមធ្វើខ្លួនឲ្យលំបាក

២- **បរន្តបៈ** ព្យាយាមធ្វើសត្វដទៃឲ្យលំបាក

៣- **អត្តន្តបៈ** និង **បរន្តបៈ** ព្យាយាមទាំងពីរបែប

៤- **នេវត្តន្តបៈ** និង **នបរន្តបៈ** ជាបុគ្គលមិនដុតកម្តៅខ្លួនឯងផង មិនដុតកម្តៅសត្វដទៃផង ជាបុគ្គលលែងមានសេចក្តីស្រេកឃ្លាន ( និច្ឆាតោ ) មានទុក្ខរលត់ហើយ ( និព្វុតោ ) ជាបុគ្គលត្រជាក់ ( សីតីភូតោ ) មានប្រក្រតីសោយនូវសេចក្តីសុខ ( សុខប្បដិសំវេទី ) មានខ្លួនដូចជាព្រហ្ម ( ព្រហ្មភូតេន អត្តនា ) ក្នុងបច្ចុប្បន្ន ( ទិដ្ឋេវ ធម្មេ ) ។

នៅពេលចប់ព្រះធម៌ទេសនា អ្នកស្រុកសាលា បានពោលសរសើរព្រះធម៌ទេសនា និងសូមដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹកស្មើដោយជីវិត ៕

សូមអនុមោទនា !

## ពាក្យរំលឹក

ពេលខ្លះ ព្រោះហេតុតែយើងចង់បានសេចក្តីសុខពេកទៅធ្វើឲ្យយើងមិនមានសេចក្តីសុខក្នុងពេលនោះឯង ។ គួរព្យាយាមសិក្សារឿយៗ ចំពោះអ្វីដែលបានមកដល់ជីវិតនេះ ឲ្យយល់ ឲ្យឃើញ

ច្បាស់ មិនចាប់យកដោយសេចក្តីប្រកាន់ ហើយក៏មិនប្រទូស្តទាស់ដោយទោមនស្សដែរ នេះជាសេចក្តីសុខស្ងប់ដែលគួរអប់រំចម្រើន ។

ថ្ងៃណាមួយ សេចក្តីស្លាប់នឹងមកដល់ជីវិតយើង នឹងមកបង្ខំឲ្យយើងចាកចោលអ្វីៗគ្រប់យ៉ាង ដូច្នេះយើងត្រូវតែហ្វឹកហាត់ក្នុងការលះបង់អ្វីៗនោះ ឲ្យព្រម ឲ្យសុខចិត្ត ឲ្យទៅជាទម្លាប់ តាមរយៈនៃទាន សីល ភាវនា បើមិនបានហ្វឹកហាត់ទេ ដល់ពេលវេលាដែលត្រូវចាកទៅទាំងបង្ខំនោះ យើងពិតជាលំបាក ម្យ៉ាងទៀត ដល់ពេលឈឺជិតស្លាប់ វាមិនមែនដូចយើងនៅរស់សុខស្រួលទេ វាពិតជាលំបាកក្នុងរឿងដាច់ខ្យល់នេះណាស់ ដូច្នេះ ត្រូវហ្វឹកហាត់ក្នុងសេចក្តីអត់ធន់ និងកំណត់នូវវេទនា ជាតួសោយអារម្មណ៍ មិនមែនជាសត្វបុគ្គលតួខ្លួនយើង ជាអ្នកសោយឡើយ ។

# វាចាល្អ ៤ យ៉ាង

១- **សុភាសិតវាចា** ពោលពាក្យឲ្យគេព្រមព្រៀងគ្នាក្នុងផ្លូវល្អ មិនពោលញុះញង់ ។

២- **ធម្មវាចា** ពោលពាក្យមានប្រយោជន៍ មិនពោលរោយរាយឥតបានការ ។

៣- **បិយវាចា** ពោលពាក្យជាទីស្រឡាញ់ ប្រកបដោយមេត្តាចិត្ត មិនពោលទ្រគោះបោះបោក ។

៤- **សច្ចវាចា** ពោលពាក្យពិតប្រាកដ មិនពោលកុហកឡេះឡោះ ។



# សំណាងពិត

រូបរាងល្អស្រស់សម្រស់មានស្នេហ៍ មានឪម៉ែថែមិនដែលខ្វល់ខ្វាយ
បញ្ហារាក់ជ្រៅម៉ែឪដោះស្រាយ ឥឡូវប្រែកាយក្លាយជាមានគ្នា ។
សំណាងបំផុតរបស់ស្ត្រី គឺបានស្វាមីយល់ចិត្តភរិយា
សំណាងបំផុតបុរសរាល់គ្នា គឺបានភរិយាជាស្រីគ្រប់លក្ខណ៍ ។
ប៉ុន្តែសំណាងបុរសស្ត្រី សំណាងលោកីយ៍ដោយក្ដីជំពាក់
សំណាងដូចគ្នាគ្រប់គ្រាស្មោះស្ម័គ្រ តែថ្ងៃបែកបាក់ពិតជាក់ជាមាន ។
បើសំណាងល្អត្រូវបន្តសាង កុំអាងសំណាងហើយធ្វើបំពាន
សំណាងអភ័ព្វក៏ធ្លាប់ឃើញមាន ឥតធ្វើបុណ្យទានហ៊ានចាយទុនចាស់ ។
អ្នកគ្មានសំណាងក៏កុំភ័យអី ត្បិតក្នុងលោកីយ៍មានអ្វីទៀងខ្លះ
វ័យក្មេងតទៅទៀងតែជាចាស់ យូរឆាប់ប្ដូរផ្លាស់ទៀងតែមរណា ។
ទាន់ជីវិតនៅត្រូវថែកេរ្តិ៍ឈ្មោះ កុំស្លាប់ទាំងរស់ទោះក្រពិការ
ទោះអភ័ព្វស្នេហ៍តែមានមេត្តា ទានសីលរក្សាពិតជាសំណាង ។

ដោយឧបាសក **គុយ សុធន**

# គួរតែបានរីករាយ

តើអ្នកលំបាកដោយសារអ្វី ទើបមិនស្រដីមករកខ្ញុំ
ឬមួយក៏អ្នកមានគំនុំ ទើបជួបមុខខ្ញុំពុំបរិយាយ ។
បើអ្នកលំបាកដោយសារខ្ញុំ គួរកុំបន្តឱ្យវែងឆ្ងាយ
គឺមានគន្លឹះអាចដោះស្រាយ រក្សាចិត្តកាយឱ្យគង់វង្ស ។
មិនបាច់ខ្ពើមខ្ញុំម្ដុំរូបកាយ រូបខ្ញុំគង់ក្លាយជាគម្រង់
មិនបាច់មើលងាយខ្ញុំអ្នកល្ងង់ ខ្ញុំគង់ក្លាយជាធូលីដី ។
មិនបាច់ចង់ឈ្មោះខ្ញុំទេណា ខ្ញុំចាញ់តណ្ហាទល់សព្វថ្ងៃ
មិនបាច់ច្រណែននឹងខ្ញុំអី ត្បិតរូបខ្ញុំក្ដីគង់រលាយ ។
កុំចាប់កំហុសខ្ញុំអ្វីទាន កំហុសខ្ញុំមានតាំងពីនាយ
មិនបាច់កុហកខ្ញុំហើយទាយ ខ្ញុំស្ពាយសុទ្ធតែគ្រឿងកាឡៃ ។
មិនបាច់លួចខ្ញុំទេលោកអើយ ត្បិតទ្រព្យនេះហើយនាំឱ្យភ័យ
ចាំបាច់សម្លាប់ខ្ញុំធ្វើអ្វី ខ្ញុំគង់តែក្ស័យផតបីខាន ។
អ្នកមានអ្វីៗគ្រប់យ៉ាងហើយ ម្ដេចឡើយឱ្យចិត្តដុតរោលបាន
អ្វីៗមានហើយទាំងប៉ុន្មាន សមគួរតែបានរីករាយហើយ ។

( ស្រង់ន័យពីបណ្ដាញសង្គម( facebook )) ដោយឧបាសក **គុយ សុធន**

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
# ក្នុងការឧបត្ថម្ភធម្មទាន

| | |
|---|---|
| ១. លោកគ្រូ រស់ សូផាត | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. ឧបាសក សោម រតនៈ | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. ឧបាសិកា ជា សុណារី | ៨. ឧបាសិកា ប៊ិត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក ជឹម ជំនិត | ១២. ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ង៉ូវ គា | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសក ច័ន្ទ សុខុម | ១៦. ឧបាសក អ៊ឹម វ៉ៃយ៉ា |
| ១៧. ឧបាសក ម៉ៅ ម៉ន | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូផា | ២០. ឧបាសិកា ហាយច័ន្ទធរី |
| ២១. ឧបាសក គឹម សោភ័ណ | ២២. ឧបាសក ហង់ វណ្ណៈ |

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង ។

# រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
# ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

| | | |
|---|---|---|
| ១- | លោក កេត សេរីភ័ក្រ្ត និង អ្នកស្រី ប៉ុល ហគ្គា +បុត្រ ..... | ស.រ.អ. |
| ២- | ឧ.ស.កៅ សេក និង ឧ.សិ.យី សាគុណ ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ៣- | ឧ.សិ.គុជ ឡាំងអេង និង អ្នកស្រី សេង យុវធា + កូនចៅ .. | ស.រ.អ. |
| ៤- | ឧ.សិ.ង៉ែត លេន ព្រមទាំងបុត្រ និងចៅ ...................... | ស.រ.អ. |
| ៥- | ឧ.សិ.ចាន់ នារីសុខ និងក្រុមគ្រួសារ ........................... | ស.រ.អ. |
| ៦- | ឧ.សិ.ឆាន់ ហៃគីង ព្រមទាំងបុត្រ និង ចៅ .................... | ស.រ.អ. |
| ៧- | ភិក្ខុ ឆុំសាវឿន+ភិក្ខុឈួមសម្បូរ+ពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | ស.រ.អ. |
| ៨- | ឧ.ស.ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា ព្រមទាំងបុត្រ .. | ស.រ.អ. |
| ៩- | ឧ.ស.ជឹម អេងស្រ៊ន និង ឧ.សិ.វ៉ា សុខគីន ព្រមទាំងបុត្រ +ចៅ | ស.រ.អ. |
| ១០- | ឧ.សិ.ជុំ ឆដា ( ហៅ លាភ )...................................... | ស.រ.អ. |
| ១១- | ឧ.ស.ឈួន ផារិន និង ឧ.សិ.ព្រុំ ប្រណីត ...................... | ស.រ.អ. |
| ១២- | ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅៗ ............. | ស.រ.អ. |
| ១៣- | ឧ.ស.តាប ឈន និង ឧ.សិ.ព្រាប មិច .......................... | ស.រ.អ. |
| ១៤- | ឧ.សិ.តាំង លេខគៀវ ( ហៅ តាំងហ៊ាង ) ព្រមទាំងកូនចៅ . | ស.រ.អ. |
| ១៥- | ឧ.ស.តែ ប៊ុនគង់ និង ឧ.សិ.ថោង បូនី ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ១៦- | ឧ.ស.តាំង អាង និង ឧ.សិ.កួយ ឡាំហួង ព្រមទាំងបុត្រ ........ | ស.រ.អ. |
| ១៧- | ឧ.សិ.ប៉ាន សារិទ្ធ ហៅង៉ា ព្រមទាំងកូនចៅ .................... | ស.រ.អ. |
| ១៨- | ឧ.សិ.ប៊ិត ចងខាំ និង ឧ.សិ.សាន ផល្លីនព្រមទាំងបុត្រ+ចៅ. | ស.រ.អ. |
| ១៩- | ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹង រិទ្ធារី ព្រមទាំងបុត្រ ...... | ស.រ.អ. |

២០- លោក ពេជ្រ សីហា និង អ្នកស្រី ថាប់ សុរត្ន័ ................ ស.រ.អ.

២១- ឧ.ស.ភឿក វ៉ាន និង ឧ.សិ.ហ៊ូ អាត់ ព្រមទាំងកូនចៅ ...... ស.រ.អ.

២២- ឧ.ស.ម៉ៃ គួលអេង និង ឧ.សិ.រស់ កល្យាណ ................... ស.រ.អ.

២៣- ឧ.សិ.រស់ លីណា ព្រមទាំងកូនចៅ .... ស.រ.អ.

២៤- ឧ.ស.លី ឌីន និង ឧ.សិ.ថាច់ លីហ៊ាន ................................ ស.រ.អ.

២៥- ឧ.សិ.លី ប៊ូលីនស៊ីមប៊ូ ............................................. ស.រ.អ.

២៦- ឧ.សិ.លី សួវង្ស ......................................................... ស.រ.អ.

២៧- ឧ.ស.វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ+ចៅ . ស.រ.អ.

២៨- ឧ.សិ.ស៊ីវ យក់លុយ  ព្រមទាំងបុត្រ និងចៅ .................. ស.រ.អ.

២៩- ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ព្រមទាំងបុត្រ .......... ស.រ.អ.

៣០- ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ... ស.រ.អ.

៣១- ឧ.សិ.ស្រង់ អៃ និង ឧ.សិ.ស្រង់ ឡេង ព្រមទាំងបុត្រ+ចៅ ស.រ.អ.

៣២- ឧ.ស.ស្រេង វិសុទ្ធ និង អ្នកស្រី គឹម ស៊្រុនកណិកា + បុត្រ ..... ស.រ.អ.

៣៣- ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា ព្រមទាំងបុត្រ ស.រ.អ.

៣៤- ឧ.សិ.ហេង លាភ ព្រមទាំងបុត្រ និង ចៅ ...................... ស.រ.អ.

៣៥- ឧ.ស.ហោ លាន និង ឧ.សិ.ឆឹង អួន .............................. ស.រ.អ.

៣៦- ឧ.សិ.ឡុង អ៊ីម ព្រមទាំងបុត្រ និងចៅ ....................... ស.រ.អ.

៣៧- ឧ.ស.ឡេង កុយ និង ឧ.សិ.ឈឹម សេន ........................ ស.រ.អ.

៣៨- ឧ.សិ.ឡាំង គីមឆេង ព្រមទាំងបុត្រ ........................... ស.រ.អ.

៣៩- ឧ.សិ.អួន ញ៉ ........................................................... ស.រ.អ.

៤០- លោកគ្រូធម្មបណ្ឌិត អឿ សៅ .................................. ស.រ.អ.

៤១- ឧ.ស.អៀង ឆាយ និង ឧ.សិ. អៀ កេសរ ព្រមទាំងបុត្រ . ស.រ.អ.

| | | |
|---|---|---|
| ៤២- | ឧ.សិ.កែវ សុខលាភ ព្រមទាំងបុត្រ .............................. | អូស្ត្រាលី |
| ៤៣- | កញ្ញា ខុម គាដារ៉ា ( ហៅ ស្រីណេ ) .............................. | អូស្ត្រាលី |
| ៤៤- | យុវជន ខុម ច័ន្ទឪណា .................................................. | អូស្ត្រាលី |
| ៤៥- | ឧ.ស.ខុម ពុធដានី និង ឧ.សិ.គាប ពុទ្ធារី .................... | អូស្ត្រាលី |
| ៤៦- | ឧ.ស.ង៉ូវ ឈីវ និង ឧ.សិ.ហេង ពាស៊ីម ព្រមទាំងបុត្រ+ចៅ | អូស្ត្រាលី |
| ៤៧- | ឧ.សិ.ឆេង លុន ព្រមទាំងបុត្រ និងចៅ ........................ | អូស្ត្រាលី |
| ៤៨- | ឧ.សិ.ជូ រ៉េន ........................................................ | អូស្ត្រាលី |
| ៤៩- | ឧ.សិ.ឈ គឹមស៊ីន និង ក្រុមគ្រួសារកូនចៅ .................. | អូស្ត្រាលី |
| ៥០- | ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង ព្រមទាំងបុត្រ.... | អូស្ត្រាលី |
| ៥១- | លោក ញាន ហេងម៉ូវ និង អ្នកស្រី ស៊ា ចន្ថា ព្រមទាំងបុត្រ | អូស្ត្រាលី |
| ៥២- | ឧ.ស.ឌុច ផ្លែក និង ឧ.សិ.ហ៊ុន ណូក ............................. | អូស្ត្រាលី |
| ៥៣- | ឧ.សិ.តាំង ស៊ុយន .................................................... | អូស្ត្រាលី |
| ៥៤- | ឧ.ស.ទា សុង និង ឧ.សិ.ង៉ោ ចាន់ខេង ព្រមទាំងកូនចៅ .. | អូស្ត្រាលី |
| ៥៥- | ឧ.ស.ប៊ុន ហេង និង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ ......... | អូស្ត្រាលី |
| ៥៦- | ឧ.ស.ប៉ុច រឿត និង ឧ.សិ.ញូង ស៊ាងម៉េង ព្រមទាំងបុត្រ.. | អូស្ត្រាលី |
| ៥៧- | លោកយាយ ប្រាក់ខាត់+ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ | អូស្ត្រាលី |
| ៥៨- | ឧ.សិ.ពុធ សុខង៉ោ+ឧ.សិ.លី វណ្ណា និង ឧ.ស.ខួយ ចេង ... | អូស្ត្រាលី |
| ៥៩- | ឧ.សិ.ម៉េង ប៊ុន្នារី ( ហៅស្រីពៅ )និងស្វាមី ព្រមទាំងបុត្រ. | អូស្ត្រាលី |
| ៦០- | ឧ.ស.យ៉ង់ សិន និង ឧ.សិ.នន់ ហេង ព្រមទាំងបុត្រ+ចៅ. | អូស្ត្រាលី |
| ៦១- | ឧ.សិ.យិន មួយឡាង និង ស្វាមី ព្រមទាំងបុត្រ .............. | អូស្ត្រាលី |
| ៦២- | លោក យឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល +បុត្រ........ | អូស្ត្រាលី |
| ៦៣- | ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង ព្រមទាំងបុត្រ . | អូស្ត្រាលី |

| | | |
|---|---|---|
| ៦៤- | ឧ.ស.រាជ ស៊ាង និង ឧ.សិ.វង់ រិទ្ធ ព្រមទាំងបុត្រ ........... | អូស្ត្រាលី |
| ៦៥- | ឧ.សិ.លឹម ស៊ូឆេង ព្រមទាំងកូនចៅ .......................... | អូស្ត្រាលី |
| ៦៦- | ឧ.ស.លឹម ហុងលី និង ឧ.សិ.ស៊ឹម តេងគី ព្រមទាំងបុត្រ... | អូស្ត្រាលី |
| ៦៧- | ឧ.ស.សរ ប៊ុនធឿង ព្រមទាំងបុត្រ និងចៅ.................. | អូស្ត្រាលី |
| ៦៨- | ឧ.ស.ស៊ីវ មាស និង ឧ.សិ.លាង ណាំសួរ ព្រមទាំងកូនចៅ.. | អូស្ត្រាលី |
| ៦៩- | ឧ.សិ.សុខ ណារី និង ស្វាមី ព្រមទាំងបុត្រ .................... | អូស្ត្រាលី |
| ៧០- | កញ្ញា ស៊ុយ ដាណែត ............................................ | អូស្ត្រាលី |
| ៧១- | ឧ.ស.ស៊ូ ឃីម និង ឧ.សិ.សៀង តិច ព្រមទាំងបុត្រ+ចៅ.. | អូស្ត្រាលី |
| ៧២- | ឧ.សិ.សៀង វួច ព្រមទាំងកូនចៅ .............................. | អូស្ត្រាលី |
| ៧៣- | ឧ.សិ.សេង សៀងឈុន ព្រមទាំងបុត្រ និងចៅ ............. | អូស្ត្រាលី |
| ៧៤- | ឧ.ស.សំ សុខគុណ និង ឧ.សិ.លី សៀមហៀង + បុត្រ ... | អូស្ត្រាលី |
| ៧៥- | កុង ហេង ឡេងថៃ និង ម៉ា អ៊ា គីមទាង+ចៅថៃ ឃីអ៊ុយ | អូស្ត្រាលី |
| ៧៦- | ឧ.សិ.ហេង ពាអ៊ី និង ឧ.ស.អេង តាយ+កូនអេង ឡាយហួរ | អូស្ត្រាលី |
| ៧៧- | លោកម្ចាស់ សីលបាវរោ ឡូញ ផល្លី ........................... | អូស្ត្រាលី |
| ៧៨- | ឧ.ស.ឡៅ គីមងួន និង ឧ.សិ.ដួង លី ព្រមទាំងបុត្រ ........ | អូស្ត្រាលី |
| ៧៩- | ឧ.សិ.អ៊ន ម៉ា ព្រមទាំងកូនចៅ .................................... | អូស្ត្រាលី |
| ៨០- | ឧ.សិ.អ៊ុច សុផល្លី ព្រមទាំងកូនចៅ .............................. | អូស្ត្រាលី |
| ៨១- | HENG Srey Chea+HENG Srey Chan+H.Srey Neang. ... | អូស្ត្រាលី |
